OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2016, 13:40
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៦៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de Wilde d'Estmael)*

លោក ស្រ៊ា រតនៈ

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោក ហុង គីមសួន

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរូដ៍ | បារាំង |
| លោក សៅ វ៉ន (2-TCW-989) | ខ្មែរ |
| លោក មាស វឿន (2-TCW-1008) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅ សាក្សី៖ លោក សៅ វ៉ន** (2-TCW-989)

សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី.......... ទំព័រ ៣

**ការសួរសំណួរទៅ សាក្សី៖ លោក មាស វឿន** (2-TCW-1008)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី .......... ទំព័រ ២៨

សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី.......... ទំព័រ ៣៣

សួរដោយវាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី .......... ទំព័រ ៥៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:០៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី សៅ វ៉ន បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1008។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់ ក្នុងសិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក សៅ វ៉ន លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-1008។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ញាតិ ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ សាក្សីមានមេធាវីប្រឹក្សា គឺលោកស្រីមេធាវី សុខ សុជាតា។

សូមអរគុណលោកប្រធាន។

[០៩:០៨:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ុយ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសូមលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះខ្លាំង វិលមុខនៅពេលបម្លាស់ទី និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៩:៤៩]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដើម្បីមានឱកាសសួរដោលចំពោះសាក្សីរូបនេះ។ ដំបូងនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងមេធាវី សហព្រះរាជអាជ្ញា។

[០៩:១០:២០]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ខ្ញុំជាមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា។ ប្រហែលជាលោកចាំខ្ញុំហើយ ដែលខ្ញុំសួរសំណួរលោកនៅខែកក្កដា ឆ្នាំទៅ នៅក្នុងតុលាការកំពូល។ ខ្ញុំនឹងសួរសំណួរលោកនូវសំណួរមួយចំនួនទាក់ទងទៅនឹងសក្ខីកម្មដែលលោកបានឆ្លើយកាលពីម្សិលមិញនៅទីនេះ។

កាលពីម្សិលមិញ ហើយនៅសវនាការតុលាការកំពូលនោះ លោកសាក្សី លោកបាននិយាយលម្អិតអំពីការប្រជុំពីរ។ មួយក្នុងចំណោមនោះ គឺការប្រជុំបន្ទាន់ ឬក៏ប្រញាប់នៅភ្នំត្រែល ហើយនិងការប្រជុំមួយទៀតនៅទីរួមខេត្តតាកែវ។ ហើយខ្ញុំនឹងសួរសំណួរច្រើនទៀតទាក់ទងទៅនឹងការប្រជុំបន្ទាន់នៅភ្នំត្រែលនៅពេលក្រោយ ប៉ុន្តែឥឡូវនេះ ខ្ញុំសួរអំពីការប្រជុំនៅទីប្រជុំជនខេត្តតាកែវមុនសិន។

ខ្ញុំនឹងសួរសំណួរបែបនោះ ដោយត្រឡប់ទៅសក្ខីកម្មរបស់លោក ដែលលោកបានឆ្លើយទៅអង្គជំនុំជម្រះតុលាការកំពូលនៅទីនេះ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥។ លោកសាក្សីប្រហែលជានៅម៉ោង១០:៣៥ ព្រឹកនៅថ្ងៃនោះ ខ្ញុំបានសួរលោក ថាតើលោកចាំពីការប្រជុំនៅទីក្រុងតាកែវដែរឬទេ ហើយខ្ញុំនឹងអានចម្លើយដែលលោកបានឆ្លើយពីមុននៅពេលនោះ។ លោកបានបញ្ជាក់នៅម៉ោង១០:៤៣ ដូចខាងក្រោមនេះ ខ្ញុំដកស្រង់សម្តីលោក៖ “បាទ ខ្ញុំនៅចាំគឺប្រជុំនោះ ការប្រព្រឹត្តឡើងនៅក្នុងខេត្តតាកែវ” ហើយខ្ញុំសួរសំណួរលោកបន្ទាប់មកទៀតនៅថ្ងៃនោះដែរ “តើឥឡូវនេះលោកចាំដែរទេថា លោកបានប្រជុំ -- ចូលរួមប្រជុំពីរ មួយគឺនៅភ្នំត្រែល មួយទៀតនៅទីប្រជុំជនខេត្តតាកែវ ដែលពិភាក្សាអំពីជោគវាសនានៃអតីតទាហានលន់ នល់ ឬមន្ត្រីលន់ នល់”។

[០៩:១៣:០៣]

ហើយខ្ញុំសួរថា៖ “តើពិតដែរទេ ដែលមានការណែនាំមិនឲ្យមានការប៉ះពាល់ដល់អតីតទាហានលន់ នល់ ពីថ្នាក់ក្រោមដល់ស័ក្តិ៥?” ហើយលោកឆ្លើយដូចខាងក្រោមនេះ៖ “បាទ ពិតណាស់ហើយ គឺថាចំណុចសង្ខេបរបស់លោកទាំងពីរនោះគឺត្រឹមត្រូវហើយ” លោកឆ្លើយថាអ៊ីចឹងកាលណោះ។ នៅខាងក្រោមបន្តិចទៅទៀត លោកបាននិយាយអំពីការប្រជុំនៅទីរួមខេត្តតាកែវដែលថា ប្រជុំនៅខាងលិចផ្សារចាស់ គឺនៅខាងលិចផ្សារចាស់ បន្ទាប់មក លោកបាននិយាយដូចតទៅនេះ ហើយនេះគឺជាចំណុចដែល

នឹងខ្ញុំសួរ -- ខ្ញុំនឹងសួរលោក។

នៅម៉ោង១១:០៩នាទី លោកបាននិយាយដូចខាងក្រោមនេះ នៅពេលដែលលោកពិភាក្សាអំពីកិច្ចប្រជុំនៅទីរួមខេត្តតាកែវ។ ខ្ញុំដកស្រង់សម្ដីលោកជូនលោកស្ដាប់ឡើងវិញ៖ “ខ្ញុំអាចនៅចាំបានថា ខ្ញុំបានប្រុងប្រយ័ត្នដែលថាទាហានថ្មើរជើងពីថ្នាក់ទាប ពលទោទៅដល់ថ្នាក់ស័ក្តិ៥ មិនត្រូវប៉ះពាល់ទេ អ្វីដែលខ្ញុំចាំពីកិច្ចប្រជុំនោះ ដែលខ្ញុំអាចប្រាប់លោកថា នៅពេលដែលសង្គ្រាមទោះបីជាមុនរំដោះបានប្រទេសទាំងស្រុងក៏ដោយ ខៀវ សំផន បានប្រកាសតាមវិទ្យុថា ទាហានពលទោ ទាហានថ្មើរជើងគឺថា ហើយនិងមន្ត្រី ហើយពួកគហបតី ហើយនិងជនរួមជាតិ ហើយអ្នកដែលចូលរួមក្នុងរណសិរ្សរួបរួមជាតិ នឹងត្រូវបានអនុគ្រោះ។ ហើយរណសិរ្សរួបរួមជាតិ នឹងចោទប្រកាន់តែជនប្រាំពីររូបទេ មាន លន់ នល់, សិរិមតៈ, អ៊ិន តាំ, សូស្តែន ហ្វៃណង់ដែស, ឡុង បូរ៉េត, ចេង ហេង ហើយនិង សឺង ង៉ុកថាញ់។ នេះហើយជាអ្វីដែលខ្ញុំចាំ”។ សូមចប់សេចក្ដីដកស្រង់។

ឥឡូវនេះ ខ្ញុំសួរលោកព្រឹកនេះ លោកសាក្សី គឺសួរដូចខាងក្រោមនេះ។ តើលោកអាចពន្យល់ពីមូលហេតុ ហេតុអ្វីថាលោកចងចាំពីសុន្ទរកថារបស់លោក ខៀវ សំផន នៅពេលដែលលោកនិយាយអំពីការប្រជុំដែលលោកបានចូលរួមនៅក្នុងទីរួមខេត្តតាកែវ?

[០៩:១៥:៣៣]

**ឆ៖** ខ្ញុំសូមធ្វើការបញ្ជាក់ជម្រាបជូនទៅលោកបានជ្រាបថា អ្វីដែលខ្ញុំបានចងចាំនោះ គឺលោកអ៊ំ ខៀវ សំផន គាត់បានប្រកាសមុនរំដោះទូទាំងប្រទេស គាត់និយាយដូចខ្ញុំបានលើកឡើងហើយថានាយទាហាន ពលទាហាន អ្នករដ្ឋការស៊ីវិល ឲ្យតែដាក់អាវុធចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជារណសិរ្សរួបរួមជាតិកម្ពុជាលើកលែងទោស។ រណសិរ្សរួបរួមជាតិកម្ពុជា វិនិច្ឆ័យទោសប្រហារជីវិតតែលន់ នល់, សិរិមតៈ, អ៊ិន តាំ, សុះស្តែន, ឡុង បូរ៉េត, ចេង ហេង បាទ នេះជាការពិតហើយដែលលោកបានសួរខ្ញុំពេលនេះ ហើយខ្ញុំឆ្លើយ ខ្ញុំនៅចងចាំ បាទ សូមអស់យោបល់។

**ស៖** បាទ ខ្ញុំយល់ តើអាចទៅរួចដែរទេ ដែលថារឿងនេះកើតឡើងជាយូរណាស់មកហើយ។ ខ្ញុំចង់ឲ្យលោកត្រឡប់ទៅមើលពិនិត្យការចងចាំរបស់លោក អំពីការប្រជុំនៅទីរួមខេត្តតាកែវ ហើយលោកប្រាប់ខ្ញុំនិងជម្រាបតុលាការថាតើលោកនឹកឃើញថា ពីការប្រជុំជាក់លាក់មួយនោះ លោកពិតជាបាននឹកឃើញអ្វីជាសុន្ទរកថា លោក ខៀវ សំផន ដែរឬទេ?

**ឆ៖** បាទសូមធ្វើការបញ្ជាក់ជម្រាបជូន ពេលនោះសង្គ្រាមគឺនៅមិនទាន់បានបញ្ចប់ទេ មិនទាន់

ទទួលជ័យជម្នះទេ ក៏ប៉ុន្តែគាត់ប្រកាសនោះ ខ្ញុំចងចាំតាមវិទ្យុ ហើយវិទ្យុពេលហ្នឹងក៏មិនទូលាយដែរទេ ក៏បើកស្ដាប់។ ហើយកាលក្នុងសង្គ្រាមនោះ ពីម្សិលមិញ ខ្ញុំបានលើកឡើងហាក់ដូចជាភ្លេចបន្តិចផងដែរ អំពីសារាចរ ក្នុងសង្គ្រាម គឺឱ្យកម្មាភិបាល មានវិធានការប្រុងប្រយ័ត្នចំពោះអ្នករដ្ឋការចាស់។ បាទ ប្រើពាក្យ "រដ្ឋការចាស់" ហ្នឹង បានន័យថា មេឃុំជំទប់ ប៉ូលិសទាហាន និងគ្រូបង្រៀនផងដែរ ដែលរស់នៅក្នុងតំបន់រំដោះ បាទ ដើម្បីខ្លាចក្រែងកម្លាំងទាំងអស់នោះ មានប្រតិកម្មប្រឆាំងនឹងចលនាបដិវត្តន៍ ប្រជាជាតិប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំក៏ចងចាំការងារនោះ ប៉ុន្តែដល់មុនរំដោះទូទាំងប្រទេស អ៊ំ ខៀវ សំផន គាត់បានលើកឡើងថា នាយទាហាន ពលទាហាន អ្នករដ្ឋការឱ្យទៅដាក់អាវុធចូលរួមនោះ យើងនឹងលើកលែងទោស។ បាទ សូមធ្វើការបញ្ជាក់ជម្រាបប៉ុណ្ណោះ សូមអស់យោបល់បាទ។

[០៩:១៩:២២]

**ស៖** ខ្ញុំយល់ពីចម្លើយរបស់លោក ប្រហែលជាខ្ញុំត្រូវព្យាយាមសួរលោកតាមវិធីផ្សេង។ នៅក្នុងចម្លើយដដែល ដែលលោកឆ្លើយនៅអង្គជំនុំជម្រះតុលាការកំពូល នៅពេលដែលខ្ញុំសួរសំណួរលោកអំពីការប្រជុំនៅខេត្ត ទីរួមខេត្តតាកែវ ថាលោកមានការយកចិត្តទុកដាក់ខ្លាំង គឺថាអារម្មណ៍កាលនោះ ដែលថាមានការយកចិត្តទុកដាក់។ តើមានអ្វីដែលត្រូវយកចិត្តទុកដាក់ខ្លាំង គឺថាអាចនឹងផ្សាភ្ជាប់ទៅនឹងបងប្រុសរបស់លោក ដែលលោកបានឆ្លើយកាលពីម្សិលមិញជូនតុលាការហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមគោរព និងសូមឆ្លើយ។ អ្វីដែលខ្ញុំបានទៅប្រជុំនៅក្រុងតាកែវនោះ កន្លែងផ្សារចាស់នោះ គឺខ្ញុំរីករាយ ព្រោះថាជ័យជម្នះ សង្គ្រាមដែលបាញ់គ្នាទៅវិញទៅមកគឺបញ្ចប់។ ដូច្នេះ ការសប្បាយនេះ មិនមែនសប្បាយទៅលើជីវិតបងខ្ញុំតែម្នាក់នោះទេ គឺជីវិតទូទៅដែលមានឈ្មោះជាអ្នករដ្ឋការ ដូចម្សិលមិញ ខ្ញុំសូមកែសម្រួលសម្ដីខ្ញុំបន្តិចផងដែរ ព្រោះថា នៅពេលដែលបង សៅ ស៊ុំ ត្រឡប់ទៅដល់ផ្ទះ គេនៅអនុវត្តសារាចរចាស់ក្នុងសង្គ្រាម ថាឱ្យប្រុងប្រយ័ត្នអ្នករដ្ឋការដែលមានតួនាទីមេឃុំ ជំទប់ រហូតទាហាន គ្រូបង្រៀននោះ។ អ៊ីចឹងហើយ ដល់តែពេលនោះ ឃើញគេចាប់ គេហៅបងឱ្យទៅរៀនសូត្រ។ អ៊ីចឹងទៅអ្វីដែលខ្ញុំចងចាំប្រាកដនោះ ក្រោយពីអ៊ំ ខៀវ សំផន និយាយថា "បញ្ហាការអប់រំ រៀនសូត្រនេះ គឺត្រូវបញ្ចប់ហើយពេលនោះ" នេះការចងចាំរបស់ខ្ញុំ ដែលខ្ញុំរៀន និងចងចាំពេលនោះ បាទ សូមអស់យោបល់។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយ -- មិនចុងក្រោយទេបាទ សំណួរទាក់ទងទៅនឹងពេលវេលា។ តើវាអាចទៅរួចដែរឬទេថា ការប្រជុំនៅទីរួមខេត្តតាកែវ កើតឡើងភ្លាមៗបន្ទាប់ពី

ការរំដោះនៅខែមេសា ឆ្នាំ១៩៧៥ មិនមែននៅឆ្នាំ១៩៧៦ មួយឆ្នាំក្រោយពីហ្នឹងទេ។ តើទៅរួចអ៊ីចឹងទេលោកសាក្សី?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូនជាថ្មីម្ដងទៀត។ ការប្រជុំនៅទីរួមខេត្តតាកែវនោះ គឺនៅក្នុងឆ្នាំ១៩៧៦ ដែលក្នុងរយៈកាលនោះគឺ ខ្ញុំមកនៅតំបន់២៥ហើយ។ ដូច្នេះ ខ្ញុំទៅរួមប្រជុំនៅទីនោះមានឈ្មោះ ដូចខ្ញុំបានជម្រាបខាងភូមិភាគនិរតី ដែល តាម៉ុក គាត់បានឲ្យខេត្តមួយៗ ហៅកម្មាភិបាលទៅរៀនសូត្រ ទៅប្រជុំពេលនោះ បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន។ បាទ សូមអស់យោបល់។

[០៩:២៣:២៦]

**ស៖** អរគុណលោកសាក្សី។ មូលហេតុដែលខ្ញុំសួរសំណួរនេះទៅលោកអំពីកាលបរិច្ឆេទនោះ គឺដោយសារផ្អែកទៅលើបញ្ហាមួយទៀតផងដែរ គឺថាមានកម្មាភិបាលមួយទៀតដែលលោកស្គាល់ ក៏និយាយអំពីការប្រជុំនៅទីរួមខេត្តតាកែវដែរ ដែលថានៅក្នុងការប្រជុំនោះគេមានពិភាក្សាអំពីជោគវាសនារបស់ទាហានលន់នល់ពីថ្នាក់ក្រោមមកដល់ស័ក្តិ៥ គេមិនឲ្យប៉ះពាល់ទេ។ សាក្សីនោះ ឈ្មោះ តាជឹមឈ្មោះគាត់ ពេជ្រ ជឹម។ គាត់និយាយអំពីការប្រជុំនេះ ក៏ប៉ុន្តែគាត់ផ្ដល់សេចក្ដីលម្អិត ច្បាស់អំពីទីតាំងនៃការប្រជុំនោះ ហើយខ្ញុំព្យាយាមចង់ឲ្យដឹងថា តើគាត់និយាយពីការប្រជុំតែមួយដែលលោកបានចូលប្រជុំ ឬក៏ការប្រជុំខុសពីអ្វីដែលលោកបានចូលរួមនៅក្នុងខេត្តតាកែវនោះ?

លោកប្រធាន ខ្ញុំយោងទៅរកសក្ខីកម្មរបស់ ពេជ្រ ជឹម គឺថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ប្រហែលជាម៉ោងប្រាំបួនកន្លះពេលព្រឹក។

លោកសាក្សី ខ្ញុំបានសួរសំណួរនេះទៅ ពេជ្រ ជឹម។ ហើយគាត់ឆ្លើយថា គាត់យល់ស្របថាគាត់បានចូលរួមការប្រជុំនោះ ហើយគាត់បាននិយាយថា ខ្ញុំគ្រាន់តែចូលប្រជុំនោះ បន្ទាប់ពីឆ្នាំ១៩៧៥ នៅខាងក្រោយមន្ទីរបក្ស។ នៅក្នុងនោះ តាម៉ុក ក៏បានចូលរួមដែរ។ បន្ទាប់មកគាត់ក៏បន្ត នៅក្នុងខេត្តតាកែវ គឺបន្ទាប់ពីថ្ងៃរំដោះ។ ការប្រជុំនៅទីរួមខេត្តតាកែវ គឺបន្ទាប់ពីឆ្នាំ១៩៧៥ មានន័យថា បន្ទាប់ពីថ្ងៃទី១៧ មេសា ៧៥ គឺនៅក្នុងផ្ទះមួយនៅតាមមាត់បឹងមួយនៅខាងជើងផ្នែកខាងជើងនៃទីក្រុងតាកែវ។ លោកសាក្សីខ្ញុំមិនសូវស្គាល់ទីតាំងភូមិសាស្ត្រនៅទីរួមខេត្តតាកែវទេ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់។ លោកបាននិយាយអំពីទីតាំង គឺថា នៅខាងលិចផ្សារចាស់។ ប៉ុន្តែ ពេជ្រ ជឹម គាត់យោងទៅរកការប្រជុំមួយដែលធ្វើឡើងនៅផ្ទះ នៅតាមបណ្ដោយមាត់បឹង ឬក៏តាមមាត់ស្ទឹងបាទ។ អ៊ីចឹងខ្ញុំសួរលោកថា តើគាត់និយាយពីការប្រជុំផ្សេងមួយទៀត ខុសពីអ្វីដែលលោកចូលរួមនៅក្នុងខេត្តតាកែវ ឬក៏គាត់និយាយពីការប្រជុំតែ

មួយដែលលោកបានចូលរួមដែរ?

[០៩:២៦:១៥]

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន គឺការប្រជុំនោះ ពេលដែលខ្ញុំទៅប្រជុំនៅផ្សារចាស់ក្រុងតាកែវនោះ គឺ ពេជ្រ ជឹម ខ្ញុំមិនបានដឹងថា គាត់ចូលរួម ឬអត់ទេ។ តែដោយឡែកដែលលោកបានលើកឡើងអំពីផ្ទះដែល ពេជ្រ ជឹម បានលើកឡើងនោះ គឺមានមែននៅត្រង់បឹងខាងលិចផ្សារក្រុង -- ផ្សារចាស់ក្រុងតាកែវ ហ្នឹងដែលកន្លែង តាម៉ុក នៅ។ ដូច្នេះ ក្នុងក្របខ័ណ្ឌហ្នឹង ខ្ញុំមិនបានយល់ដឹងវែងឆ្ងាយទេ ពីព្រោះតាម៉ុក ក្រែងគាត់ហៅក្របខ័ណ្ឌ ពេជ្រ ជឹម នេះគាត់នៅជាប់ជើងជាមួយនឹងស្រុក។ បាទ ការលើកឡើងបញ្ជាក់ហេតុផល សូមជម្រាបជូនតែប៉ុណ្ណេះ។ សូមអស់យោបល់។

**ស៖** ដើម្បីឲ្យប្រាកដ ខ្ញុំយល់ពីចម្លើយរបស់លោកឲ្យបានច្បាស់នោះ តើលោកកំពុងតែនិយាយថា គាត់អាចនឹងសំដៅទៅរកការប្រជុំមួយផ្សេង តាជឹម ខុសពីការប្រជុំមួយដែលលោកបានចូលរួមនៅក្នុងខេត្តតាកែវហ្នឹង ឬយ៉ាងដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ អរគុណលោកប្រធាន។ ឥឡូវនេះ មេធាវីការពារក្ដីព្យាយាមនាំមុខ ហើយសុំឲ្យសាក្សីឆ្លើយស្មានព្រាវហើយ ហើយឲ្យគាត់បញ្ជាក់ តាជឹម គាត់រៀបរាប់ពីទីតាំងប្រជុំរបស់ ពេជ្រ ជឹម ហ្នឹងឲ្យសាក្សីបញ្ជាក់។ ហើយគឺថា សូមឲ្យសាក្សីឆ្លើយពីអ្វីដែលគាត់មិនអាចឆ្លើយបាន ចង់ឲ្យគាត់បញ្ជាក់ពីការកំណត់ទីតាំងរបស់ ពេជ្រ ជឹម មិនអាចទៅរួចលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំមានសិទ្ធិសួរសំណួរនេះ ពីព្រោះសាក្សីនេះ ក៏បានរៀបរាប់ពីទីតាំងនៃការប្រជុំមួយគាត់ឆ្លើយថានៅខាងលិចផ្សារចាស់។ តាជឹម គឺថាយោងទៅរកការប្រជុំមួយនៅកន្លែងផ្សេង។ ខ្ញុំមិនទាន់ច្បាស់ទេ អ៊ីចឹងខ្ញុំរីករាយនឹងសួរសំណួរនេះឡើងវិញក៏បាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីការប្រជុំដែល ពេជ្រ ជឹម គាត់បាននិយាយពីទីតាំងនោះ។ ផ្អែកលើការយល់

ដឹង និងបទពិសោធន៍របស់លោកអំពីទីក្រុងតាកែវ តើទីតាំងដែលគាត់និយាយនោះ ជាការប្រជុំផ្សេងពីអ្វីដែលលោកបាននិយាយថា លោកចូលរួមជម្រាបតុលាការនេះ កាលពីម្សិលមិញ និង ព្រឹកនេះដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន គឺការប្រជុំនោះ ផ្សេង។ បាទ សូមអស់យោបល់។

**ស៖** បាទ អរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំត្រឡប់ទៅការប្រជុំមួយផ្សេងទៀត។ គឺការប្រជុំនៅភ្នំត្រែល សូមដាក់នៅក្នុង "អាហ្នឹងជាការប្រជុំបន្ទាប់ ឬក៏ប្រញាប់"។ ម្សិលមិញ ហើយនិងសក្ខីកម្មពីរមុនរបស់លោក គឺថាការចង់ចាំរបស់លោកអំពីការប្រជុំនោះ គឺថាកើតឡើងមួយខែ ឬក៏ពីរខែ បន្ទាប់ពីការរំដោះ។ ឥឡូវនេះ ខ្ញុំព្យាយាមចង់រកឲ្យឃើញថា តើកាលបរិច្ឆេទជាក់លាក់ដែលលោកចាំហ្នឹងមួយណា? ជាពិសេសហ្នឹងលោកសាក្សី ខ្ញុំចង់សួរដូចខាងក្រោមនេះ។ នៅពេលដែលលោកទៅចូលរួមប្រជុំនៅភ្នំត្រែល តើលោកនឹកឃើញអ្នកណាម្នាក់នៅក្នុងការប្រជុំនោះ ឬក៏មុនពេលការប្រជុំនោះដែលនិយាយពីការប្រជុំមួយធំជាងហ្នឹងនៅភ្នំពេញ នៅថ្ងៃទី២០ ថ្ងៃទី២១, ២២ ខែឧសភា ដែលកម្មាភិបាលរាប់រយនាក់ត្រូវបានគេអញ្ជើញឲ្យទៅចូលរួមក្នុងការប្រារព្ធជ័យជម្នះ១៧ មេសា?

**ឆ៖** សូមធ្វើការជម្រាបជូន គឺខ្ញុំអត់បានដឹងទេ ការប្រជុំនៅទីក្រុងភ្នំពេញនោះ។ បាទ សូមអស់យោបល់ហើយ។

**ស៖** មិនបញ្ហាអីទេលោកសាក្សី។ ឥឡូវនេះ ខ្ញុំយោងទៅរកអ្វីដែលៗគិតថា លោកមិនបានដឹងអំពីរឿងហ្នឹងទេ ប៉ុន្តែលោកអាចដឹងឧទាហរណ៍ស្រដៀងហ្នឹង។

លោកប្រធាន ខ្ញុំនឹងត្រឡប់ទៅប្រើសៀវភៅរបស់ ប៊ិន ឃៀរនិន E3/1593, អង់គ្លេស ERN 01150043 ទំព័រ៩២ នៅក្នុងសៀវភៅ, បារាំង 00638827, ខ្មែរ 00637496។ ឃៀរនិន ជាបញ្ញវន្តគាត់និយាយយោងទៅរកអត្ថបទសារព័ត៌មាននៅក្នុងសារព័ត៌មានបាងកកប៉ុស្ត៍។ គាត់សរសេរអំពីអតីតអ្នករដ្ឋការលន់ នល់ ហើយសមាជិកក្រុមគ្រួសារនៅក្នុងសៀវភៅរបស់គាត់ គាត់សរសេរដូចខាងក្រោមនេះ៖ តាមពិត -- សូមអភ័យទោស ខ្ញុំនឹងចាប់ផ្តើមតិចបាទ -- "ប្រភពឯករាជ្យបានរាយការណ៍ថាអំណាចមជ្ឈិមគឺថា បញ្ជាឲ្យមានការសម្លាប់ ប៉ុន្តែតាមនៅថ្ងៃទី២០ មិថុនា ឆ្នាំ១៩៧៥ នៅក្នុងព័ត៌មានបាងកកប៉ុស្ត៍នោះគឺថាៗ អតីតមន្ត្រីដែលបានរត់ចេញជាមួយ -- ទាំងក្រុមគ្រួសារនៅថ្ងៃទី២៤ ឧសភាហ្នឹង គេត្រូវបានគេឃាត់ខ្លួន ហើយគេមានសំណាង គឺថាពីរបីថ្ងៃក្រោយមកគឺគេមានបញ្ជាថា មិនឲ្យមានការសម្លាប់អតីតទាហាន ឬក៏មន្ត្រីរដ្ឋការលន់ នល់ ទេ"។ បញ្ចប់សេចក្តីដកស្រង់។

លោកសាក្សី បីថ្ងៃ មុនខែឧសភា ២១ គឺថា អាចនឹងខែឧសភា ថ្ងៃទី២០-២១ គឺថាអាចនឹងមានការប្រជុំមួយនៅថ្ងៃទី២០-២១ ខែឧសភា ដែលថា គេបានទទួលបទបញ្ជានៅថ្ងៃទី២៨ ខែឧសភា។ តើការប្រជុំនៅភ្នំត្រែលធ្វើឡើងនៅកាលបរិច្ឆេទណាមួយនៅក្នុងរវាងថ្ងៃទី២២ ទៅថ្ងៃទី២៨ ខែឧសភា នៅឆ្នាំ១៩៧៥ ហ្នឹងដែរឬទេ លោកសាក្សី?

[០៩:៣៤:១៣]

**ឆ៖** បាទ ខ្ញុំសូមធ្វើការបញ្ជាក់ ឆ្លើយបំភ្លឺអ្វីដែលខ្ញុំបានទៅប្រជុំនៅភ្នំត្រែលនោះៗ ខ្ញុំមិនបានចងចាំនៅថ្ងៃពិតប្រាកដទេ ក៏ប៉ុន្តែទទួលស្គាល់ការចងចាំនោះ គឺនៅក្រោយថ្ងៃ១៧ មេសា ជ័យជម្នះ ក៏ប៉ុន្តែពេលរយៈពេលនោះមិនយូរវែងពេក មិនយូរពេកទេបាទ។ គឺក្រោយហ្នឹង ខ្ទង់រយៈកាលមួយខែ ជាងមួយខែ ក្នុងចន្លោះហ្នឹង។ បាទ សូមអស់យោបល់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅសុន្ទរកថារបស់ ខៀវ សំផន ដែលលោកទើបតែយកមកនិយាយអម្បាញ់មិញ គឺនៅក្នុងពេលឆ្លើយចំពោះមុខតុលាការកំពូល ក៏ដូចជាព្រឹកមិញនេះផងដែរ។ នៅក្នុងកំណត់ហេតុ -- នៅក្នុងចម្លើយរបស់លោកនៅម៉ោង ១៥:២៨ ដែលឆ្លើយជូនតុលាការកំពូលលោកបាន -- ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានឮ ខៀវ សំផន និយាយនៅមុនពេលរំដោះ គឺថាហើយសូមឱ្យកងទ័ពដែលអំពាវនាវឡើងដោយតាម៉ុកហ្នឹង គឺថា ឱ្យសម្រុកវាយដណ្ដើមយកភ្នំពេញ។" លោកនៅចាំសុន្ទរកថារបស់ ខៀវ សំផន នៅពេលនោះទេ?

**ឆ៖** បាទ សូមធ្វើការជម្រាបជូន។ អ្វីដែលមុនរំដោះទូទាំងប្រទេសនេះគឺសម្ដីតាម៉ុក ឱ្យកងទ័ពវាយសម្រុកចូលទីក្រុងភ្នំពេញ ហើយរំដោះទីក្រុងភ្នំពេញពិតប្រាកដមែន ព្រោះពីពេលនោះនៅតំបន់១៣ តាម៉ុក បានអញ្ជើញកងទ័ពទាំងអស់ទៅប្រជុំនៅ គេហៅថា បច្ចុប្បន្នហៅឃុំអូរសារ៉ាយ ជួបជុំគ្នាហ្នឹងមួយពេល ហើយគាត់ឡើងប្រកាសយ៉ាងនុ៎ង។ ដល់តែក្រោយមកអ្វីដែលខ្ញុំធ្វើការបញ្ជាក់ជម្រាបជូននេះ គឺពេលនោះ បើនិយាយអំពីវ៉ាដ្យូ វិទ្យុហ្នឹង មិនមានជាទូទៅទេ តែសម្រាប់ខ្ញុំមានមួយ ហើយក៏បានស្ដាប់សេចក្ដីថ្លែងការណ៍របស់ អ៊ំខៀវ សំផន មុនរំដោះទូទាំងប្រទេស គាត់បានលើកឡើង ដូចខ្ញុំបានជម្រាបហើយ អ្វីទាំងអស់គឺគាត់លើកលែងទោស ដែលវិនិច្ឆ័យទោស សម្រាប់តែវីរជនប៉ុន្មានរូបនោះទេ មាន លន់ នល់, សិរិមតៈ, អ៊ិន តាំ, សូស្ដែន ហ្វែណង់ដែស, ចេង ហេង។ ខ្ញុំបាទមានបាត់ការចងចាំខ្លះ ប៉ុន្តែចាំថាប្រាំពីររូបបាទ។ សូមអស់យោបល់។

[០៩:៣៧:៤៤]

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំដឹងថាលោកមិនអាចចាំកាលបរិច្ឆេទឲ្យបានច្បាស់លាស់នៃសុន្ទរកថានោះទេ តើវាអាចទេដែលថាសុន្ទរកថាហ្នឹង គឺត្រូវសុន្ទរកថានៅថ្ងៃទី២៦ ខែមេសា ១៩៧៥ គឺឯកសារ E3/11 គឺថា ពីរៗខែក្រោយពេលរំដោះ?

**ឆ៖** បាទ សូមៗបញ្ជាក់សំណួរម្តងទៀត បាទ ខ្ញុំអត់បានយល់ពីខ្លឹមសារ។

**ស៖** មិនអីទេលោកសាក្សីខ្ញុំសួរឡើងវិញ។ សុន្ទរកថារបស់ ខៀវ សំផន ដែលលោកលើកយកមកនិយាយនេះ តើលោកចាំថាតើសុន្ទរកថាហ្នឹងថ្លែងនៅម្ដុំថ្ងៃ ២៦ ខែកុម្ភៈ ១៩៧៥ ឬ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែចងចាំថាមុនរំដោះទូទាំងប្រទេស ការថ្លែងការណ៍របស់គាត់ហ្នឹងក្នុងឋានៈគាត់ជាមេបញ្ជាការកងទ័ពរំដោះ បាទ ប្រើពាក្យកងទ័ពរំដោះពេលហ្នឹង បាទ។ ហើយខ្ញុំមិនបានចងចាំតទៅទៀតទេបាទ សុំអស់យោបល់ប៉ុណ្ណឹងហើយបាទ សូមចប់។

**ស៖** សូមអរគុណលោកសាក្សី។ កាលពីម្សិលមិញ ក៏ដូចពីលោកមុន លោកបានឆ្លើយអំពីរណសិរ្សនៅភូមិជាងទង។ ក្នុងសមត្ថភាពលោក ហើយក្នុងពេលដែលលោកស្ដាប់ប្រកបដោយការយកចិត្តទុកដាក់នៃសុន្ទរកថាតំណាងឲ្យកងទ័ពរណសិរ្សរំដោះជាតិហ្នឹងឬ?

**ឆ៖** បាទ សូមធ្វើការជម្រាបជូន។ ខ្ញុំស្ដាប់ហ្នឹងក្នុងឋានៈជាអ្នកទទួលខុសត្រូវក្នុងឃុំជាងទង។ ហើយក្នុងរូបភាពកងទ័ពបាទ។ សូមមានយោបល់យ៉ាងនេះ សូមអស់យោបល់ បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអានសម្រង់មួយនៃចម្លើយមួយដែលតំណាងឲ្យរណសិរ្សរួបរួមជាតិកម្ពុជា ក៏ដូចជាតំណាងឲ្យរាជរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិ គឺថាឯកសារនេះវែងដែរ ហើយខ្ញុំក៏បានផ្ដល់អត្ថបទជាភាសាអង់គ្លេសឲ្យអ្នកបកប្រែដែលមាននៅពីខាងមុខអ្នកបកប្រែស្រាប់ ប៉ុន្តែអត់មានការបកប្រែទៅជាភាសាបារាំងទេឯកសារនេះ។ ឯកសារនេះ គឺ ឯកសារ E3/118 នេះគឺជាសេចក្ដីថ្លែងការណ៍តំណាងឲ្យរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ការដែលខ្ញុំសុំអានសម្រង់គឺឯកសារ E3/1539។ ដូច្នេះ ខ្ញុំសូមអានសម្រង់ចេញពីឯកសារនេះ ហើយសង្ឃឹមថានឹងមានការបកប្រែបានល្អ។

**ស៖** លោកសាក្សីសេចក្ដីថ្លែងការណ៍ចុះថ្ងៃទី២៦ មីនា ១៩៧៥។ ខ្ញុំសូមអានដូចតទៅ នៅលើវេទិកាដ៏បង្ហូរឈាម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:៤២:៤៨]

**លោក ខេល លីសាក់៖**

សូមអរគុណ។ លោកមេធាវី សូមផ្តល់លេខ ERNសម្រាប់ទំព័រមួយនេះផង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមទោស គឺ 00166896។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមចាប់ផ្តើមម្តងទៀត។ នៅដំណាក់កាលបង្ហូរឈាមរបស់កម្ពុជា ចក្រពត្តិអាមេរិក បានបង្ហាញជូននូវការគាំទ្ររបស់ខ្លួនជាមួយនឹងអាយ៉ងរបស់ខ្លួន ឡុង បូរ៉េត ហើយខ្មែរសាធារណរដ្ឋក៏បាន អំពាវនាវឱ្យប្រជាជនកម្ពុជា ក៏ដូចភាគីម្តងទៀត សុំឱ្យមានការផ្អាកការបាញ់គ្នា ហើយនិងធ្វើការបង្រួបបង្រួមជាតិ។ ពួកក្បត់ជាតិដ៏មហាអាក្រក់នេះ ឡុង បូរ៉េត គឺបានបញ្ជាក់អះអាងថា អ្នកស្នេហាជាតិរបស់ខ្មែរក្រហមហ្នឹង គឺថាមានហេតុផលដែលត្រូវឱ្យយល់អំពីអ្នកគាំទ្រលន់នល់ដែលគាត់និយាយថា គឺជាអ្នកស្នេហាជាតិទាំងអស់ហ្នឹង គឺត្រូវតែសម្តែងនូវភាពស្មោះត្រង់ចំពោះប្រជាជន ចំពោះប្រទេស ក៏ដូចជាឯករាជ្យជាតិ និងក៏សម្រាប់សុច្ចភាព ភាពទៀងត្រង់ទាំងអស់គ្នាផងដែរ។ ក្នុងនាមឱ្យរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងរំដោះជាតិកម្ពុជា ខ្ញុំសូមធ្វើការ យកចិត្តទុក -- បង្ហាញជូនដោយយកចិត្តទុកដាក់ជូនពិភពលោកទាំងមូលឱ្យបានជ្រាប។ ទី១ មន្ត្រីជាន់ខ្ពស់ និងកម្មាភិបាលនៃសាធារណរដ្ឋខ្មែរដ៏គួរឱ្យអៀនខ្មាសនេះ គឺវាខុសគ្នាអំពីអ្នកស្នេហាជាតិខ្មែរក្រហម គឺវាខុសគ្នាដូច សហើយនិងខ្មៅតែម្តង។ ហើយក្នុងរយៈពេល៥ឆ្នាំនេះ គឺថាពួកសាធារណរដ្ឋ គឺមានបង្ហាញនូវអំពើក្បត់ជាតិ វិទ្ធង្សនា ក៏ដូចជាអំពើពុករលួយ។ ប្រជាជនកម្ពុជា គឺបានបំបាត់ កម្ចាត់ពួកគេចេញពីសង្គម ដើម្បីភាពយុត្តិធម៌។ ទី២ ឡុង បូរី ខ្លួនគាត់ផ្ទាល់ត្រូវបានថ្កោលទោសប្រហារជីវិតដោយប្រជាជនកម្ពុជានៅចុងបញ្ចប់នៃសមាជជាតិ នៅថ្ងៃទី២៥ កុម្ភៈ១៩៧៥។ ចក្រពត្តិអាមេរិកមានកំហុសយ៉ាងធ្ងន់ធ្ងរដែលខ្លួនយល់ឃើញថា ឡុង បូរី នេះ គឺអាចបត់បែននៅធ្នុះរបស់ខ្លួនក្នុងការតស៊ូនៃអ្នកស្នេហាជាតិរបស់ក្រុមខ្មែរក្រហម ហើយនិងឱ្យពួកគេមកជួប។ ហើយ ឡុង សង្ឃឹមថា ឡុង បូរ៉េត អាចនឹងធ្វើកិច្ចការផ្សេងៗប្រសើរជាង លន់ នល់។ ដោយការថ្កោលទោសប្រហារជីវិតដោយសមាជ

ជាតិ ពួកមហាជនក្បត់រួមមាន៖ កាំង ទន់ហាក់, ប៉ាន់ សុទិ, សាក់ ស៊ុតសាខន, សូខាំ ខូយ, លន់ ណុន, គី តាំងលឹម, ហ៊ូ ហុង, គង់ អន, លិ ខ្វាន់, លន់ នល់, អ៊ីយ៉ាំង, ជាវ សៀងលាង, ឡុង រដ្ឋា, វ៉ាន់ ស, ង្ហួន ជួន, សាង សារ៉ាត់, អ៊ុង ស៊ីក្លួន គឺជាឧក្រិដ្ឋជនសង្គ្រាម ដែលតាមរយៈការរំដោះទីក្រុងភ្នំពេញហ្នឹង គឺថាត្រូវតែប្រឈមមុខទៅនឹងយុត្តិធម៌ នូវឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅក្នុង -- ដែលពួកគេបានប្រព្រឹត្ត ក្នុងរយៈពេលប្រាំឆ្នាំមកលើប្រជាជន ប្រទេសជាតិ និងប្រទេសកម្ពុជាតែម្តង។

[០៩:៤៧:៤៥]

គឺថាពួកក្បត់ជាតិទាំងអស់នេះ គឺជាឧក្រិដ្ឋជនសង្គ្រាមដ៏កំសាក ដែលត្រូវប្រឈមមុខជាមួយនឹង រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលនៃកម្ពុជា ហើយចក្រពត្តិអាមេរិក គឺថាប្រជាជនកម្ពុជានេះ គឺ ទាំងប្រុសទាំងស្រីបានបូជាជីវិតរបស់ខ្លួនដើម្បីប្រទេសជាតិ។ ខ្ញុំសូមអញ្ជើញឲ្យ អំពាវនាវឲ្យសហរដ្ឋ អាមេរិកបញ្ឈប់ចំពោះអំពើទាំងអស់នេះដែលគួរឲ្យអៀនខ្មាស។ ហើយបន្ទាប់មកទៀត រណសិរ្សរួបរួម ជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយសម្តេច នរោត្តម សីហនុ គឺថាបានប្រកាសថា នឹង វាយប្រយុទ្ធជាមួយនឹងចក្រពត្តិអាមេរិករហូតដល់ដង្ហើមចុងក្រោយ ហើយនិងក៏ដូចជាជាមួយនឹងពួក បរិវាររបស់គេផងដែរ។" បញ្ចប់ការដកស្រង់។ នេះគឺជាសម្រង់មួយវែងណាស់លោកសាក្សី តើលោក នៅនឹកឃើញថា លោកបានស្តាប់សេចក្តីថ្លែងការណ៍តាមរយៈវិទ្យុក្នុងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះដែរទេ?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន អ្វីលោកលើកឡើងអម្បាញ់មិញនេះ គឺហួសសមត្ថភាព ខ្ញុំក្នុងការយល់ដឹង។ ដូច្នេះខ្ញុំជម្រាបថា ខ្ញុំអត់បានដឹងទេបាទ ព្រោះការលើកឡើងដែលខ្ញុំចង់ចាំនោះ គឺ ក្នុងរយៈកាលខ្លី ពេលខ្លី ហើយវិទ្យុនោះក៏ស្តាប់បានខ្លះ មិនបានឋិតថេរជារៀងរាល់ថ្ងៃទេ។ ប៉ុន្តែខ្លឹមសារ ដែលខ្ញុំបានចងចាំប៉ុន្មានប្រយោគនេះ គឺខ្ញុំឮសួរអ៊ីចឹង ខ្ញុំសប្បាយ។ បានន័យថា ការវិនិច្ឆ័យនេះហ្នឹង ចំពោះប្រមាណរូប មិនជាទូទៅពេញផ្ទៃប្រទេស។ បាទ អ៊ីចឹងសូមអស់យោបល់។

[០៩:៥០:១៤]

**ស៖** អ្នកដែលថ្លែងសុន្ទរកថានេះ ឬក៏អ្នកដែលសរសេរសុន្ទរកថានេះ គឺអតីតសម្តេចព្រះនរោត្តម សីហនុ ដែលៗថ្លែងទៅកាន់ជនរួមជាតិរបស់ព្រះអង្គ។ ហើយដែលក្នុងនោះមាននិយាយអំពីឧក្រិដ្ឋជន សង្គ្រាម លន់ នល់ ហើយនិងទាហានដែលជាឧក្រិដ្ឋជនសង្គ្រាម។ តើលោកធ្លាប់ស្តាប់ឮសុន្ទរកថាបែប នេះដែរទេមុនៗ?

**ឆ៖** បាទ សូមធ្វើការជម្រាប គឺអត់បានស្តាប់ទេ អត់ដែលបានស្តាប់ទេបាទ សូមអស់យោបល់។

**ស៖** ចុះលោកធ្លាប់ស្តាប់សេចក្តីថ្លែងការណ៍របស់អតីតសម្តេចព្រះ នរោត្តម សីហនុ ដែលថ្លែងសំដៅទៅលើមន្ត្រីនៃរបប លន់ នល់ នោះដែរទេ?

**ឆ៖** សូមធ្វើការជម្រាប ខ្ញុំបានស្តាប់សេចក្តីថ្លែងការណ៍របស់វរៈព្រះមហាក្សត្រ នរោត្តម សីហនុ នៅពេលក្រោយរដ្ឋប្រហារ។ លោក លន់ នល់ ធ្វើរដ្ឋប្រហារ គាត់អំពាវនាវឲ្យប្រជាជនយើងចូលព្រៃម៉ាគីម៉ាគា សាមគ្គីគ្នាដើម្បីរំដោះប្រទេសជាតិ ផ្តួលរំលំ លន់ នល់, សិរិមតៈ, ស៊ឺង ង៉ុកថាញ់, អ៊ិន តាំ។ បាទ តែប៉ុណ្ណឹងទេ។ បាទ សូមអស់យោបល់។

**ស៖** ខ្ញុំដឹងថា សំណួរទាំងនេះជាសំណួរដែលពិបាកៗនឹងឆ្លើយ ប៉ុន្តែខ្ញុំព្យាយាមសុំអានឈ្មោះនៃពួកមហាក្បត់២០នាក់ផ្សេងទៀត។ តើលោកនៅចាំនេះ ឈ្មោះដែលខ្ញុំទើបតែអាន ២១នាក់នៅក្នុងសេចក្តីថ្លែងការណ៍របស់អតីតព្រះមហាក្សត្រនេះដែរទេ? ចាំឈ្មោះអ្នកទាំង២១នាក់នោះខ្លះទេ?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ ជម្រាបថា ខ្ញុំអត់ដែលបានឮឈ្មោះទាំងអស់នោះទេ។ បាទ សូមអស់យោបល់។

[០៩:៥២:៥៨]

**ស៖** សូមអរគុណលោកសាក្សី។ មិនជាអ្វីទេ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត គឺប្រធានបទដែលនិយាយអំពីបញ្ហារឿងរ៉ាវដែលអាចកើតឡើងនៅក្រុងតាកែវ ប្រហែលជានៅក្នុងឆ្នាំ ១៩៧៣ ឬក៏មុននេះ។ តើលោកធ្លាប់ឮប្រជាជនវៀតណាមនេះត្រូវបានគេប្រព្រឹត្តយ៉ាងអាក្រក់ ដោយទាហាន លន់ នល់ នៅក្នុងទីរួមខេត្តតាកែវនោះដែរទេ?

**ឆ៖** សូមធ្វើការបញ្ជាក់ជារួម ខ្ញុំមិនបានដឹងទេ ក្រោយពីរដ្ឋប្រហារ ហើយខ្ញុំអត់ទាន់មានតួនាទីអ្វី ខ្ញុំជាប្រជាជនសាមញ្ញនៅក្នុងភូមិត្រពាំងទឹក ឃុំជាងទង។ បាទ សូមអស់យោបល់។

**ស៖** មានសាក្សីមួយរូប ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺសាក្សីរូបនេះគាត់បាននិយាយថា “មានយួនជាច្រើនដែលត្រូវបានគេសម្លាប់នៅមុនឆ្នាំ១៩៧៥ នៅសាលាដៃប្រាំ នៅក្នុងទីរួមខេត្តតាកែវតែម្តង”។ តើលោកធ្លាប់ឮការសម្លាប់ទ្រង់ទ្រាយធំដោយមន្ត្រីលន់ នល់ គឺសម្លាប់យួននៅក្នុងសាលាដៃប្រាំនោះដែរទេ?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ ជម្រាបជូន ខ្ញុំមិនបានដឹង មិនបានយល់ ក្នុងកិច្ចការទាំងអស់នោះទេ។ បាទ សូមអស់យោបល់។

[០៩:៥៥:០៣]

**ស៖** មិនជាបញ្ហាអ្វីទេលោកសាក្សី។ តើលោកនៅនឹកឃើញ ឬក៏លោកដឹងថាមានការប្រយុទ្ធ បន្តប្រយុទ្ធគ្នារវាងកងកម្លាំងភូមិភាគនិរតី ហើយនិងវៀតកុង គឺនៅប្រហែលជានៅក្នុងឆ្នាំ១៩៧៣ ធ្លាប់ឮៗ អំពីការប៉ះទង្គិចគ្នារវាងកម្លាំងទាំងពីរនេះទេ?

**ឆ៖** ខ្ញុំសូមធ្វើការបញ្ជាក់ជម្រាបជូន អ្វីទាំងអស់ដូចកងកម្លាំងប្រដាប់អាវុធប៉ះទង្គិចគ្នានោះ ខ្ញុំមិនបានដឹងទេ តែៗដឹងតាមរូបភាពខ្លឹមសារនយោបាយក្នុងឆ្នាំ៧៣ តាម៉ុក បានឲ្យកម្មាភិបាលឃុំ អប់រំមេភូមិមិនឲ្យលក់អង្ករឲ្យវៀតណាម កងទ័ពវៀតណាមដែលបានចូលមកទិញ ព្រោះគាត់ថា "ឥឡូវនេះវៀតណាមគេសន្តិភាពហើយ ដូច្នេះយើងទុកសេដ្ឋកិច្ចនេះបម្រើសមរភូមិ ឲ្យគាត់កងទ័ពយើង។" បាទ សូមអស់យោបល់ បាទ។

**ស៖** ខ្ញុំយល់ហើយលោក ប៉ុន្តែប្រហែលជាលោកកំពុងនិយាយសំដៅទៅក្រោយឆ្នាំ១៩៧៥ និយាយអំពីការបង្រួបបង្រួមគ្នានៅថ្ងៃទី៣០ ខែមេសា ឬក៏ក្រោយនោះមក ប្រហែលជាលោកច្រឡំ។ ខ្ញុំនិយាយអំពីការប៉ះទង្គិចគ្នារវាងកងទ័ពភូមិភាគនិរតី និងវៀតកុង នៅក្នុងឆ្នាំ១៩៧៣ ហើយក្រោយមកកងកម្លាំងវៀតកុងទាំងអស់នោះ គឺត្រូវបានគេបង្ខំឲ្យចាកចេញពីបូរណភាពដែនដីកម្ពុជា លោកនៅនឹកឃើញអំពីការប៉ះទង្គិចគ្នានេះទេ?

**ឆ៖** បាទ ខ្ញុំ ការជម្រាបរបស់ខ្ញុំអម្បាញ់មិញ គឺខ្ញុំបានយល់ បាទ ផ្នែកប៉ះទង្គិចគ្នាក្នុងរយៈកាលឆ្នាំ៧៣ នោះគឺអត់ ខ្ញុំអត់បានដឹងទេ ប៉ុន្តែក្នុងរយៈកាលឆ្នាំ៧៣ នយោបាយរណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង គឺតាម៉ុក គាត់បានបញ្ជាឲ្យគ្រប់ខេត្តមកស្រុក ស្រុកមកឃុំ គឺថាហាមមិនឲ្យប្រជាជនលក់អង្ករឲ្យកងទ័ពវៀតណាមបាទ។ អ៊ីចឹងខ្ញុំក៏អនុវត្តទៅតាមហ្នឹង បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន ខ្លឹមសារនេះតែប៉ុណ្ណេះ បាទសូមអស់យោបល់។

[០៩:៥៨:១៥]

**ស៖** លោកសាក្សី តើលោកធ្លាប់ដែលឮអង្គការមួយ ឬក៏ថាអាចហៅថាខ្មែរស អង្គការខ្មែរស ឬក៏ខ្មែររំដោះ គឺៗខ្មែរស ឬក៏ខ្មែររំដោះ លោកធ្លាប់ឮទេ?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន ពាក្យនេះ ខ្ញុំមិនបានឮទេ បាទ សូមអស់យោបល់។

**ស៖** បាទ មិនបញ្ហាអ្វីទេ ខ្ញុំមានសំណួរខ្លីៗសូមឲ្យលោកជួយបញ្ជាក់បន្តិច។ ខ្ញុំសូមចូលទៅចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺE3/9118 នៅត្រង់ទំព័រ១១ ERN ជាអង់គ្លេស

01098756, ខ្មែរ 00957786 គេបានសួរលោកអំពីទស្សនាវដ្ដីទង់បដិវត្តន៍ ហើយលោកបានឆ្លើយ ខ្ញុំសូមដកស្រង់ដូចតទៅ សូមដកស្រង់៖ “ទស្សនាវដ្ដីទង់បដិវត្តន៍ គឺណែនាំយើងកុំឲ្យ គឺថាមានភាពទៅជ្រុលនិយម ហើយក៏ៗកុំឲ្យស្ដាំនិយមពេក កុំឲ្យជ្រុលនិយម ឆ្វេងនិយមពេក”។ តើលោកអាចពន្យល់ជូនតុលាការបានទេ ក្នុងពេលនោះថាកុំឲ្យឆ្វេងនិយមពេក កុំឲ្យស្ដាំនិយមពេក។ តើពាក្យនេះចង់មានន័យថាម៉េចដែរ?

**ឆ៖** សូមធ្វើការជម្រាបជូន។ អ្វី ពាក្យនៅក្នុងទង់បដិវត្តហ្នឹង គឺឯកសារហ្នឹងបានន័យថា អនុវត្តកុំឆ្វេងពេក កុំស្ដាំពេក បានន័យថា កុំឆ្វេងពេក ឧទាហរណ៍បើមតិណែនាំខាងលើមក កម្លាំងកសិករ ឬកងចល័តអីចុះធ្វើការកំណត់ថាម៉ោងមួយ ដូច្នេះយើងមុននឹងឲ្យគេចុះម៉ោងមួយ ត្រូវវិភាគផង។ វិភាគថា បើយើងម៉ោងមួយ ប៉ុន្តែធម្មជាតិ ពេលនោះក្ដៅខ្លាំង ហើយដល់ម៉ោងមួយហើយ កំណត់ត្រូវតែចុះដូច្នេះយើងមិនត្រូវឲ្យចុះទេ បើចុះនោះគឺយើងឆ្វេងហើយ ដោយយើងមិនវិភាគផ្អែកទៅលើធម្មជាតិ ក្ដៅកាលណាបើឲ្យកម្លាំងទាំងអស់នោះចុះទៅអនុវត្តជីកប្រឡាយ លើកទំនប់នោះ ប៉ះពាល់ដល់សុខភាព។ នេះការយល់របស់ខ្ញុំគឺមានន័យប៉ុណ្ណឹង ហើយការអនុវត្តក៏ទៅតាមហ្នឹង។ ឯឆ្វេងពេក ឯស្ដាំពេកនោះ ក៏យើងសម្រួលកុំឲ្យគាត់ធូររលុង រយីករយាក ខ្វះខាតពីពេលវេលា។ ដូច្នេះ បើយើងកំណត់ម៉ោង ប៉ុន្មានប្រាំពីរ ឬក៏ម៉ោងប្រាំពីរកន្លះទៅដល់ការដ្ឋាន សូមឲ្យគាត់ផ្ចិតផ្ចង់ ផ្ទៀងផ្ទាត់ពេលវេលា។ បាទ ហ្នឹងការយល់របស់ខ្ញុំ និងអនុវត្តពេលហ្នឹងគឺអ៊ីចឹងបាទ។ សូមអស់យោបល់ ខ្លឹមសារ ឆ្វេងនិយម និងស្ដាំ។ បាទ សូមអស់យោបល់ហើយ។

[១០:០២:២១]

**ស៖** នៅពេលមួយនោះ ដោយសារលោកជាកម្មាភិបាលខ្មែរក្រហមផង ថាតើមានឧទាហរណ៍ណាផ្សេងទៀត ដែលលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេ ដែលលោកថា ដែលមានពាក្យថា កុំឆ្វេងពេក កុំស្ដាំពេកនោះ?

**ឆ៖** បាទ សូមលើកបញ្ជាក់ជម្រាបជូនក្នុងន័យអនុវត្ត ហើយពេលនោះ ក៏ប្រុងប្រយ័ត្នផងដែរ ដើម្បីកុំឲ្យឆ្វេងនិយម និងស្ដាំនិយម។ ខ្ញុំសូមអធ្យាស្រ័យឆ្លើយនៅពេលនេះ ហើយការចម្លើយរបស់ខ្ញុំនេះក្រែងវែង ឬខ្លី ក៏សូមអធ្យាស្រ័យ។ ឧទាហរណ៍ពេលនោះ គឺយើងធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម គឺពាក្យថា “ថ្មី”។ អ៊ីចឹងកម្មាភិបាលកាលហ្នឹងនៅជំនាន់ហ្នឹងគឺមាន អ៊ុំ គា គណៈតំបន់២៥ គាត់ប្រាប់ថាយើងធ្វើស្រែ ឥឡូវនេះពង្រាបដី ស្រែតូចរលាយឲ្យបានទៅ១០០ម៉ែត្រ បួនជ្រុង មួយហិកតា។

អ៊ីចឹងដើម្បីកុំឱ្យឆ្វេង យើងត្រូវទទួលស្គាល់ថា យើងពង្រាបដីនេះមួយ គឺយើងបំបាត់នូវកម្មសិទ្ធ ឯកជនរបស់បុគ្គលមួយៗ។ ដូច្នេះ អ្វីដែលខ្ញុំឈរលើទីតាំងវិភាគ ឧទាហរណ៍ថា កុំឱ្យឆ្វេងពេកនោះ ឧទាហរណ៍ អ្នកទៅភ្ជួរក្នុងចំណោមស្រែមួយហិកតា ភ្ជួរនង្គ័លប្រាំ ឬប្រាំមួយ។ ដូច្នេះ ពេលដែលភ្ជួរនោះ បើបាក់ផាលទៅមួយនោះ អ្នកខ្លះប្រើ -- ដូចថាវាមានន័យមួយថាគ្នាខ្មាំង ប្រឆាំងនឹងសហករណ៍ ប្រឆាំងនឹងបដិវត្តន៍សង្គមនិយម។ បាទ ដូច្នេះ ពេលនោះ ខ្ញុំបានធ្វើការអប់រំក្នុងឋានៈជាអ្នកអប់រំ គឺសម្រេចថា សូមអស់លោកទាំងអស់ជាប្រធានកង ប្រធានក្រុម កុំអាលដាក់កំហុសបំភ័យឱ្យគ្នាមានការតក់ស្លុត ពីព្រោះឧទាហរណ៍បើយើងមានស្រែរបស់យើងផ្ទាល់ ហើយយើងមានគល់ មានឫស ពេលខ្លះ យើងភ្លេចភ្លាំងយើងភ្ជួរទៅមិនបានជាគិត យើងអាចបាក់ ជន្លួញ ឬផែប ឬបាក់ ត្រង់នេះ ត្រង់នោះ។ ដូចនេះ ឥឡូវនេះស្រែទាំងអស់នោះរំលាយទៅជាតែមួយ អ៊ីចឹងការពង្រាបដី ការឫស ការកាប់ឆ្ការ វាអាចមានគល់ មានឫស ហើយចំពោះអ្នកមកភ្ជួរនោះក៏មិនមែនជាម្ចាស់ស្រែ។ អ៊ីចឹងការបាក់ ការទង្គិច ខូចខាតរបស់ទាំងអស់នេះ នោះមិនមែនជាខ្មាំងទេ ហើយក៏មិនមែនជាអ្នកប្រឆាំងបដិវត្តន៍ដែរ។ បាទ នេះការលើកឡើងដែលថាកុំឆ្វេង គឺត្រង់ហ្នឹង។ ឯត្រង់ស្តាំ ក៏យើងកំណត់ថា យើងក៏ត្រូវថ្លឹងថ្លែងផងដែរ ក៏ការលើកឡើងស្តាំនោះគ្រាន់តែលើកឡើងថា ឱ្យគាត់គោរពអង្គការវិន័យ មានក្រិតក្រម អ្វីៗទាំងអស់កុំឱ្យគាត់ធូររលុងលេងសើចហួសហេតុ ចំអេះចំអាស ឬពាក្យអ្វីដែលរបបដែលយើងត្រូវជម្រុះចោល។ បាទ សូមអស់យោបល់។ ខ្ញុំការយល់ ឆ្វេង-ស្តាំហ្នឹង គឺយល់បានតែប៉ុណ្ណឹងដែរ។ បាទ សូមអស់យោបល់។

[១០:០៦:២០]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំជិតនឹងបញ្ចប់សំណួររបស់ខ្ញុំហើយ។ ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺត្រង់ទំព័រ១៣ ERN 01098758 ជាភាសាអង់គ្លេស, ជាភាសាខ្មែរ 00957789។ លោកសាក្សីនៅក្នុងកិច្ចសម្ភាសន៍មួយនេះ លោកនិយាយអំពីកិច្ចប្រជុំមួយដែលមានវត្តមានរបស់ តាម៉ុក នៅពេលនោះ។ ហើយសំណួរដែលគេសួរលោក គឺសួរដូចតទៅ៖ “តើ តាម៉ុក មាននិយាយអ្វីទេនៅក្នុងអង្គប្រជុំនោះ?” លោកឆ្លើយថា សូមដកស្រង់៖ “ក្នុងអង្គប្រជុំនោះ គាត់មកនិយាយប្រហែលជា៣០នាទី គាត់ប្រាប់យើងឱ្យប្រុងប្រយ័ត្ន គាត់ក៏និយាយទៅកាន់ តាសោម និង តាមុត។ លោកគ្រូ សោម និងលោកគ្រូ មុត ប្រជាជននិយាយថាអ្នកឯងទាំងពីរនេះកាចសាហាវណាស់ ដូច្នេះត្រូវតែត្រឡប់ទៅវិញ ទៅសុំទោសប្រជាជន។” លោកសាក្សី លោកធ្លាប់ឮទេ ដែលនៅពេលនោះគឺថា តាសោម និង តាមុត នេះត្រូវបាន តាម៉ុក ស្តីបន្ទោសឱ្យថា “ជាមនុស្សកាចសាហាវ”។ លោកចាំទេ?

**ឆ៖** បាទ អ្វីដែលសំណួរនេះ ខ្ញុំរីករាយនឹងឆ្លើយ ព្រោះអីពេលនោះនៅពេលនោះហើយ ដែលសន្និបាតនៅក្នុងសាលាក្បែរជើងភ្នំដំរីរមៀលប្រចាំឆ្នាំ ហើយគាត់អង្គុយធ្វើបទឧទ្ទេសនាម ហើយដែលខ្ញុំចងចាំនោះ ពេលនោះគាត់និយាយអំពីលក្ខណៈឲ្យកម្មាភិបាលបង្កបង្កើតសេដ្ឋកិច្ច ក្តាប់កម្លាំងប្រជាជន។ ហើយគាត់និយាយថា ពេលនោះៗដែលខ្ញុំចងចាំ គាត់និយាយថា៖ “ថ្នាក់ភូមិ ឃុំ ស្រុក ខេត្តគ្មានសិទ្ធិសម្លាប់មនុស្សទេណា ដូច្នេះការវិនិច្ឆ័យជីវិតមនុស្សមានតែគណៈភូមិភាគ និងមជ្ឈិម” ហើយគាត់ងាកពេលហ្នឹងគាត់អង្គុយកណ្តាល ហើយ តាសោម ហើយ តាមុត អង្គុយខាង។ គាត់ថា “អ៊ីចឹង ដូចជាសូមធ្វើការប្រាប់ផង គ្រូសោម គ្រូមុតណា ប្រជាជនឮថាប្រជាជនខ្លាច ខ្ញុំដើរមកគេប្រាប់។ ថាលោក គេខ្លាចលោក អ៊ីចឹងធ្វើម៉េចលោកចុះទៅឲ្យប្រជាជនស្រឡាញ់ ធ្វើម៉េចកុំឲ្យគេខ្លាច ព្រោះគេខ្លាចគេស្អប់ គេខ្លាចតែចំពោះមុខទេ ប៉ុន្តែដល់ហើយទៅ ក្រោយខ្នងគេស្អប់។” អ៊ីចឹងសូម ការលើកឡើងនោះគឺពិតប្រាកដមែន គាត់និយាយអ៊ីចឹងមែន។ បាទ សូមអស់យោបល់ហើយបាទ។

[១០:០៩:៣៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំនៅសល់ប្រធានបទមួយទៀតខ្លីទេ ខ្ញុំអាចសួរក្រោយពេលសម្រាកសិនក៏បាន ថាតើឈ្មសមនឹងឈប់សម្រាកឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដល់ម៉ោងសម្រាកហើយ។

បាទ ឥឡូវនេះ ដល់ពេលៗត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវ-នាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោកនួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីសាជាថ្មីលោកសាក្សី។ ប្រធានបទចុងក្រោយរបស់ខ្ញុំគឺដូចតទៅនេះ ហើយខ្ញុំសូមយោងទៅចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏សូមឱ្យលោកបញ្ជាក់នូវអ្វីដែលលោកបានឆ្លើយនោះ គឺត្រង់ទំព័រ២១, ERN 01098766, ខ្មែរ 00957800។ នៅក្នុងចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយអំពីមនុស្សម្នាក់ឈ្មោះថា ចាន់ ចក្រី។ តើ ចាន់ ចក្រី នេះជាអ្នកណា?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមធ្វើការជម្រាបជូន ចាន់ ចក្រី នេះ ខ្ញុំមិនបានស្គាល់ទេបាទ។ សូមអស់យោបល់ហើយបាទ។

[១០:៣៧:៣៦]

**ស៖** ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកបន្តិចនៅត្រង់ទំព័រនេះ ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាលោកបានឆ្លើយថា៖ "ប៉ុន្តែក្រោយពីនៅទីនោះពីរបីខែ គឺថាខ្ញុំមានការភ័យខ្លាចណាស់ដែលនិយាយអំពីការចាប់មេបញ្ជាការកងទ័ពម្នាក់ឈ្មោះ ចក្រី"។ ហើយសំណួរក៏សួរទៀតថា៖ "តើគាត់ហ្នឹងជា ចាន់ ចក្រី ឬ?" ហើយលោកឆ្លើយថា៖ "បាទ មិនមែនជា ចន្ទ រង្សីទេ គឺ ចាន់ ចក្រី ដែលធ្លាប់ធ្វើជាមេបញ្ជាការកងទ័ពខ្មែរក្រហម គឺថាមានទំនាស់ផ្ទៃក្នុងរវាងភូមិភាគនិរតីជាមួយនឹងភូមិភាគបូព៌ា" ហើយក៏មានការសួរជាបន្តទៅមុខទៀតផងដែរ។ ដូច្នេះខ្ញុំចង់សួរទៅលោកថា តើលោកនៅចាំបានទេថា ចាន់ ចក្រី គឺជាមេបញ្ជាការកងទ័ពមកពីភូមិភាគបូព៌ានោះឬ?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន អ្វីដែលខ្ញុំបាទមានឈ្មោះថាមិនស្គាល់ ព្រោះអត់ស្គាល់

មែន ហើយក៏មិនដែលជួបមុខ ប៉ុន្តែបើខ្ញុំការចងចាំក្រែង យាយបូ នៅតំបន់ នៅគណៈស្រុកកៀនស្វាយ គាត់បានលើកឡើង គាត់កាលហ្នឹងគឺថាមានឈ្មោះ ចក្រី ថាកងទ័ពភូមិភាគបាទ មានការទំនាស់ជាមួយនឹងបក្ស គាត់និយាយមួយពេលហ្នឹងគ្រាន់តែនិយាយជាឯកជន អត់បានប្រជុំជាទូទៅទេ។ អ៊ីចឹងសូមអស់យោបល់ប៉ុណ្ណឹងហើយបាទ ខ្ញុំចាប់អារម្មណ៍បានប៉ុណ្ណឹង។

**ស៖** តើលោកចាំបានទេ ថាកម្មាភិបាលនារីហ្នឹងមាននិយាយលម្អិតអ្វីបន្ថែមទៀតទេ?

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន គាត់អត់មាននិយាយអ្វីលម្អិតទៀតទេ ព្រោះការនិយាយនេះ ពេលហ្នឹងនិយាយ គាត់ធ្វើដំណើរទៅឃុំកំពង់ស្វាយដែលឃុំខ្ញុំរស់នៅហ្នឹង ហើយគាត់និយាយគ្រាន់តែនិយាយប៉ុណ្ណឹងហើយក៏ចប់ទៅ។ អត់មានជាការប្រជុំរួមកម្មាភិបាលទាំងអស់នោះទេ បាទ សូមអស់យោបល់។

[១០:៤០:៣២]

**ស៖** ចុះ ចន្ទ រង្សី ដែលលោកនិយាយនេះ គឺនរោត្តម ចន្ទ រង្សី ដែលមកពីខេត្តកំពង់ស្ពឺនោះឬ?

**ឆ៖** បើនិយាយអំពីលក្ខណៈ នរោត្តម ចន្ទ រង្សី ហ្នឹង ខ្ញុំគ្រាន់តែឮឈ្មោះ តាមរយៈកងទ័ពថា ចន្ទ រង្សី ហ្នឹងគឺនៅសមរភូមិកំពង់ស្ពឺ។ បាទ ហើយថាសមរភូមិហ្នឹងបែកក្រោយគេ។ អ៊ីចឹងសូមអស់យោបល់ប៉ុណ្ណឹងហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន យើងខ្ញុំអត់មានសំណួរអ្វីទៀតទេលោកប្រធានសម្រាប់សាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអ៊ីចឹងល្អហើយអ៊ីចឹង។ បាទ ដល់ពេលនេះការស្តាប់សក្ខីកម្មសាក្សី សៅ វ៉ន បានដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះសូមអរគុណលោក សៅ វ៉ន ដែលបានចំណាយពេលវេលា ដ៏

មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្តីនេះ។ ឥឡូវនេះ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ មានសុខភាពល្អ និងមានសេចក្តីសុខ សេចក្តីចម្រើន។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ជូនលោក សៅ វ៉ន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

[១០:៤២:៥៨]

បាទ មុននឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1008 អង្គជំនុំជម្រះមានបំណងស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគីនានា ពាក់ព័ន្ធនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំដល់អង្គជំនុំជម្រះថ្មីៗនេះ ឲ្យទទួលយកនូវឯកសារ ជាឯកសារភស្តុតាងដែលឯកសារថ្មីចំនួនប្រាំមួយ ពីសំណុំរឿងផ្សេងមកដាក់នៅក្នុងសំណុំរឿង០០២ ហើយនិងជាមូលដ្ឋានក្នុងការពិភាក្សាដេញដោលចំពោះសាក្សីដែលមានរហស្សនាម 2-TCW-1008។ ឯកសារទាំងប្រាំមួយនេះ មាននៅក្នុងសំណើសុំលេខ E319/36 ចុះថ្ងៃទី១១ វិច្ឆិកា ឆ្នាំ២០១៥ ចំនួនប្រាំ ហើយនិងឯកសារថ្មីចំនួនមួយ។ ហើយឯកសារថ្មីហ្នឹង គឺជាលេខ E319/22.3.32 ដែលជាកំណត់ហេតុស្តាប់ចម្លើយសក្ខីកម្មសាក្សី 2-TCW-1008។ ហើយនេះគឺជាសំណើសុំថ្មី ជាបន្ទាន់ដែលអង្គជំនុំជម្រះត្រូវដោះស្រាយសំណើនេះជាមុន មុននឹងសួរដេញដោលចំពោះសាក្សីដែលមានរហស្សនាម 2-TCW-1008។

ជាដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីធ្វើការបង្ហាញនូវសំណើសុំរបស់ខ្លួនចំពោះមុខភាគី និងអង្គជំនុំជម្រះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ យើងខ្ញុំបានផ្ញើសំណើសុំប្រើប្រាស់ឯកសារដែលត្រូវបានដាក់ជាភស្តុតាង ជូនទៅអង្គជំនុំជម្រះនៅក្នុងសំណើមុន ក៏ប៉ុន្តែអង្គជំនុំជម្រះមិនទាន់បានសម្រេចទៅលើឯកសារនោះនៅឡើយទេ។ គឺឯកសារប្រាំក្នុងនោះ ហើយបួន គឺចេញមកពីសាក្សី 2-TCW-1008 ដែលនឹងមកផ្តល់សក្ខីកម្មនាពេលបន្តិចទៀតនេះ ហើយនិងឯក

សារមួយទៀត គឺជាឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺឯកសារ E319/23.3.28។ ខ្ញុំគិតថា សំណើនេះដូចជាមិនមានបញ្ហាអ្វីទេ ព្រោះវាជាកំណត់ហេតុបួនរបស់សាក្សីដែលនឹងមកផ្ដល់សក្ខីកម្ម ហើយវានឹងផ្ដល់ប្រយោជន៍ដល់ភាគីទាំងអស់ ក្នុងការប្រើប្រាស់កំណត់ហេតុទាំងអស់នេះ ដើម្បីសួរសាក្សី ហើយនិងក៏ជាផលប្រយោជន៍របស់អង្គជំនុំជម្រះក្នុងការប្រើប្រាស់ឯកសារទាំងអស់នេះផងដែរ។ ឯកសារទាំងអស់នេះ ជាឯកសារថ្មី ដូច្នេះវាជាភស្តុតាងថ្មី ដែលយើងត្រូវតែស្នើសុំពីអង្គជំនុំជម្រះដើម្បីប្រើប្រាស់ ដោយសារតែអង្គជំនុំជម្រះមិនទាន់បានសម្រេចទៅលើឯកសារនេះនៅឡើយ។ មានឯកសារប្រាំ មួយទៀត -- ទី៥មួយទៀត គឺកំណត់ហេតុរបស់សាក្សី 2-TCW-1008 ហ្នឹង គឺឯកសារ E319/22.3.32។ ឯកសារនេះត្រូវបានស្នើជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ដោយមេធាវីការពារក្ដីលោក នួន ជា នៅក្នុងសំណើមួយផ្សេងទៀត។

ដូច្នេះ ដូចខាងភាគីការពារក្ដី និងភាគីផ្សេងទៀតដែរ យើងស្នើសុំប្រើប្រាស់ឯកសារមួយនេះ ដើម្បីសួរដេញដោលសាក្សី។ ដូច្នេះ ខ្ញុំគិតថាមិនមានបញ្ហាអ្វីជាក់លាក់ ពាក់ព័ន្ធទៅនឹងសំណើដែលផ្អែកទៅលើវិធាន៨៧.៤នេះទេ ហើយឯកសារនេះត្រូវបានដាក់នៅខែវិច្ឆិកា ឆ្នាំ២០១៥កន្លងទៅនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ចុះខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តើមានមតិយោបល់អ្វីដែរទេ លើសំណើសុំរបស់សហព្រះរាជអាជ្ញា សុំទទួលយកឯកសារជាភស្តុតាងដាក់នៅក្នុងសំណុំរឿង ហើយនិងពិភាក្សាដេញដោលសាក្សី 1008 នាពេលខាងមុខនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ពីខាងមេធាវីនាំមុខ យើងខ្ញុំមិនមានការជំទាស់ចំពោះឯកសារទាំងអស់នេះទេ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមសហមេធាវីការពារក្ដីលោក នួន ជា តើមានសារណាតបទៅនឹងសំណើសុំនេះដែរឬទេ? បើមាន សូមអញ្ជើញ បាទ!

[១០:៤៧:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

តាមការចំណាប់អារម្មណ៍ ហើយនិងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលត្រូវចូលខ្លួនមកនេះ គឺថាយើងខ្ញុំនឹង -- យើងខ្ញុំមិនមានអ្វីជំទាស់ទេ ប៉ុន្តែសូមអនុញ្ញាតឲ្យខ្ញុំរំឭកដល់អង្គជំនុំជម្រះផងដែរថា សំណើសុំផ្ទាល់មាត់ដែលរង់ចាំសេចក្តីសម្រេចនៅឡើយ ពាក់ព័ន្ធនឹងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានូវសាក្សីម្នាក់ ក៏ដូចជាក្នុងកំណត់ហេតុមកពីកងពលលេខ១៦៤ គឺឯកសារ E319/23.3.17.1 និង E319/23.3.17 បាទដដែលទេ។ យើងក៏បានស្នើសុំផងដែរ កាលពីសប្តាហ៍មុន ខ្ញុំមានបំណងប្រើប្រាស់ឯកសារនេះដើម្បីសួរសាក្សីដែលត្រូវចូលខ្លួនមកនេះ។ នៅពេលដែលអង្គជំនុំជម្រះកំពុងតែស្តាប់ភាគីដើម្បីសម្រេចទៅលើឯកសារនេះ។ ដូច្នេះយើងខ្ញុំក៏ស្នើសុំផងដែរ គឺឲ្យសម្រេចទៅលើសំណើសុំផ្ទាល់មាត់របស់ខ្ញុំ ចំពោះឯកសារមួយនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើឯកសារនេះ មានផ្ញើតាមអ៊ីម៉ែល ដើម្បីស្នើសុំឲ្យធ្វើការបញ្ជាក់ផងដែរទេ? ដោយសារថា ដូចជាមាន កំពុងតែមានភាពច្របូកច្របល់បន្តិច។

**លោក វ៉ិចទ័រ កូប៉េ៖**

ពេលនេះ ខ្ញុំមិនច្បាស់នៅឡើយទេ លោកស្រីចៅក្រម។ គឺឯកសារនេះ គឺឯកសារមិនៗបានដាក់នៅលើ*អ៊ិនធឺហ្វេស* នៅឡើយទេ ក៏ប៉ុន្តែសហមេធាវីនាំមុខបានជំទាស់ម្តងហើយ ទៅនឹងឯកសារនេះ។ នៅពេលសួរ ព្រុំ សារ៉ាត គឺខ្ញុំអត់អាចប្រើប្រាស់ឯកសារនេះបានទេ។ អ៊ីចឹងឯង បានជាខ្ញុំដាក់សំណើសុំដោយផ្ទាល់មាត់ទៅលើឯកសារពីរ ហើយពេលនេះក៏ស្នើសុំដោយផ្ទាល់មាត់ជាថ្មីម្តងទៀត ទាក់ទងទៅនឹងឯកសារឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:៥០:00]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើតាមខ្ញុំចាំ លោកមេធាវី កូប៉េ អ្វីដែលអង្គជំនុំជម្រះចង់បាននោះគឺចង់បាននូវសំណើដែលមានសំអាងហេតុត្រឹមត្រូវថា តើវាមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលត្រូវបានបំពេញ យោងតាមវិធាន៨៧(៤) ប្រសិនបើលោកមិនដាក់សំណើត្រឹមត្រូវទេ ហើយយើងមិនអាចសម្រេចបានទេ។ អ៊ី0ចឹងយើងមិនអាច

ធ្វើអីបានទេ បើមិនមានសំអាងហេតុត្រឹមត្រូវនោះ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំក៏មានសំណួរដដែលនេះផងដែរពីលោកស្រីចៅក្រម ហ្វេនស៍ នៅពេលស្ដាប់ចម្លើយ ព្រុំ សារ៉ាត ខ្ញុំបានឆ្លើយទៅហើយ ក៏ប៉ុន្តែឯកសារនេះគឺជាឯកសារវាពាក់ព័ន្ធខ្លាំងជាបឋម ហើយក៏ជាចម្លើយដ៏វែងរបស់អតីតកងទ័ពកងពល១៦៤ គាត់និយាយតែពីអ្វីដែលកើតឡើងនៅក្នុងដែនទឹកនៃកម្ពុជាប្រជាធិប-តេយ្យតែប៉ុណ្ណោះ។

[១០:៥១:០៥]

នេះគឺជាចម្លើយដូចគ្នាទៅនឹង TCW-1008 ដែលនឹងត្រូវឆ្លើយ គឺឆ្លើយដូចគ្នាទៅនឹង ព្រុំ សារ៉ាត់ ដែរ។ ដូចដែលខ្ញុំបានជម្រាបជូនហើយ គឺក្នុងឯកសារមានការពិភាក្សាគ្នាយ៉ាងទូលំទូលាយអំពីការប្រព្រឹត្តទៅលើជនភៀសខ្លួនវៀតណាម អ្នកនេសាទជនជាតិថៃ និងគោលនយោបាយថា តើត្រូវធ្វើយ៉ាងដូចម្ដេចចំពោះអ្នកនេសាទថៃ ចំពោះជនភៀសខ្លួនវៀតណាម ដែលចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ក៏ដូចជាកំណត់ហេតុឆ្លើយកិច្ចសម្ភាសន៍ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែល ព្រុំ សារ៉ាត់ នេះបានឆ្លើយ។ ដូច្នេះកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ ក៏ដូចជាចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារពីរនេះគឺថាមានការជាប់ពាក់ព័ន្ធចម្បង ជាបឋម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺថ្ងៃនេះ លោកសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលបញ្ហានេះឡើងវិញមែនទេ? ពីព្រោះថាកាលពីសវនាការលើកមុននោះ អង្គជំនុំជម្រះបានបដិសេធសំណើរបស់លោកហើយ។ ខ្ញុំសូមរំឭកលោកផងថា វិធាន៨៧(៤)នោះ គឺតម្រូវឲ្យដាក់សំណើនៅពេលសមស្រប។ អ៊ីចឹងតើឯក-សារហ្នឹងត្រូវបានធ្វើជូននៅពេលណា អីនៅពេលណា? សូមលោកបញ្ជាក់បន្តិចទៅមើល៍។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំបានធ្វើសំណើដោយផ្ទាល់ ដាក់សំណើដោយផ្ទាល់មាត់រួចមកហើយ ប្រហែលជាខ្ញុំខុសហើយ អង្គជំនុំជម្រះមិនទាន់សម្រេចនៅឡើយនោះទេ។ អ៊ីចឹងឯងនៅពេលដែលលោកស្រីចៅក្រមសួរ ខ្ញុំក៏ឆ្លើយទៅគាត់ថា ឯកសារនេះវាពាក់ព័ន្ធយ៉ាងណានោះ។ ហើយនៅពេលនេះ យើងខ្ញុំក៏ស្នើសុំដោយផ្ទាល់មាត់ជាថ្មីម្ដងទៀតផងដែរ។ បាទ អ៊ីចឹងនៅពេលនេះ ខ្ញុំគ្រាន់តែលើកឡើងនូវសំណើដែលបានស្នើសុំពីមុនរួចមកហើយ ហើយសំណើសុំនេះគឺថានៅរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅឡើយ។ ដូច្នេះ

សំណួររបស់ខ្ញុំស្នើ -- សំណើរបស់ខ្ញុំគឺថាសូមឲ្យអង្គជំនុំជម្រះមេត្តាសម្រេច ដើម្បីអនុញ្ញាតឲ្យយើងខ្ញុំយកឯកសារទាំងពីរនេះទៅសួរសាក្សីដែលនឹងត្រូវចូលខ្លួនមកនេះ។

[១០:៥៣:៣៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ចំពោះឯកសារដែលលើកឡើងដោយសហព្រះរាជអាជ្ញានោះ គឺជាសាក្សីដែលនឹងមកផ្ដល់សក្ខីកម្ម ហើយយើងមិនជំទាស់អ្វីទេ។ ក៏ប៉ុន្តែយើងខ្ញុំសូមបន្ថែមបន្តិច គឺមេធាវីការពារក្ដីលោក ខៀវ សំផន គឺពាក់ព័ន្ធនឹងវិធាន៨៧(៤) គឺវាមានភាពយឺតយ៉ាវនៃសំណើនេះ។ ព្រោះវាពាក់ព័ន្ធទៅនឹងកងពល១៦៤ ដូច្នេះទោះបីជាមេធាវីការពារក្ដីជំទាស់ក៏ដោយ អង្គជំនុំជម្រះក៏នៅតែស្ដាប់សក្ខីកម្មសាក្សីរូបនេះ។ ហើយឯកសារដែលមេធាវី កូប៉េ ស្នើសុំដាក់នេះគឺជាឯកសារដែលមានសារៈសំខាន់នៅក្នុងការការពារកូនក្ដីរបស់គាត់។ ដើម្បីសួរសាក្សីដែលសហព្រះរាជអាជ្ញាបានស្នើសុំនោះ បន្ទាប់ពីមានការដាក់បញ្ចូលនូវកំណត់ហេតុសំណុំរឿង០០៣, ០០៤ មកនៅក្នុងសំណុំរឿង០០២/០២។

ដូច្នេះ ពាក់ព័ន្ធទៅនឹងបញ្ហានេះ គឺមិនមាននៅក្នុងដីកាដំណោះស្រាយទេ ព័ត៌មាននៃកងពល១៦៤នោះ។ ពិតណាស់យើងមិនអាចដឹងមុននូវហេតុការណ៍ដែលនឹងកើតមាននៅក្នុងពេលសវនាការ ហើយយើងក៏មិនដឹងថាតើអង្គជំនុំជម្រះនឹងទទួលយកសាក្សីណាខ្លះយកមកផ្ដល់សក្ខីកម្មនោះដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ជម្រាបជូនសាក្សីពាក់ព័ន្ធ -- អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ ខ្ញុំមិនទាន់ស្ថិតនៅក្នុងស្ថានភាពនេះនៅឡើយទេ ក៏ប៉ុន្តែសំណើនេះ វាមានភាពយឺតពេលបន្តិច អ៊ីចឹងអង្គជំនុំជម្រះគួរតែពិចារណាផង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមឲ្យបំភ្លឺបន្តិច សាក្សីដែលនឹងមកផ្ដល់សក្ខីកម្មត្រូវបានស្នើដោយព្រះរាជអាជ្ញា ឬក៏ដោយមេធាវីការពារក្ដី ឬដោយមេធាវី កូប៉េ?

[១០:៥៥:៣៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សាក្សីរូបនោះត្រូវបានស្នើសុំដោយមេធាវី កូប៉េ ក៏ប៉ុន្តែនៅពេលដែលមានការដាក់បញ្ចូលឯកសារមកពីសំណុំរឿង ០០៣, ០០៤ អ៊ីចឹងហើយ យើងមានប្រតិកម្មតបទៅនឹងភស្តុតាងថ្មីដែលយកមកដាក់នៅក្នុងសំណុំរឿងរបស់យើងនេះ។ ខ្ញុំគ្រាន់តែទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹង

អ្វីដែលយើងមានប្រតិកម្ម ដែលថាព័ត៌មានខ្លះវាមិនមាននៅក្នុងដីកាដំណោះស្រាយទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោក កូប៉េ ដើម្បីឲ្យចប់សព្វគ្រប់ -- ដើម្បីឲ្យវាចប់សព្វគ្រប់ទៅលើបញ្ហានេះ តើលោកឥឡូវនេះកំពុងតែស្នើសុំយកឯកសារមកសួរសាក្សីរូបនេះ ដោយយោងទៅលើសំណើសុំផ្ទាល់មាត់ពីមុនរបស់លោកនោះ គឺត្រូវតែអនុលោមទៅតាមវិធាន៨៧(៤) ដែលថាឲ្យលោកនេះ ត្រូវតែបង្ហាញនូវហេតុផលឲ្យបានត្រឹមត្រូវ។

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំអាច លោកស្រីចៅក្រម បញ្ហាដែលថាមានការពាក់ព័ន្ធនេះ គឺដោយសារយើងចូលទៅផ្នែកមួយស្តីអំពីការប្រព្រឹត្តមកលើជនអៀស -- ជនជាតិវៀតណាមនៅក្នុងដែនទឹក ប្រហែលជាក្នុងពាក់កណ្តាល ខែ១២ ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់ ប៉ាក់ សុខ ហើយឯកសារនេះ វាពាក់ព័ន្ធទៅនឹងសាក្សីចុងក្រោយក៏ដូចសាក្សីដែលត្រូវចូលខ្លួនបន្ទាប់នេះ។ ហើយឯកសារនេះ មិនទាន់បានយកមកពិភាក្សា នៅសម្រាប់ពេលការពិភាក្សាបញ្ចប់សួរដេញដោលនៅឡើយទេ។ នៅពេលដែលកំពុងតែដំណើរការ កិច្ចដំណើរការនីតិវិធី ខ្ញុំក៏បានឃើញឯកសារនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឃើញទៅថាវាមានការជាប់ពាក់ព័ន្ធមែនទែន។ វាជាការពិតហើយថា នៅពេលនោះ យើងខ្ញុំគួរតែដាក់សំណើសុំជាលាយលក្ខណ៍អក្សរ ប៉ុន្តែដោយសារតែវាមានពេលខ្លីពេក តែពីរថ្ងៃនៅពេលដែល ព្រុំ សារ៉ាត ចូលខ្លួនមកឆ្លើយ យើងខ្ញុំបានដាក់ទៅលើ*អ៊ីនធីហ្វេស* ប៉ុន្តែដោយសារតែការខ្វះនូវធនធាន យើងខ្ញុំមិនបានដាក់សំណើសុំជាលាយលក្ខណ៍អក្សរនៅពេលនោះបានទាន់ពេលវេលា។ ប៉ុន្តែក្នុងពេលសវនាការយើងខ្ញុំបានស្នើសុំដោយផ្ទាល់មាត់ហើយ។ នេះឯងគឺជាមូលហេតុដែលយើងខ្ញុំស្នើសុំសម្រាប់ការប្រើប្រាស់ឯកសារនោះ ជាពិសេសដោយសារតែប្រធានបទនៅក្នុងឯកសារនេះ គឺវាថ្មីផង ហើយ ប៉ាក់ សុខ បានឆ្លើយនៅក្នុងពាក់កណ្តាលខែធ្នូ។ ហើយបើទោះបីជាអង្គជំនុំជម្រះបាន ក៏បានអនុញ្ញាតផ្តល់នូវធនធានបន្ថែមទៀតមកដល់មេធាវី អង្គភាពការពារ គាំពារការការពារក្តី ក៏ប៉ុន្តែយើងខ្ញុំមិនទាន់បានប្រើប្រាស់ធនធាន គឺថវិការដែលបានអនុញ្ញាតផ្តល់នេះនៅឡើយទេ។ យើងខ្ញុំគួរតែស្នើសុំតាំងពីមុនមែន ក៏ប៉ុន្តែដោយសារតែមានបុណ្យណូអែលផង ហើយបុណ្យចូលឆ្នាំផង ក៏យើងខ្ញុំមិនអាចដាក់បានទាន់ពេលវេលា។

[១០:៥៩:00]

**ប្រធានអង្គជំនុំ៖**

ចុះសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញា តើមានបញ្ហាអ្វីទេលើសំណើសុំរបស់លោកក្រុមសហមេធាវីការពារក្តីលោក នួន ជា?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ បាទ ពិតណាស់សាក្សីដែលនឹងមកផ្តល់សក្ខីកម្មនោះ គឺត្រូវបានស្នើដោយមេធាវី នួន ជា ដូច្នេះមិនមានបញ្ហាអ្វីត្រង់ចំណុចនេះទេ។ ខ្ញុំសូមបញ្ជាក់ថា កាលពីខែវិច្ឆិកានោះគឺយើងខ្ញុំបានស្នើសុំឱ្យកំណត់ហេតុមួយចំនួនរបស់សាក្សីរូបនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ដាក់ជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ ចំពោះសំណើដែលលើកឡើងនាពេលនេះ របស់មេធាវីការពារក្តីនោះ កាលពីមុនយើងបានជំទាស់ហើយ ដោយសារតែនីតិវិធីបានដំណើរការរួចទៅហើយ ហើយមិនមានសំណើផ្លូវការអ្វីផ្អែកតាមវិធាន៨៧(៤)ទេ នៅពេលសវនាការថ្ងៃនោះគួរតែមានការដាក់ជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះ មិនត្រូវធ្វើផ្ទាល់មាត់ទាន់ហន់អ៊ីចឹង ដូចដែលមេធាវីការពារក្តីបានធ្វើទេ ហើយគាត់គួរតែដាក់នៅក្នុងអ៊ីនធឺហ្វេសឱ្យបានត្រឹមត្រូវ។ ការធ្វើអ៊ីចឹងគឺវាប៉ះពាល់ទៅដល់គោលការណ៍ចំពោះមុខ។ យើងចាំឱ្យមានការដាក់ឯកសារនៅក្នុងអ៊ីនធឺហ្វេស យើងមិនត្រូវស្នើសុំមកភ្លាមៗអ៊ីចឹងទេ ប៉ុន្តែយើងមិនជំទាស់អ្វីទៅនឹងការដាក់ឯកសារនេះជាភស្តុតាងទេ។ ហើយសំណើរបស់មេធាវី នួន ជា នេះ គឺយើងមិនជំទាស់អ្វីទេ នៅថ្ងៃនេះ ព្រោះថាឯកសារទាំងអស់នេះ គឺជាឯកសារដែលត្រូវបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញារួចមកហើយ ក្រោយពីមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដែលមានលក្ខណៈយឺតយ៉ាវបន្តិច។ ខ្ញុំគិតថា សម្រាប់ជាថ្ងៃអនាគតនោះ គឺគួរតែមេធាវីការពារក្តីរៀបចំសំណើជាលាយលក្ខណ៍អក្សរត្រឹមត្រូវយោងតាមវិធាន៨៧(៤) ហើយដាក់ឱ្យបានទាន់ពេលវេលា មិនគួរមកស្នើសុំនៅវិនាទី ឬក៏នាទីចុងក្រោយនៅក្នុងសវនាការអ៊ីចឹងទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានសារណាតបអ្វីទេលើសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា លើការសុំឱ្យទទួលយកឯកសារជាភស្តុតាងសម្រាប់ដេញដោលសាក្សី 1008 នាពេលខាងមុខនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

យើងខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ លោកប្រធាន។

[១១:០១:៥៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមឱ្យមេធាវីការពារក្ដី នួន ជា លោកអាចបង្ហាញនូវលេខឯកសារបានទេ? គឺលេខឯកសារដែលលោកចង់ឱ្យអង្គជំនុំជម្រះសម្រេចនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ E319/23.3.17.1។ គឺមានកិច្ចសម្ភាសន៍ពីរដែលឆ្លើយជូនអ្នកស៊ើបអង្កេត ហើយឯកសារទាំងពីរនេះ គឺឯកសារ E319/23.3.17 និង E319/23.3.18 ជាកំណត់ហេតុស្ដាប់ចម្លើយពីរ ហើយនិងឯកសារដែលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ជាឯកសារចុះកាលបរិច្ឆេទឆ្នាំ២០១៤។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះ ចង់ឱ្យបញ្ជាក់គឺលោកស្នើសុំឯកសារបី ដែលអនុលោមទៅតាមវិធាន៨៧(៤) អ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយលោកស្រីចៅក្រម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខាងសហព្រះរាជអាជ្ញា តើមានយោបល់អីពាក់ព័ន្ធទៅនឹងសំណើសុំឯកសារទាំងពីរនេះទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះលោកស្រីចៅក្រម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះអង្គជំនុំជម្រះយល់ឃើញថា ភាគីទាំងអស់គឺថាមិនជំទាស់ទៅនឹងឯកសារនេះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៤:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយឥឡូវនេះ បន្ទាប់ពីបានស្ដាប់ភាគីលើសំណើសុំទាំងពីរសរុបរួមគឺសំណើសុំរបស់ក្រុម

សហព្រះរាជអាជ្ញា ដែលនៅសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារធ្វើជាឯកសារភស្តុតាងដាក់ចូលទៅក្នុងសំណុំរឿង ហើយសួរដេញដោលសាក្សីដែលមានរហស្សនាម 2-TCW-1008 ហើយនិងសំណើសុំផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តី លោក នួន ជា ដែលស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកនូវឯកសារជាភស្តុតាងសម្រាប់សួរដេញដោលសាក្សីរូបនេះ ចំនួនបី អង្គជំនុំជម្រះសម្រេចទទួលយក និងដាក់ចូលជាភស្តុតាងនូវឯកសារតាមសំណើសុំរបស់សហព្រះរាជអាជ្ញា E319/23.3.28, E319/23.3.29, E319/23.3.30, E319/23.3.31, E319/23.3.32 និង E319/23.3.3 ហើយនិងទទួលយកឯកសារជាភស្តុតាង ដាក់ចូលសំណុំរឿងនូវឯកសារដែលស្នើសុំដោយក្រុមសហមេធាវីការពារក្តីលោក នួន ជា គឺឯកសារ E319/23.3.17, E319/23.3.17/1, E319/23.3.18។ ហើយអង្គជំនុំជម្រះនឹងផ្តល់នូវសំអាងហេតុនាពេលក្រោយ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1008 បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សី ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[១១:០៨:២៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

កុំៗអាលទាន់និយាយៗ ចាំរង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឱ្យភ្លើងសញ្ញាក្រហមជាមុនសិនណ៎ា។ អង់បន្តិចទៅ កាលណាស្តាប់សំណួរទៅ គឺជាការគិតមួយ គិតថាក្របខ័ណ្ឌប៉ុនណា ចម្លើយរបៀបណាដែលឆ្លើយតប ចាំបាច់ឆ្លើយតបនឹងសំណួរផង ហើយជាការផ្តល់លទ្ធភាពក្នុងការសម្របសម្រួលពេលវេលា ដើម្បីក្បាលមីក្រូហ្វូនប្រតិបត្តិការ ព្រោះភាសារបស់លោកដែលឆ្លើយតបមកភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះនោះ គឺនឹងបកប្រែជាភាសាបារាំង និងជាភាសាអង់គ្លេស អ៊ីចឹងវាទាមទាររយៈពេលមួយរយៈទៀត ក្នុងការបកប្រែភាសាហ្នឹង ឱ្យបានច្បាស់លាស់ ហើយនិងអស់សេចក្តី។

តើលោកឈ្មោះអី?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ មាស វឿន។

**ស៖** អរគុណ លោក មាស វឿន។ តើលោកកើតថ្ងៃខែឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំថ្ងៃខែទេ តែខ្ញុំកើតឆ្នាំ១៩៤៤។

**ស៖** បាទ អរគុណ។ ហើយលោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ លោក មាស វឿន?

[១១:១០:០០]

**ឆ៖** បាទ ខ្ញុំនៅភូមិ១ស្រែខ្ពង ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**ស៖** បាទ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា បច្ចុប្បន្ននេះ?

**ឆ៖** បាទ ខ្ញុំរស់នៅបច្ចុប្បន្ន គឺភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃ?

**ឆ៖** បាទ ខ្ញុំធ្វើស្រែ។

**ស៖** ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** បាទ ឪពុកខ្ញុំឈ្មោះ មាស (ស្លាប់) ម្ដាយខ្ញុំឈ្មោះ អ៊ឹម – ប៉ែន អ៊ឹម (ស្លាប់)។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ អ៊ឹម យឹម ហើយខ្ញុំមានកូនប្រាំបីនាក់ ស្លាប់មួយ។

**ស៖** លោក មាស វឿន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងជាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ទេ និងក៏ដូចជាមិនជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវអង្គជំនុំជម្រះទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះទេ។ តើពិតដែរឬទេរបាយការណ៍នេះ?

**ឆ៖** បាទ ពិតមែន។

**ស៖** លោក មាស វឿន តើលោកមានជំនឿសាសនាអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បាទ ខ្ញុំជឿសាសនាព្រះយាយស៊ូគ្រិស្ត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ អង្គជំនុំជម្រះបង្គាប់ឲ្យក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ធ្វើការសម្របសម្រួលណែនាំសាក្សីឲ្យធ្វើសម្បថតាមជំនឿសាសនារបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ។

*(សម្រាករយៈពេលខ្លី)*

[១១:១២:៥៥]

**ក្រឡាបញ្ជី៖**

បាទ អរគុណលោកប្រធាន។ លោកសាក្សីសូមលោកដាក់ដៃឆ្វេងនៅលើព្រះគម្ពីរ ហើយលើកដៃស្តាំឡើងលើ បន្ទាប់មកសូមលោកនិយាយតាមខ្ញុំ៖ ខ្ញុំសូមប្រកាសជាឱឡារិកថា

**លោក មាស វឿន៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា

**ក្រឡាបញ្ជី៖**

ខ្ញុំនឹងនិយាយតែការពិត

**លោក មាស វឿន៖**

ខ្ញុំនិយាយតែពីការពិត

**ក្រឡាបញ្ជី៖**

ការពិតទាំងអស់

**លោក មាស វឿន៖**

ការពិតទាំងអស់

**ក្រឡាបញ្ជី៖**

ហើយនិងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។

**លោក មាស វឿន៖**

មិននិយាយអ្វីក្រៅពីការពិតនោះទេ។

**ក្រឡាបញ្ជី៖**

បាទ សូមអរគុណ។

**សួរដោយប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះលោក មាស វឿន យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីដែលត្រូវចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ នៅក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការ

ឆ្លើយតបទៅនឹងសំណួរ ឬក៏សូមឲ្យលោកធ្វើការអធិប្បាយ រៀបរាប់ដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលចម្លើយតប ឬសេក្តីអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។

ហើយក្នុងឋានៈលោកជាសាក្សីត្រូវឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះដោយផ្ទាល់ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

**ស៖** លោក មាស វឿន តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណាខ្លះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំបានធ្លាប់គេទៅសម្ភាសនៅផ្ទះខ្ញុំម្តង ហើយក្រោយពីហ្នឹងមក បានមកកន្លែងអង្គជំនុំជម្រះ ពីរៗ -- បីដង បាទ។

**ស៖** អ៊ីចឹងលោកធ្លាប់ផ្តល់សក្ខីកម្មដល់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហ្នឹង ចំនួនបួនលើកហើយអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** បាទ អរគុណ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល បានអាន ឬក៏ស្តាប់ការអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនចំនួនបបួនលើក ចំពោះ ជាមួយនឹងអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ បានមើលខ្លះដែរតែកន្លែងខ្លះចាំ កន្លែងខ្លះមិនចាំគ្រប់ទាំងអស់នោះទេ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ឬក៏ស្តាប់ការអាន ដើម្បីរំឭកការចងចាំនោះ ពិតជា

ត្រឹមត្រូវសមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយ ដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីប្អូនលើក កាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ អាចបានខ្លះ អត់ខ្លះ។

[១១:១៦:៥៥]

**ស៖** អត់ហ្នឹង អត់យ៉ាងម៉េចទៅ? យើងចង់ដឹងថាអ៊ីចេះ ខ្លឹមសាររបស់ឯកសារដែលលោកអានហ្នឹង វាដូចគ្នាទៅនឹងខ្លឹមសារដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនដែរឬទេ? កាលណាមានបញ្ហា វាត្រូវដោះស្រាយបញ្ហាហ្នឹងជាមុន មុននឹងផ្តល់ លោកផ្តល់សក្ខីកម្ម យល់ទេ? ព្រោះឯកសារដែលលោកបានអានហ្នឹង គឺជាឯកសារដែលបានធ្វើកិច្ចសម្ភាសន៍ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើជាមួយលោកកាលពីពេលមុននោះឯង ដើម្បីឱ្យលោកពិនិត្យមើលឡើងវិញ ដើម្បីជារំឭកការចងចាំ ព្រោះទី១ រឿងវាយូរ, ទី២ រឿងវាធំ វាធំធេង ដែលកំណត់ហេតុធ្វើស្តាប់សក្ខីកម្មរបស់លោកប្អូនប្រាំដងឯណោះ វាវែងណាស់។ អ៊ីចឹងហើយបានជាយើងចង់ដឹងថាខ្លឹមសារជារួម ឬក៏ចំណុចដែលលោកចងចាំបាននោះ តើវាដូចគ្នា ឬសមស្របទៅនឹងខ្លឹមសារនៃចម្លើយដែលលោកផ្តល់កាលពីពេលមុនដែរឬទេ?

**ឆ៖** បាទចំណុចខ្លះដូច តែចំណុចខ្លះមិនដូចទេ ប៉ុណ្ណឹង។

**ស៖** បាទ អរគុណណាស់ ហើយលោក មាស វឿន។ ហើយនៅពេលនេះ លោកបានទទួលជំនួយមេធាវីប្រឹក្សាសាក្សី ដែលអង្គជំនុំជម្រះបានផ្តល់ឱ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមសំណើរបស់លោកហើយ គឺលោកស្រីមេធាវី សុក សុជាតា ជាមេធាវីសាក្សីរបស់លោក -- ប្រឹក្សាជាមួយលោក ក្នុងករណីចាំបាច់ គឺលោកអាចប្រឹក្សាយោបល់បាន ប្រឹក្សាយោបល់តែចំពោះសំណួរណាដែលនាំឱ្យលទ្ធភាពនៃចម្លើយតប ឬសេចក្តីអត្ថាធិប្បាយតបរបស់លោក ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ទម្លាក់កំហុសលើខ្លួនឯង នោះទើបពិភាក្សាណ៎ះ! បើសិនជាសំណួរទាំងឡាយដែលមិនដាក់ ទម្លាក់ថាឱ្យលោក ទម្លាក់កំហុសលើលោក ថាលោកបានចូលរួមប្រព្រឹត្តដោយផ្ទាល់ ឬក៏រួមជាមួយសហការមួយផងទៀត ប្រព្រឹត្តអំពើអាក្រក់ៗនៅក្នុងរបបនោះទេ គឺចាត់ទុកថាមិនមែនជាសំណួរដែលនាំឱ្យដាក់ពិរុទ្ធភាព ដែលចាំបាច់ត្រូវពិភាក្សាជាមួយសាក្សីទេ ព្រោះមានកាតព្វកិច្ចត្រូវតែឆ្លើយ រាល់សំណួរហើយឆ្លើយតែការណ៍ដែលពិត។ លោកយល់ទេ?

**ឆ៖** បាទ យល់។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីតាំងសំណួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនេះរឿងក្តី ពីព្រោះលោក នួន ជា ជាម្ចាស់សំណើក្នុងការសុំឲ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីរូបនេះ។ ហើយសហមេធាវីទាំងពីរក្រុមមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ ដោយសហមេធាវីការពារក្តីលោក ខៀវ សំផន និងសួរចុងក្រោយគេបង្អស់នៃដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១១:២០:៣៨]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី លោកទើបតែបានបញ្ជាក់ប្រាប់តុលាការ ហើយនិងស្បថចំពោះព្រះគម្ពីរថា លោកជាគ្រិស្តបរិស័ទ ហើយលោកនិយាយតែការពិត។ ហើយចំណុចមួយនៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយអំពីជំនឿសាសនារបស់លោក គឺ E3/8752 ហើយលោកបញ្ជាក់ថា ជំនឿ គ្រិស្តសៀននេះគឺថា បុគ្គលម្នាក់ដែលត្រូវបាននាំមកតុលាការនេះគឺឈ្មោះឌុច តើលោកជា -- ចូលជាគ្រិស្តបរិស័ទពីមុនហើយ ឬក៏ក្រោយឆ្នាំ១៩៧៩ ទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំជឿឆ្នាំ៩៣ ជឿព្រះគ្រិស្ត៩៣។

**ស៖** បាទ អរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ហើយនិងរយៈពេលមុនពេលរំដោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ដែរ ហើយខ្ញុំពិនិត្យមើលអ្វីដែលលោកបាននិយាយនៅក្នុងចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រភាសាអង់គ្លេស នៅទំព័រ២ ERN 00849487, ខ្មែរ 00733313 (មិនមានអត្ថបទបកប្រែភាសាបារាំងទេលោកប្រធាន) លោកបានឆ្លើយនៅក្នុងចម្លើយមជ្ឈមណ្ឌលឯកសារកម្ពុជារយៈពេលគឺថា មុនឆ្នាំ១៩៧០ មុនរដ្ឋប្រហារ ក្នុងខែមីនា ឆ្នាំ១៩៧០ លោកបាននិយាយអំពីបងប្រុស បងប្អូនប្រុសរបស់លោក។ សូមលោកប្រាប់តុលាការ តើបងប្អូនប្រុសរបស់

លោកមួយចំនួន មានបញ្ហាអ្វីទេ មុនឆ្នាំ១៩៧០?

**ឆ៖** ប្អូនប្រុសឈ្មោះអី ដូចមិនមាន ទាក់ទងប្អូនប្រុសខ្ញុំអត់មាននេះផង ប្អូនប្រុសខ្ញុំស្លាប់អស់ហើយ អត់ដឹងថា មានទាក់ទង ខ្ញុំដូចអត់មាននិយាយក្នុងហ្នឹងផង។

**ស៖** ខ្ញុំសូមរំឭកការចងចាំរបស់លោក លោកសាក្សី។ ប្រហែលជា៥ ឬ៦ឆ្នាំហើយដែលលោកបានផ្តល់បទសម្ភាសន៍។ ខ្ញុំដកស្រង់ពាក្យរបស់លោក អ្វីដែលលោកបាននិយាយកាលនោះ៖ “បន្ទាប់ពីខ្ញុំបានចាកចេញពីផ្ទះចូលទៅក្នុងព្រៃ ខ្ញុំដឹងថា ខ្ញុំបានបម្រើកិច្ចការខ្មែរក្រហម នៅពេលនោះបងប្រុសរបស់ខ្ញុំអាយុ៣០ឆ្នាំ គេបានចាប់ខ្លួន ហើយគេយកទៅសម្លាប់នៅឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ បន្ទាប់មកប្អូនប្រុសរបស់ខ្ញុំក៏គេបានចាប់ខ្លួន ហើយនិងយកទៅសម្លាប់ដែរ។ ហើយ -- ពីព្រោះគេចោទថា គាត់មាននិន្នាការជាប់ពួកខ្មែរក្រហម។” បាទ សូមអភ័យទោសគឺថា ខ្ញុំយោងទៅរករយៈពេលមុនឆ្នាំ១៩៧៥។ តើត្រូវដែរឬទេលោកសាក្សី បងប្រុស ហើយនិងប្អូនប្រុសរបស់លោក ហើយនិងឪពុកម្តាយរបស់លោកត្រូវបានគេសម្លាប់ក្នុងចន្លោះឆ្នាំ១៩៧០ទៅ៧៥ ពីព្រោះគេជឿ សង្ស័យថាពួកគាត់ហ្នឹង ជាប់មាននិន្នាការជាមួយចលនាខ្មែរក្រហម?

[១១:២៥:00]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយបញ្ជាក់ពីពេលហ្នឹង ខ្ញុំនឹកឃើញៗ ដែលលោកបញ្ជាក់ដល់ខ្ញុំ។ មុនឆ្នាំ១៩៧០ ពី៦៧, ៦៨ -- ៦៧អីចឹងហើយ ដែលខ្ញុំ ពេលដែលខ្ញុំចេញ ចាកចេញមកព្រៃហ្នឹង បងប្រុសខ្ញុំមានគេចាប់ ដោយសារមានការទាក់ទងរវាងអ្នកនៅព្រៃហ្នឹង ហើយឲ្យអង្ករឲ្យអីមកខាងព្រៃហ្នឹង។ ដូច្នេះក្នុងពេលនុំងមានបងប្រុសខ្ញុំម្នាក់ ហើយប្អូននុំង ប្អូនថ្លៃទេ មិនមែនជាប្អូនបង្កើតទេ។ បងៗខ្ញុំ គឺបងបង្កើត ហើយប្អូននោះគឺប្អូនថ្លៃ ហើយបងជីដូនមួយនោះម្នាក់ ស្លាប់។ កាលនុំង គឺមានការគេចាប់យកទៅសម្លាប់នៅភ្នំត្រពាំងក្រឡឹងនុំង។ បាទ ខ្ញុំនឹកឃើញប៉ុណ្ណឹង។

**ស៖** នៅទំព័របន្ទាប់ លោកបាននិយាយថា “ខ្ញុំចូលទៅក្នុងព្រៃ ខ្ញុំបានខ្លាចពួកស៊ើបការណ៍របបលន់នល់”។ តើលោកខ្លាចមន្ត្រីស៊ើបការណ៍ ឬក៏គិញរបស់លន់ នល់ ឬក៏ថា ដោយសារតែមូលហេតុអ្វីវាមានពាក់ព័ន្ធអីទៅនឹងបងប្អូនប្រុស ហើយនិងឪពុកមារបស់លោក ឬក៏យ៉ាងដូចម្តេច?

**ឆ៖** បាទ កាលខ្ញុំនៅព្រៃ តែបងខ្ញុំ ប្អូនខ្ញុំ នៅផ្ទះ ហើយពេលខ្លះដែលមានបងប្អូនខ្លះដែលមករកនៅជិតភូមិហ្នឹង គេមកសុំអង្ករ សុំបាយទៅ ហើយជួនកាល គេដឹងពីរឿងកិច្ចការហ្នឹងទៅ នាំឲ្យមានការទាក់ទងស៊ើប ហើយគេពិនិត្យបានទៅ ក៏គេមានការចាប់ មានការនាំខ្លួនអីចឹង ហ្នឹងមានការទាក់ទង

អ៊ីចឹងឯង។

**ស៖** អរគុណលោកសាក្សី ខ្ញុំនឹងចូលទៅដល់ការការវាយលុកចូលទីក្រុងភ្នំពេញចុងក្រោយ នៅឆ្នាំ១៩៧៥ ខែមេសា លោកបានឆ្លើយយ៉ាងលម្អិតក្នុងរយៈពេលបួនថ្ងៃក្នុងពីឆ្នាំ២០១២ ហើយខ្ញុំមានសំណួរនៅតុលាការនេះ ហើយខ្ញុំមានសំណួរបន្ថែមខ្លះសួរលោកទៀត នៅពេលនេះ។

នៅក្នុងចម្លើយដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រ៩, ERN 00849494, ខ្មែរ 00733320 លោកមិននិយាយអំពីការវាយប្រហារទីក្រុងភ្នំពេញ បន្ទាប់មក លោកនិយាយថា សូមដកស្រង់សម្តី៖ "នៅពេលនោះ គឺកងពលមកពីភូមិភាគបូព៌ា បន្ទាប់មក គឺកងទ័ពនិរតី ហើយនិងកងទ័ពមកពីពាយ័ព្យ បានចូលចាប់ដៃគ្នា ដើម្បីវាយ"។ ខ្ញុំមិនប្រាកដថា មិនដឹងថា លោកយោងទៅរកភូមិភាគពាយ័ព្យដែរឬអត់ទេ ខ្ញុំទុកសិន។

តើលោកចាំថា លោកបាននិយាយនៅពេលដែលគេកាន់កាប់ទីក្រុងភ្នំពេញបាន គឺថាកងកម្លាំងមកពីភូមិភាគបូព៌ា ហើយនិងភូមិភាគនិរតី ហើយនិងភាគឧត្តរ បានមកចាប់ដៃគ្នា រួមគ្នាដែរឬទេ?

**ឆ៖** បាទ កាលដែលវាយចូលភ្នំពេញហ្នឹង មានអ្នកកងទ័ពខាងឧត្តរ ហើយនិងខាងបូព៌ា ហើយនិងខាងនិរតីដែលខ្ញុំដឹងតែកងប៉ុណ្ណឹង ហើយនិងកងភូមិភាគពិសេសេ ក្នុងពេលវាយចូលភ្នំពេញ បាទ។

[១១:៣០:០០]

**ស៖** នៅពេលដែលចូលកាន់កាប់បានទីក្រុងភ្នំពេញ តើលោកបានដឹងដែរឬទេ ថាមានការប៉ះទង្គិចអាវុធរវាងកងកម្លាំងខាងបូព៌ា ហើយនិងកងកម្លាំងខាងនិរតីដែរទេ?

**ឆ៖** បាទ ក្នុងពេលនោះអត់មានទេ ខ្ញុំខាង -- និយាយពីខ្ញុំផ្ទាល់ ខ្ញុំអត់បានដឹងថាប៉ះពាល់គ្នាទេ។ ចំណែកផ្នែកខាងខ្ញុំខាងណោះ។

**ស៖** សូមអរគុណ។ តើលោកនៅចាំដែរឬទេ នៅពេលមួយអតីតទាហាន លន់ នល់ ដែលលើកទង់ជ័យសហើយនោះ នៅចាំថាពួកទាហានលន់ នល់ បានលើកទង់ជ័យសដែរឬទេ?

**ឆ៖** បាទ បានលើក លើកតាមផ្ទះ មានលើកតាមផ្ទះថ្ម ផ្ទះអីមានលើកទង់សទាំងអស់ តែបងប្អូនខាងណោះអត់មានតបតទេ។

**ស៖** នៅពេលដែលទាហាន លន់ នល់ បានលើកទង់ជ័យសហើយ តើមានការណែនាំដូចម្តេចនៅក្នុងកងពលរបស់លោកថា ត្រូវធ្វើម៉េចចំពោះពួកទាហានដែលបានលើកទង់ជ័យសហើយនោះ? ហើយខ្ញុំឱ្យលោកឆ្លើយកម្រិតតែអ្វីដែលលោកដឹងក្នុងកងពលរបស់លោកតែប៉ុណ្ណោះ។

**ឆ៖** បាទ ខ្ញុំបានទទួលការណែនាំ បើសិនណាជាខ្លាំងលើកទង់សហើយ គឺអត់ឲ្យបងប្អូនខាងណោះប៉ះពាល់ទេ សូមយកតែកាំភ្លើងចេញហើយ ឲ្យគេនៅតាមកន្លែងគេដដែល។

[១១:៣២:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវហ្នឹងដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣២:៥៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី មុនពេលឈប់សម្រាក ខ្ញុំបានសួរលោកអំពីកងទ័ពលន់នល់ លើកទង់ជ័យសនៅទីក្រុងភ្នំពេញ នៅថ្ងៃ១៧ មេសា ១៩៧៥។ តាមរយៈសក្ខីកម្មរបស់លោក ខ្ញុំយល់ថា លោកបានស្នាក់នៅក្នុងទីក្រុងភ្នំពេញតែមួយសប្តាហ៍ទេ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយជូនទៅមជ្ឈមណ្ឌលឯកសារ អង់គ្លេសគឺ ERN 00849495, ខ្មែរ 0033321 -- 00373321 លោកថា ប្រជាជនគឺថាធ្វើដំណើរតាមដងផ្លូវកាត់ដីហុយ ហើយលោកមិនដឹងថាវាយ៉ាងនោះទេ។ ហើយតាមដែលខ្ញុំយល់នោះ គឺថានៅពេលដែលលោកចាកចេញពីភ្នំពេញ លោកបានធ្វើដំណើរទៅកំពត ហើយស្នាក់នៅកំពតនោះ ប្រហែលជា១០ខែ ឬក៏មួយឆ្នាំ។ តើលោកដឹងទេថាមានអ្វីកើតឡើងចំពោះទាហានលន់លន់ដែលបានចាប់ខ្លួននៅថ្ងៃ១៧ មេសា ១៩៧៥? លោកដឹងថា មានរឿងអ្វីកើតឡើងដល់ទាហានលន់ នល់ទាំងនោះទេ នៅពេលដែលលោកនៅឯកំពត?

[១៣:៣៥:៤៦]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំដែលផ្លាស់ពី ដកចេញពីភ្នំពេញទៅនៅកំពតនោះ នៅត្រង់កំពង់ត្រាច ទូកមាសៗ។ ខ្ញុំអត់បានដឹងថាទាហាន លន់ នល់ នៅកន្លែងនោះទេ ដែលខ្ញុំទៅហ្នឹងឃើញតែប្រជាជន ឃើញតែភូមិប្រជាជនទេ ហើយខ្ញុំទៅហ្នឹង ទៅដើម្បីការ ធ្វើមើលផ្លូវរទេះភ្លើងដែលវាដាច់ជួសជុលឲ្យ -- អ្នកធ្វើការគេជួសជុលផ្លូវរទេះភ្លើងតែប៉ុណ្ណោះបាទ។

**ស៖** ខ្ញុំសួរលោកតាមរបៀបផ្សេងវិញ។ លោកសាក្សី តើខ្លួនលោកផ្ទាល់ ឬក៏កងទ័ពណាម្នាក់នៅក្នុងកងពលរបស់លោកចូលរួមពាក់ព័ន្ធនៅក្នុងការសម្លាប់ទាហាន លន់ នល់ ដែលបានលើកទង់ជ័យស ទោះជាអ្នកនោះមកពីភ្នំពេញក្តី មកពីកំពតក្តី តើកងទ័ពរបស់លោកណាមានចូលរួមពាក់ព័ន្ធក្នុងការសម្លាប់អ្នកទាំងនោះទេ?

**ឆ៖** បាទ កងទ័ពខ្ញុំអត់មានបានទាក់ទងនឹងសម្លាប់ទេ ពីព្រោះអី ចេញពីភ្នំពេញទៅសុទ្ធតែពួកខ្ញុំទាំងអស់ អត់មានកងទាហាន លន់ នល់ ណាដែលនៅជាប់ជាមួយខ្ញុំនោះទេ។

**ស៖** នៅពេលដែលលោកនៅកំពត មុនទៅកោះកុង តើលោកធ្លាប់បានឮអំពីកងទ័ពលន់ នល់

លើកទង់ជ័យស ហើយក្រោយមកក៏ត្រូវបានគេសម្លាប់ចោលទាំងអស់ទៅ។ លោកធ្លាប់ឮទេ?

**ឆ៖** បាទ ខ្ញុំអត់បានឮផង។

**ស៖** ខ្ញុំសូមត្រឡប់ចូលទៅនិយាយអំពីការរំដោះ ហើយនិងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកមួយ ជាពិសេសគឺឯកសារ E3/424 នៅក្នុងសំណួរចម្លើយលេខ៥ លោកបានឆ្លើយដូចតទៅ៖ "សួរ៖ ប្រសិនបើប្រជាជនទីក្រុងភ្នំពេញបដិសេធមិនចាកចេញ តើថ្នាក់លើខ្មែរក្រហមបញ្ជាឲ្យសម្លាប់អ្នកទាំងនោះទេ? បាញ់សម្លាប់អ្នកទាំងនោះទេ? ឆ្លើយ៖ គឺមិនមានបញ្ជាឲ្យបាញ់សម្លាប់អ្នកទាំងនោះទេ។" សូមលោករៀបរាប់ជូនតុលាការឲ្យបានលម្អិតបន្តិចមើលថា បញ្ហាហ្នឹងបានធ្លាក់មកដល់លោកហ្នឹងដោយរបៀបណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៣៩:១៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សំណួរដែលនិយាយអំពីទាហាន លន់ នល់ ខ្ញុំមិនជំទាស់អ្វីទេ។ ក៏ប៉ុន្តែបើនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺការជម្លៀសជនស៊ីវិលនោះ ខ្ញុំគិតថា មេធាវីការពារក្តីកំពុងតែយល់ច្រឡំអំពីការជំនុំជម្រះក្តីយើងនេះហើយ ប្រហែលជាទាល់តែសប្តាហ៍ក្រោយនៅចំពោះមុខតុលាការកំពូលឯណោះ បានដោះស្រាយបញ្ហាហ្នឹង។ រឿងហ្នឹងគឺយើងបានពិភាក្សាដេញដោលគ្នារួចមកហើយនៅក្នុងសំណុំរឿង០០២/០១ ដែលនិយាយអំពីការជម្លៀសប្រជាជន។ ដូច្នេះ ក្នុងសំណុំរឿង០០២/០២ យើងនេះ គឺមិនមាននិយាយអំពីការជម្លៀសប្រជាជនទេ។ វាមិនពាក់ព័ន្ធទៅនឹងប្រធានបទទេ លោកប្រធាន។

**លោក វីុចទ័រ កូប៉េះ៖**

ដូចជាស្មុគស្មាញបន្តិច។ សាក្សីបានរៀបរាប់លម្អិតនៅក្នុងសវនាការលើសំណុំរឿង០០២/០១ ការដែលខ្ញុំមិនសួរសំណួរបើកចំហដោយសារថាបាន -- សូមពន្យល់ ថាហេតុអ្វីបានជាចំណុចនេះមានការជាប់ពាក់ព័ន្ធដូចដែលការលើកឡើងរបស់សហព្រះរាជអាជ្ញា ដោយសារសំណួរបន្ទាប់របស់ខ្ញុំវាមានការជាប់ពាក់ព័ន្ធ អ៊ីចឹងខ្ញុំចង់បង្កើតនូវមូលដ្ឋានរួចហើយទើបខ្ញុំតាំងសំណួរជាក្រោយ។ ខ្ញុំគ្រាន់តែចង់សួរ

ថាតើ គាត់ ដោយសារតែគាត់មកពីកងទ័ពភូមិភាគបូព៌ា គឺថាត្រូវបានបញ្ជាដោយមេបញ្ជាការម្នាក់ដែលយើងចង់ឲ្យចូលខ្លួនជាសាក្សីនៅទីនេះ។ ដូច្នេះ សំណួរបន្ទាប់របស់ខ្ញុំ គឺពាក់ព័ន្ធនឹងមេបញ្ជាការ។ ដូច្នេះ ខ្ញុំនឹងរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤២:៣០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ភាពច្របូកច្របល់គឺអ៊ីចេះលោកមេធាវី ទោះបីជាសំណួរសួរតាមក្រោយក៏ដោយ ប៉ុន្តែសួរថាតើលោកកំពុងសួរការជម្លៀសហ្នឹង គឺការជម្លៀសជនស៊ីវិល ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួរដែលខ្ញុំចង់សួរ គឺខ្ញុំចង់ដឹង ថាតើគាត់ដឹងថាមេបញ្ជាការកងពលភូមិភាគបូព៌ាហ្នឹងគាត់ទទួលបានបញ្ជាដូចគ្នាដែរឬក៏អត់? ហើយសាក្សីខ្លួនឯងហ្នឹងគាត់បានទទួលបញ្ជាហ្នឹងមកពីណា ដោយសារបញ្ជានេះ ក៏បានបញ្ជាទៅដល់ភូមិភាគបូព៌ាដែរ។ ដោយសារខ្ញុំយល់ឃើញថា បុគ្គលដែលត្រូវសួរអាចនឹងមិនបានចូលខ្លួនមកចំពោះមុខតុលាការ។ ខ្ញុំ -- ហេង សំរិន នេះគាត់គឺជាមេបញ្ជាការមកពីភូមិភាគបូព៌ា។ អ៊ីចឹងខ្ញុំចង់សួរហ្នឹងគឺមានការពាក់ព័ន្ធអ៊ីចឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ក៏ប៉ុន្តែបញ្ហានេះ គឺវាពាក់ព័ន្ធនឹងការជម្លៀសជនស៊ីវិលចេញពីទីក្រុងភ្នំពេញ ឬក៏វាពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះទាហាន លន់ នល់? ខ្ញុំមិនយល់អំពីការលើកឡើងរបស់លោកនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក៏មិនយល់ដែរ ថាហេតុអ្វីខ្ញុំមិនអាចសួរសំណួរនេះបាន។ យើងមិនសួរអំពីការជម្លៀសប្រជាជនទៀតទេ ប៉ុន្តែវាមានតែមួយសំណួរសោះ សំណួរនេះវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធក្នុងការបញ្ជា ពាក់ព័ន្ធទៅនឹងភូមិភាគបូព៌ា។ តើបញ្ហាអ្វីបានជាខ្ញុំសួរសំណួរនេះមិនបាន?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យសួរ។ តាំងសំណួរសាជាថ្មីម្ដងទៀត។ ហើយសាក្សី ត្រងចាំស្ដាប់និងចាំឆ្លើយតបនូវសំណួរនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានឆ្លើយថា មានការបញ្ជាពីថ្នាក់លើថាមិនឲ្យបាញ់សម្លាប់មនុស្សទេ បើគេ បើប្រជាជនបដិសេធមិនចាកចេញពីភ្នំពេញ។ សំណួរខ្ញុំគឺដូចតទៅនេះ ខ្ញុំជឿជាក់ថា មានមនុស្សម្នាក់មានឋានៈប្រហែលលោកហ្នឹង ដូចលោក ស្មើនឹងលោក គឺលោក ហេង សំរិន ដែលជាអនុមេបញ្ជាការកងពលនៅភូមិភាគបូព៌ា។ តើលោកដឹងទេ ពេលនោះ លោក ហេង សំរិន បានទទួលបញ្ជាដូចដែលដែលលោកបានទទួលដែរទេ?

**ឆ៖** បាទ ការដែលបញ្ជាមិនឲ្យបាញ់សម្លាប់ទាហាន ឬក៏ជម្លៀសប្រជាជនទុំង ខ្ញុំបានទទួលខាងខ្ញុំ តែខ្ញុំទទួលថា ខាងលើខ្ញុំ គឺថាកងពលខាងខ្ញុំប្រាប់អ៊ីចឹង។ ក៏ប៉ុន្តែខាងបូព៌ា ខ្ញុំមិនដឹងថាគេប្រាប់យ៉ាងម៉េច ខ្ញុំអត់ដឹងដែរ ពីព្រោះអីខ្ញុំដឹងតែផ្នែកខាងខ្ញុំ ខាងកងពលលេខ១ខ្ញុំហ្នឹង ខាងនេះទេ បាទ។

[១៣:៤៥:៥៩]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែនៅសប្តាហ៍ដែលលោកនៅភ្នំពេញហ្នឹង តើលោកមានបានឮថាកងទ័ពភូមិភាគបូព៌ា គឺមានអាកប្បកិរិយាខុសពីកងទ័ពមកពីភូមិភាគនិរតី?

**ឆ៖** ខាងខ្ញុំ ខ្ញុំមិនបានថាគេខាងទុំងទេ ខ្ញុំខាងខ្ញុំ ខាងកងពលខ្ញុំ មិនបានថាគេទេ ព្រោះផ្នែកមុខសញ្ញាវាខុសគ្នា។ ខាងទុំង គេទទួលបញ្ជាផ្នែកខាងបូព៌ា ខាងខ្ញុំទទួលបញ្ជាខាងផ្នែកខាងខ្ញុំខាងនេះ ដូច្នេះគេ ដល់គេធ្វើ មិនដឹងថាគេធ្វើទទួលបែបម៉េច ក៏ប៉ុន្តែខ្ញុំខាងខ្ញុំ ខ្ញុំទទួលអ៊ីចឹង។ ទោះបីប្រជាជនក៏ដោយ ទាហានក៏ដោយ ឬសម្ភារះរបស់ប្រជាជនក្នុងទុំងក៏ដោយ ហាមឃាត់អត់ឲ្យមានការប៉ះពាល់។ សូមចប់។

**ស៖** ច្បាស់ហើយលោកសាក្សី សូមអរគុណ។ មុននឹងខ្ញុំចូលសួរអំពីខេត្តកោះកុង ខ្ញុំសូមឲ្យលោកបញ្ជាក់ពីរបីចំណុច ទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃកងពលរបស់លោក ហើយនិងថ្នាក់លើ។ នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏ដូចក្នុងកំណត់ហេតុស្តាប់ចម្លើយផ្សេងៗទៀតដែរ លោកនិយាយអំពី សុន សេន លោកនិយាយអំពី តាម៉ុក។ សុន សេន គឺជានាយអគ្គសេនាធិការ ប៉ុន្តែតាមដែលលោកដឹង តាម៉ុក គឺជាមេបញ្ជាការនៅសមរភូមិ ក៏ដូចជាមេបញ្ជាការកំពូល ដែលក្នុងជួរកងទ័ពមានគេចែកចេញជាបីផ្នែក គាត់ –តាម៉ុក– គាត់អាចបញ្ជាកងទ័ពណាក៏បាន។ ហើយបើគិតពីអំណាច គាត់មានអំណាចជាង សុន សេន។ បើខ្ញុំសង្ខេបបែបនេះ តើវាត្រឹមត្រូវដែរឬទេ ហើយលោក

ដឹងអំពីរថនាសម្ព័ន្ធបែបនេះដោយរបៀបណា សូមជម្រាបជូនតុលាការផង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៤៨:៣៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនបានចាំថា ខ្ញុំអានបែបហ្នឹងទេ ក៏ប៉ុន្តែមេធាវីការពារក្ដី គាត់សូមបញ្ជាក់ឲ្យបានច្បាស់លេខឯកសារ ហើយនិងលេខ ERN។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងផ្ដល់ជូន។ គាត់បានឆ្លើយនៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រជាអង់គ្លេស ទំព័រ២៥, ERN 00849510, ខ្មែរ00733339 ហើយក៏គាត់ឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយគឺ E319/23.3.30 គឺនៅក្នុងសំណួរចម្លើយលេខ០៥ និងលេខ២៤។ ដូច្នេះ ត្រឡប់ទៅសំណួរដើមរបស់ខ្ញុំវិញ។

**ស៖** លោកសាក្សី ដំបូង ខ្ញុំសួរលោកថា អ្វីដែលខ្ញុំរៀបរាប់អំពី តាម៉ុក នេះ តើត្រឹមត្រូវទេ គឺថាគាត់ជាមេបញ្ជាការទាំងបីសាខា ហើយក៏ជាមេបញ្ជាការនៅតាមសមរភូមិ ហើយមានអំណាចជាង សុន សេន។ ខ្ញុំសង្ខេបបែបហ្នឹង ត្រឹមត្រូវទេ?

[១៣:៥០:០៤]

**លោក មាស វឿន៖**

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** អ៊ីចឹងសូមលោកពន្យល់ជូនតុលាការ ម៉េចបានជាលោកដឹងតាំងពីកងទ័ពទាំងបីប្រភេទហ្នឹងផង?

**ឆ៖** ខ្ញុំ -- សូមលោកបញ្ជាក់បន្តិចថា កងទ័ពទាំងបីប្រភេទបែបម៉េច ខ្ញុំមិនយល់។

**ស៖** លោកបាននិយាយអំពី -- គឺលោកខ្លួនឯងផ្ទាល់និយាយអំពីកងទ័ពជើងទឹក ជើងគោក និងជើងអាកាស។ ហើយលោកបានឆ្លើយថា តាម៉ុក ជាមេបញ្ជាការទាំងបីផ្នែកហ្នឹងឯង ទាំងជើងទឹក ជើងគោក ជើងអាកាស។ ហើយបើគិតពីអំណាចនៅក្នុងជួរកងទ័ពហ្នឹងគឺគាត់មានអំណាចខ្ពស់ជាង សុន សេន។

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ពីអំណាចគ្រប់គ្រងនិងបញ្ជា ព្រោះអីកងទ័ពទាំងជើងទឹក ទាំងជើងគោក ទាំងជើងអាកាស ដែលគាត់អាចបញ្ជាបាន។ ហ្នឹងជាកិច្ចការរបស់គាត់ គាត់មានអំណាច កិច្ចការងាររបស់ខាងលើ ខ្ញុំមិនដឹងកិច្ចការងារគាត់ទាំងអស់ថា យ៉ាងម៉េចទេ ក៏ប៉ុន្តែឃើញថាគាត់បានបញ្ជាគ្រប់កងទ័ពទាំងអស់ហ្នឹង ទាំងជើងទឹក ជើងគោក ជើងអាកាស គាត់បញ្ជាបាន ក៏ប៉ុន្តែកិច្ចការខាងលើរបស់គាត់រៀបរយយ៉ាងម៉េច អាហ្នឹងខ្ញុំអត់ដឹងអស់នូវកិច្ចការរបស់គាត់ទេ។ ហ្នឹងគ្រាន់សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ខ្ញុំនៅតែយល់មិនទាន់បានច្បាស់ថា តើលោកដឹងថា តាម៉ុក ជាអ្នកត្រួតត្រារួម ក្ដាប់រួមនៅក្នុងការបញ្ជាកងទ័ព។ អ៊ីចឹងធ្វើម៉េចបានជាលោកដឹងថាដូច្នេះនៅពេលនោះ?

**ឆ៖** ខ្ញុំបានដឹងថាគាត់បញ្ជាបានដោយសារថា កងខ្ញុំក៏គាត់បញ្ជាបាន កងដទៃគាត់បញ្ជាបាន ខ្ញុំដឹងគាត់ថា ដឹងថាអ្នកដឹកនាំ ដឹងថាគាត់មានអំណាចប៉ុណ្ណឹង ខ្ញុំដឹងថាប៉ុណ្ណឹង ប៉ុន្តែអំណាចរបស់គាត់រៀបរយយ៉ាងណាទៀតនោះ ខ្ញុំមិនដឹងទេ ប៉ុន្តែគាត់បញ្ជាបានគ្រប់កងអ៊ីចឹងឯង។ សូមអស់។

[១៣:៥៣:០៤]

**ស៖** បាទ សូមអរគុណ។ លោកសាក្សី តើត្រឹមត្រូវទេអ្វីដែលខ្ញុំទើបតែលើកឡើងថា មុនពេលលោកទៅកោះកុង គឺលោកបានស្នាក់នៅកំពតពី១០ខែ ទៅមួយឆ្នាំ ត្រឹមត្រូវដែរទេ?

**ឆ៖** អត់ទេ អត់ទាន់ត្រឹមត្រូវទេ ខ្ញុំទៅប្រហែលជាបានប្រហែលជាបីទៅបួនខែប៉ុណ្ណឹងទេ ទៅកំពតនោះ។

**ស៖** ខ្ញុំមិនបាននិយាយថាលោកខុសទេ ប៉ុន្តែលោកបានឆ្លើយជូនអង្គជំនុំជម្រះសាលាដំបូងនៅខែតុលា ២០១២ នៅម៉ោង០៩:៥៦ ព្រឹក៖ “ខ្ញុំនៅខេត្តកំពតប្រហែលមួយឆ្នាំ បើខ្ញុំមិនច្រឡំទេ ក៏យ៉ាងហោចណាស់បាន១០ខែដែរ ហើយបន្ទាប់មកក៏គេបញ្ជូនខ្ញុំទៅខេត្តកោះកុង។ តើនៅក្នុងឆ្នាំ១៩៧៦ មែនទេបាទ? បាទ នៅឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧”។ តើចំណុចដែលលោកឆ្លើយនេះជួយរំឭកដល់ការចងចាំលោកបានទេ?

**ឆ៖** ខ្ញុំទៅៗនៅកំពតហ្នឹង បើទៅ ខ្ញុំបានប្រហែលជាបីទៅបួនខែប៉ុណ្ណឹង ហើយបានគេផ្លាស់ខ្ញុំទៅកោះកុង អាហ្នឹងនៅបានបីឆ្នាំ។ បីឆ្នាំនៅកោះកុង ហើយបានគេផ្លាស់ពីនុ៎ងមកទៀតនោះ បានប្រហែលជាបានផ្លាស់មកខាងព្រះវិហារវិញ។ អ៊ីចឹងខ្ញុំនៅកំពត ខ្ញុំនៅបានមិនដល់មួយឆ្នាំទេ យ៉ាងយូរប្រាំខែចុះ ហើយផ្លាស់ពីៗកំពតហ្នឹងទៅកោះកុង ខ្ញុំនៅបីឆ្នាំប៉ុណ្ណឹង។ នៅអត់បានយូរទេនៅកំពត។ ខ្ញុំជម្រាបប៉ុណ្ណឹង ឆ្លើយប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមចូលនិយាយអំពីការងាររបស់លោកនៅកោះកុង។ លោកបានក្លាយទៅជាអនុបញ្ជាកងពលលេខ១ ហើយកងពលលេខ១នេះគឺចំណុះឲ្យភូមិភាគបស្ចិម ដែលគ្របដណ្តប់ទឹកដីកោះកុងផង តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៣:៥៥:០៣]

**ស៖** តើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថា កងពលលេខ១ គឺជាកងទ័ពជើងគោករបស់ភូមិភាគបស្ចិម?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយតើត្រឹមត្រូវដែរទេ ដែលថាកងពលលេខ១ គឺរាយការណ៍ទៅឲ្យ ជូ ជេត មេភូមិភាគបស្ចិម ហៅ តាស៊ី? ហើយ តាសឹង គឺជាមេបញ្ជាការកងពលលេខ១ ត្រឹមត្រូវទេ? សូមទោស តាសឿង។

**ឆ៖** តាសឿង។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនៅកោះកុង ខ្ញុំទើបឡើងអនុកងពលនៅកោះកុងដែលបាននៅបែកគ្នា តែខ្ញុំអត់ដែលរាយការណ៍ឲ្យទៅខាង តាស៊ី ទេ ខ្ញុំរាយការណ៍ទៅឲ្យតែខាង តាសឿង តែប៉ុណ្ណោះ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែថាតើ តាសឿង ជាមេបញ្ជាកងពលលេខ១ មែនទេ?

**ឆ៖** មែន។

**ស៖** ខ្ញុំជឿថា នៅកោះកុងក៏មានកងទ័ពឈរជើងនៅទីនោះ ដែលជាកងទ័ពមិនមែនចំណុះឲ្យកងពលលេខ១ សម្រាប់ភូមិភាគបស្ចិមទេ ប៉ុន្តែចំណុះឲ្យកងពលលេខ១៦៤ទៅវិញ គឺជាកងពលចំណុះឲ្យមជ្ឈិម ឬក៏ជាកងពលជើងទឹក។ តើអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** កងពលលេខ១ ដែលនៅប្រចាំនៅកោះកុង មិនមែនជាចំណុះឲ្យកងជើងទឹកនៅខាងកំពង់សោមទេ។ កងពលលេខ១ហ្នឹងជាកងភូមិភាគរបស់បស្ចិម ហើយការគ្រប់គ្រងដោយខាងភូមិភាគ ដូច្នេះអត់មានត្រូវចំណុះទៅខាងកងពលនៅកំពង់សោមទេ។ អាហ្នឹងជា ការរាយការណ៍ ក៏អត់មានរាយទៅខាងកងពលកំពង់សោមដែរ។ ដូច្នេះរាយមកតែខាងភូមិភាគទាំងអស់។

**ស៖** ប្រហែលជាខ្ញុំយល់មិនទាន់ច្បាស់នៅឡើយទេ។ ខ្ញុំសួរឲ្យលោកបញ្ជាក់ ថាតើកងពលទាំងពីរហ្នឹងកើតឡើងនៅពេលប្រហាក់ប្រហែលគ្នា ឬក៏យ៉ាងណា? កងពលទាំងពីរហ្នឹង ឈរជើងទាំងនៅ

កោះកុងដូចគ្នា ឬក៏មានតែកងពលណាមួយទេដែលឈរជើងនៅកោះកុង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត ខ្ញុំមិនច្បាស់ត្រង់កងពល យ៉ាងម៉េច ខ្ញុំស្តាប់សំណួរអត់បាន។

[១៣:៥៩:២២]

**ស៖** ខ្ញុំសូមទោសលោកដែលសួរទៅមិនបានច្បាស់។ ចំណុចដែលខ្ញុំចង់សួរ គឺថាកងពលលេខ ១៦៤ ជាកងពលមជ្ឈិម កើតឡើងនៅពេលប្រហាក់ប្រហែលគ្នាទៅនឹងកងពលលេខ១របស់ភូមិភាគបស្ចិម តើត្រឹមត្រូវដែរទេ?

**ឆ៖** អត់ទេ កងពល១៦៤ គេកើតដោយរបស់គេផ្សេងពីមុនមកតើ! កងពលលេខ១ ក៏កើតផ្សេងពីគ្នាដែរ។ ដូច្នេះកងពល៦៤កើតផ្សេងពីគ្នា កងពលលេខ១ក៏កើតផ្សេងពីគ្នាដែរ ក៏ប៉ុន្តែគេនៅខាងកំពង់សោម ខាងពលលេខ១នៅខាងកោះកុង។ ដូច្នេះ អត់មានចម្រុះគ្នាទេ ពីមុនអត់មានចម្រុះគ្នា តាំងពីដើមមកអត់មានចម្រុះគ្នា។

**ស៖** ប្រហែលជាមានបញ្ហាដោយការបកប្រែ ប៉ុន្តែខ្ញុំបន្តទៅមុខទៀតចុះ។ តើត្រឹមត្រូវដែរទេដែលថា កងពលណាមួយ -- តើមានការពលណាមួយក្នុងចំណោមកងពលទាំងពីរ កងពលលេខ១ កងពលលេខ១៦៤ គឺថាមានអំណាចស្មើៗគ្នាទេ ឬក៏កងពលណាមួយមានឥទ្ធិពល មានអំណាចជាង?

**ឆ៖** បាទ សូមបញ្ជាក់ដែរ បើថាកងពល៦៤ហ្នឹង គេមានអំណាចជាងនឹងកងពលភូមិភាគ។

**ស៖** ខ្ញុំសូមអានជូនលោកស្តាប់នូវអ្វីដែលលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេត គឺឯកសារ E319/23.3.30 សំណួរ-ចម្លើយលេខ១៧៖ "រវាងកងទ័ពជើងទឹក ហើយនិងកងទ័ពបស្ចិម មិនមានកងពលមួយណាមានអំណាច មានឥទ្ធិពលជាងគ្នានោះទេ។ កងពលលេខ១ ជាកងពលជើងគោករបស់បស្ចិមការពារព្រំដែននៅខ្សែបន្ទាត់ព្រំដែនខាងលិច។" ដូច្នេះលោកនិយាយថាកងពលទាំងពីរនេះ គឺថាមានរចនាសម្ព័ន្ធ ហើយមិនមានកងពលណាមានអំណាចជាងកងពលណាទេ។ ពេលលោកឆ្លើយពេលនោះត្រឹមត្រូវ?

[១៤:០២:០៥]

**ឆ៖** បាទ។

**ស៖** ចុះអំពីការបញ្ជាវិញ ការបញ្ជាដែលចេញមកពីភូមិភាគនិរតី បញ្ជាមកកងពល -- (សូមទោស) បស្ចិមបញ្ជាមកកងពលលេខ១ និងការបញ្ជាមកកងពលលេខ១៦៤។ តើកងពលទាំងពីរទទួលការបញ្ជាដូចគ្នាដែរឬទេ គឺកងពល១៦៤ និងកងពលលេខ១ហ្នឹងសហការគ្នា ហើយជាទូទៅទទួលបញ្ជា

ពីថ្នាក់លើកមកដូចៗគ្នាដែរទេ?

**ឆ៖** បាទ មានដូចគ្នាដែរ។

**ស៖** តើនៅពេលដែលលោកធ្វើការនៅលើដែនសមុទ្រ តើលោកបានចែករំលែកព័ត៌មានរវាងគ្នានិងគ្នាដែរឬទេ? ឬក៏ជជែកគ្នាជាមុន ឬក៏ឲ្យផ្តល់ដំណឹងទៅពីកងពលមួយទៅកងពលមួយទៀតទេ ដើម្បីនឹងធ្វើការ ឬចាត់កិច្ចការអ្វីមួយនៅលើដែនសមុទ្រនោះ?

**ឆ៖** បាទ ខ្ញុំមិនបានទាក់ទងខាងកងពល៦៤ទេ ក៏ប៉ុន្តែមុននឹងរៀបចំដាក់ ដើម្បីការពារតាមដែនទឹក ដែនគោកហ្នឹង ហើយនិងដែនអាកាសហ្នឹង ពីព្រោះអីដែលបានធ្វើនោះ គឺខាងប្រធានកងពលគាត់ជួបគ្នាៗ ហើយគាត់បញ្ជាក់នៅក្នុងផែនទីរួចស្រេចអស់ហើយ បានកងពល -- ប្រធានកងពលហ្នឹងមកប្រាប់តាមខ្ញុំ ហើយខ្ញុំក៏ប្រាប់តាមវរសេនាធំអីចឹងទៅ។ ដូច្នេះ គេលេខាកងពល ឬក៏ប្រធានកងពលហ្នឹងគេជួបគ្នារួចអស់ហើយ ខ្ញុំមិនបានជួបទេ។ ដូច្នេះគ្រាន់តែជួបហើយបានគេមកបញ្ជាក់តាមផ្នែកកងពលនីមួយៗតាមវរសេនាធំនីមួយៗ ដើម្បីឲ្យដឹងច្បាស់។ សូមបញ្ជាក់ប៉ុណ្ណេះ។

[១៤:០៤:៤៦]

**ស៖** ប្រហែលជាលោកចង់មានន័យនិយាយពាក្យដដែលហើយ។ ខ្ញុំឲ្យប្រាកដអ្វីដែលលោកនិយាយក្នុង E3/19/23.3.32 ជាកំណត់ហេតុស្តាប់ចម្លើយលោក គឺសំណួរនិងចម្លើយ៤ និង៥ "សំណួរ៖ តើមានការផ្លាស់ប្តូរព័ត៌មានរវាងកងទ័ពជើងទឹក ហើយនិងកងពលលេខ១ ទាក់ទងអំពីព័ត៌មានក្នុងការចាប់អ្នកទូកនេសាទថៃ និងទូកវៀតណាមឬយ៉ាងណាទេ? លោកឆ្លើយថា៖ បាទ ការចែករំលែកព័ត៌មានគ្នា គឺសំខាន់ណាស់សម្រាប់ប្រតិបត្តិការរបស់យើងក្នុងការចាប់នេសាទ ថៃ វៀតណាម។ សំណួរ៖ ប្រសិនបើកងទ័ពជើងទឹក និងកងពលលេខ១ មិនបានសហការ និងចែកព័ត៌មានឲ្យគ្នាល្អទេ តើមានអ្វីកើតឡើង? លោកបានឆ្លើយថា៖ ប្រសិនបើយើងមិនមានការបែងចែករំលែកព័ត៌មាននិងសហការបានល្អទេ វាបង្ហាញថាយើងមានទំនាស់ជាមួយគ្នា។ ហើយក្នុងសភាពការណ៍បែបនេះ វាគឺផ្តល់ឱកាសឲ្យទូកទាំងឡាយចូលមកដែនទឹករបស់យើងតាមចិត្ត។" ចប់សេចក្តីដកស្រង់។ លោកសាក្សីចាំទេ ថាលោកបានឆ្លើយបែបនេះ តើនេះជាចម្លើយត្រឹមត្រូវរបស់លោកដែរទេ?

**ឆ៖** បាទ ខ្ញុំ -- ត្រឹមត្រូវហើយ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅដល់សភាពការណ៍មួយដែលកងពលរបស់លោក ឬក៏កងពល១៦៤ បានឃើញទូកនេសាទ ឬក៏ទូកជនភៀសខ្លួនដែលគេដឹកជនភៀសខ្លួន ឬអ្នកនេសាទ។ ហើយនៅ

ក្នុងខែតុលា ឆ្នាំ២០១២ នៅសាលសវនាការនេះ គេសួរលោក ហើយលោកបានឆ្លើយរួចហើយ តើនៅចាំទេ នៅពេលដែលធ្វើការនៅពេលនោះ ពេលដែលលោកបានឃើញកាណូតអ្នកនេសាទថៃ ឬក៏វៀត-ណាមចូលមក តើវិធានការដែលចាប់ពេលនោះជាវិធានការអ្វីខ្លះ?

**ឆ៖** បាទ ក្នុងពេលដែលយើងការពារដើងទឹកដើម្បីកុំឲ្យគេមកចាប់ត្រី ឬក៏ធ្វើប្រតិបត្តិអីផ្សេងៗ យើងបានសហការគ្នាដូចជាកងពល៦៤ អាចនឹងយកកម្លាំងមក យកកប៉ាល់មកដាក់នៅកងពលលេខ១ក៏មាន។ ហើយកងពលលេខ១ ជួយថែរក្សា ជួយមើលការខុសត្រូវគ្នាក្នុងកិច្ចការសហការគ្នាអ៊ីចឹង។ តែដល់ពេលកាណូតថៃ ឬក៏កាណូតយួនមកពីណាមក ក៏យើងសហការគ្នាមានវិធានការចាប់ដែរ។ កន្លងមកគឺបានធ្វើអ៊ីចឹងឯង អស់។

[១៤:០៨:១២]

**ស៖** ខ្ញុំសូមអានទូវអ្វីដែលលោកបានឆ្លើយពីមុន ថាតើនេះជាចម្លើយត្រឹមត្រូវរបស់លោកដែរឬឬទេ? មានសំណួរគេសួរប្រធានបទជាក់លាក់នេះ ឯកសារE3/319.23.3.32 សំណួរចម្លើយលេខ៨ លោកប្រធាន។ "ប្រសិនបើកាណូត ឬក៏ស្កិតមកចូលដែនទឹកគឺថា អាចនឹង១០ ឬក៏១២ គីឡូម៉ែត្រពីឆ្នេរយើងត្រូវឆែកឆេរហើយចាប់ទូកនោះ។ តែចាប់ពី ៣០ទៅ ៧០ គីឡូម៉ែត្រទឹក យើងត្រូវតែមើល ហើយនិងទៅដេញដោយកប៉ាល់ចម្បាំង។ ទាំងនេះ គឺជាគោលនយោបាយទូទៅ។ បាទ ហើយប្រសិនបើនាវាចម្បាំងសង្គ្រាមវិញ គឺថាយើងត្រូវតែចាត់វិធានការខុសពីនេះ។ លោកសាក្សី តើលោកបានឆ្លើយបែបនេះទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ បានប្រាប់គាត់ដែរតើ។

**ស៖** នៅពេលដែលកប៉ាល់ចូលមកក្នុងដែនទឹករបស់លោក តើលោកនៅក្នុងកងពលទី១ ហើយនិងកងល្បាតរបស់លោកហ្នឹង គឺតែងតែចាត់ការដូចម្ដេច ហើយមានអ្វីកើតឡើងចំពោះកប៉ាល់ដែលចូលមកដែនទឹកនោះ?

**ឆ៖** បាទ មុនពេលដែលកប៉ាល់ចូលមកដែនទឹកយើង យើងនឹងប្រាប់ឲ្យកប៉ាល់យើងទៅមើលៗ ដើម្បីដឹងថា កប៉ាល់តូច ឬកប៉ាល់ធំ ឬក៏កាណូតចាប់ត្រី។ តែបើកាលណាទៅមើលទៅ បើគេរត់ទៅ ក៏គេទៅចុះ។ ប៉ុន្តែបើសិនណាគេៗបាញ់តបតយើង យើងតបតវិញដែរ។ មានប៉ុណ្ណឹងឯង។

**ស៖** ហើយបើពិនិត្យមើលទៅឃើញថា នៅលើកាណូតនោះ មានជនជាតិ -- ជនភៀសខ្លួនវៀតណាមវិញ។ តើចំណាត់ការយ៉ាងដូចម្ដេច?

**ឆ៖** បាទ ការកាណូត បើកាណូតវៀតណាម កន្លងមកវាមកយូរៗម្ដងដែរ ក៏ប៉ុន្តែពេលខ្លះដែលគេវង្វេងមក ព្រោះគេចូលមកក្នុងដែនទឹកយើង ដើម្បីគេឡើងទៅប្រទេសថៃ អ៊ីចឹងទៅ ពេលណាដែលយើងដឹង យើងចាប់។ ចាប់ហើយយើង ចាប់បានហើយយើងបញ្ជូនទៅតាមៗថ្នាក់ តាមអង្គភាពដែលទទួលខុសត្រូវអ៊ីចឹងទៅ ហើយយើងរាយការណ៍ទៅតាម ប៉ុន្តែចាប់បានកន្លងទៅ គឺចាប់បានតែកាណូតមួយគ្រឿងអ៊ីចឹងទៅ យើងបញ្ជូនទៅតាមខាងកំពង់សោម ខាងកងពល៦៤អ៊ីចឹងទៅ ព្រោះអីគេនៅប្រចាំការជាមួយយើងដែរ។ ហើយបើយើងបញ្ជូនទៅខាងកងពល៦៤ទៅ អាហ្នឹងគឺថា គេយកទៅខាងកំពង់សោមអ៊ីចឹងទៅ។ អាហ្នឹងគឺមាន។ កន្លងមក មានចាប់អ៊ីចឹងដែរ ក្នុងពេលដែលមានយើញរត់ចេញពីៗខាងស្រុកយួនមក។ សូមមានប៉ុណ្ណឹង។

[១៤:១២:១២]

**ស៖** ខ្ញុំនឹងត្រឡប់ទៅចំណុចនេះឡើងវិញ។ ខ្ញុំនឹងអានចំណុចមួយផ្សេងទៀត ដែលនិយាយពីមេបញ្ជាការកងពល១៦៤ ឆ្លើយប្រាប់ទៅអ្នកស៊ើបអង្កេត ឯកសារ E3/19/23.3.12។ នៅក្នុងសំណួរចម្លើយ៧៥ មេបញ្ជាការកងពល១៦៤រូបនោះក៏បានឆ្លើយថា៖ "នៅនាយពីការងារនៃកងពល១៦៤ គឺយើងត្រូវរាយការណ៍អំពីកាណូតវៀតណាម ដែលចូលមកដែនទឹកកម្ពុជា។ សុន សេន បាននិយាយថា បើវៀតណាមទាំងនោះជាជនភៀសខ្លួនទៅប្រទេសថៃ យើងមិនត្រូវចាប់ខ្លួនគេទេ ហើយឲ្យពួកគេធ្វើដំណើរទៅចុះ។" ចប់សេចក្ដីដកស្រង់។

តើលោកស្ដាប់ទៅ ព័ត៌មាននេះជាខ្លឹមសារដែលលោកធ្លាប់បានឮ ជាគោលនយោបាយពេលនោះដែរឬទេ លោកសាក្សី?

**ឆ៖** ខ្ញុំបានឮដែរ ពីព្រោះអីគាត់ឮថា ជនជាតិថៃក៏អ៊ីចឹងដែរ។ បើសិនជាយើងចាប់បាន ក៏យើងបញ្ជូនទៅស្រុកថៃវិញដែរ។ តែបើជនជាតិវៀតណាម ក៏យើងបញ្ជូនទៅតាមផ្លូវនយោបាយហ្នឹងដែរ។ តែខ្ញុំចាប់បានកន្លងទៅ ខ្ញុំបញ្ជូនទៅតាមៗថ្នាក់ដឹកនាំរបស់ខ្ញុំទៅ ថ្នាក់ដឹកនាំ បញ្ជូនទៅណាទៀតហ្នឹង ខ្ញុំមិនបានដឹងទេ ពីព្រោះអីការងារទាក់ទងការងារអីជាមួយនឹងបរទេស ខ្ញុំមិនមានមុខការងារហ្នឹង គ្រាន់តែបញ្ជូនទៅតាមថ្នាក់ដឹកនាំ ឬតាមថ្នាក់កងពលអ៊ីចឹងទៅ។ សូមអស់។

**ស៖** នៅពេលដែលទីបញ្ជាការកងពលនៅកោះកុង តើនៅពេលដែលគេបញ្ជាក់ច្បាស់ថា អ្នកទាំងអស់នោះជាជនភៀសខ្លួនវៀតណាមវិញ គឺត្រូវតែសម្រេចថា បើគេចង់ទៅទិសដៅណាឲ្យគេទៅគ្រប់ករណី ឬដូចម្ដេច?

**ឆ៖** បាទ គេចង់ទៅខាងណា ក៏ឲ្យគេទៅ អាហ្នឹងគេប្រាប់តាមដំណឹង ហើយតាមកងពល ប្រាប់ខ្ញុំអ៊ីចឹងដែរ។ គេឲ្យទៅតាមតែ សម្រួលតាមដំណើររបស់គេ។ សូមអស់។

[១៤:១៥:០០]

**ស៖** តើត្រឹមត្រូវដែរឬទេនៅពេលដែលគេពិនិត្យឃើញថា អ្នកទាំងនោះពិតជាជនភៀសខ្លួន ហើយពួកគេត្រូវបានដោះលែង ហើយឲ្យបន្តដំណើរ? ហើយបើសិនជាអ្នកនោះមិនមែនជាជនភៀសខ្លួនទេ អគ្គបញ្ជាការកងពលត្រូវធ្វើការសម្រេចវិធានការបន្ទាប់ទៀត។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រង់ហ្នឹងខ្ញុំអត់បានដឹងទេ មិនដឹងអគ្គបញ្ជាការសម្រេចយ៉ាងម៉េច អាហ្នឹងខ្ញុំអត់ដឹង។

**ស៖** ខ្ញុំនឹងអានចម្លើយរបស់មេបញ្ជាការកងពល១៦៤ អ្នកអង្កេតសួរទៅគាត់អំពីៗខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅពាក់ព័ន្ធទៅនឹងអ្នកនេសាទវៀតណាម។ សំណួរ១៧០ លោកនិយាយថា៖ “មានខ្មាំងពីរប្រភេទ គឺខ្មាំងខាងផ្ទៃក្នុងនិងខ្មាំងខាងក្រៅ។ បើលោកគិតថា អ្នកនេសាទវៀតណាមណាមួយត្រូវបានគេចាត់ទុកថាជាខ្មាំងខាងក្រៅ ហើយត្រូវគេយកទៅសម្លាប់ដែរឬទេ? ខ្ញុំមិនគិតដូច្នោះទេ ខ្មាំងខាងក្រៅគឺសំដៅទៅលើយោធាវៀតណាមនៅតាមព្រំដែន។ ចំពោះករណីចាប់ទូកនេសាទវៀតណាមនោះ អ្នកនេសាទវៀតណាម តាមដែលខ្ញុំដឹងមិនត្រូវបានចាត់ទុកជាខ្មាំងខាងក្រៅទេ ក៏ប៉ុន្តែពួកគេបានរំលោភលើដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ។” លោកសាក្សីអាចនឹងផ្តល់មតិប្រតិកម្មទៅនឹងអ្វី ដែលសាក្សីរូបនេះនិយាយពាក់ព័ន្ធទៅនឹងអ្នកនេសាទវៀតណាមដែរឬទេ?

**ឆ៖** ខ្ញុំមានអីពាក់ព័ន្ធទេជាមួយនឹងខាងនេសាទរបស់វៀតណាម ព្រោះអីនេសាទរបស់វៀតណាម អត់ដែលមកកន្លែងខ្ញុំទេ តែកន្លែងគេដទៃអាហ្នឹងខ្ញុំមិនដឹងដែរ។

[១៤:១៧:២០]

**ស៖** បាទ ខ្ញុំយល់ហើយពីព្រោះករណីហ្នឹងវាយូរហើយ។ ចុះអ្វីដែលទាក់ទងទៅនឹងជនភៀសខ្លួនវៀតណាម អ្នកដែលរត់គេចពីប្រទេសវៀតណាម។ តើកងពលរបស់លោកចាត់ទុកពួកគេថាជាខ្មាំងខាងក្រៅ ឬក៏ពាក្យថាខ្មាំងខាងក្រៅនេះមានន័យថា សំដៅតែលើទាហានវៀតណាមដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រទេ?

**ឆ៖** បាទ រឿងជនភៀសខ្លួនរបស់វៀតណាមដែលមក ខ្ញុំមិនមែនមិនចាត់ទុកជាខ្មាំងទេ ខ្ញុំចាត់ទុកជាប្រជាជនដែលខ្លាចគ្រោះថ្នាក់នៅក្នុងសង្គ្រាម គេចេះតែរត់ ដូចជាខ្ញុំរត់អ៊ីចឹងដែរ។ ខ្ញុំនឹកគិតឃើញអ៊ីចឹង ព្រោះអីរបបមួយទៅរបបមួយគេចង់រស់នៅកន្លែងណា ខ្ញុំគិតឃើញថា ខ្លួនខ្ញុំដែលចាប់មក ចាប់

បានខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំអ៊ីចឹងទៅ ហើយថ្នាក់ដឹកនាំក៏ដោះស្រាយតាមបែបណា ក៏ស្រេចតែគាត់ទៅ ប៉ុន្តែការដែលគាត់រត់ៗមកអ៊ីចឹងមែន។ ហើយខ្ញុំអត់ចាត់ទុកគេជាខ្មាំងទេ ពីព្រោះអីសុទ្ធតែប្រជាជន ហើយកូនតូចអ៊ីចឹងទៅកាត់សមុទ្រ កាត់ព្រែកអ៊ីចឹង លំបាកអ៊ីចឹងដែរ។ ដូច្នេះខ្ញុំបញ្ជូនទៅតាមហ្នឹង។ ខ្ញុំមិនមែនចាត់ទុកជាខ្មាំងទេ។ បើសិនជាខ្មាំងក៏ត្រូវគិតថា ដោយថាវិញ គឺថាវាបាញ់យើងហើយបាញ់យើង បាញ់គ្នាទៅវិញទៅមកហើយ អ៊ីចឹងខ្ញុំអត់ចាត់ទុកជាខ្មាំងទេ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះឯង។

[១៤:១៩:០៤]

**ស៖** សំណួរចុងក្រោយទាក់ទងទៅនឹងជនភៀសខ្លួនវៀតណាម។ លោកប្រធាន ខ្ញុំយោងទៅរកសេចក្ដីដកស្រង់ពីសៀវភៅរបស់ ហ្វីលីព ស្បូត គឺ E3/9 ទំព័រ៣៧៩ អង់គ្លេស ERN 00396587 ហើយមានតែភាសាបារាំងទេ 00639951។ នេះគឺអ្នកសារព័ត៌មានជនជាតិអង់គ្លេសលោកសាក្សី គាត់និយាយអំពីជនភៀសខ្លួនតាមទូកមកពីវៀតណាម ដែលភាគច្រើនអ្នកទាំងអស់នោះគឺមានប្រវត្តិគ្រួសារជាជាតិចិន។ ហើយគាត់និយាយថា "បានជាមួយភាគបួន មួយលាន នៃជនជាតិទាំងអស់នោះ គឺថាត្រូវគេចពី ប៉ូលិសក៏អាចហាក់នឹងធ្វើដំណើរដូចជាដាក់ខ្លួនក្នុងមឈូសទៅ ចេញពីប្រទេស រត់ទៅបរទេស។ មួយចំនួនត្រូវបានគេប្លន់សម្លាប់ដោយចោរសមុទ្រ រឺឯ -- ដោយអំពើឃោរឃៅ ហើយមានចំនួនតិចតួចដែលនៅរស់។ ហើយអ្នកនិពន្ធនេះនិយាយអំពីចោរសមុទ្រ តើលោកធ្លាប់ឮ ឬក៏បានឆ្លងកាត់អំពីការកាប់សម្លាប់ដែលថាជនជាតិភៀសខ្លួនទាំងអស់នោះត្រូវចោរសមុទ្រថៃ ហើយចោរសមុទ្រម៉ាឡេបានកាប់សម្លាប់ពួកគេ តើធ្លាប់ លោកធ្លាប់ឮបែបនេះទេកាលនោះ?

**ឆ៖** ខ្ញុំអត់បានឮទេ។ កាលណោះអត់បានដឹងដែរ។

**ស៖** សំណួរចុងក្រោយប្រធានបទនេះ គឺថាខ្ញុំសួរអំពីអ្នកនេសាទនៅក្នុងដែនសមុទ្រ។ ចម្លើយមួយរបស់លោក លោកនិយាយថា គឺថាទូកនេសាទថៃត្រូវបានកប៉ាល់ចម្បាំង*អេស្កក* ឬក៏អមទៅច្រាំង ឬក៏ទៅដែនដីគោក។ ឥឡូវសូមលោកពន្យល់លម្អិតជាងនោះបន្តិច ជូនតុលាការផងបានទេ?

[១៤:២១:៤០]

**ឆ៖** កប៉ាល់ កាណូតភាគច្រើន គឺកាណូតថៃ អង្កាល់នុ៎ងគឺគេចាប់ត្រីក្នុងដែនសមុទ្រយើងមែន ហើយមិនទាន់ធ្វើអីថា បាញ់ ឬក៏ឡើងទៅវ៉ៃ ទៅបាញ់អីទេ ប៉ុន្តែកាលនោះយើងមិនសូវមានឧបករណ៍សម្ភារៈសម្រាប់ការពារហ្នឹង គេចេះតែចូលចាប់ត្រីទាំងយប់ទាំងថ្ងៃ អត់មានសម្រាកទេ។ ហើយព្រមជាមួយនេះ មានកប៉ាល់យោធាដែលអម ជួយការពារទូកនេសាទហ្នឹងផង។ ហើយដល់ពេលនោះ ចេះតែ

ចូល មុនដំបូងចូលតិចល្មមទេ ក៏ប៉ុន្តែដល់យើងអត់ធ្វើអីទៅ ចេះតែចូលច្រើនៗមក បន្តបន្ទាប់ទាំងយប់ទាំងថ្ងៃអ៊ីចឹងទៅ យើងក៏បានយកកប៉ាល់យើងខ្លះដើម្បីទៅបៀត ដូចថាទៅបង្ហាញ ទៅអីអ៊ីចឹងទៅ ក៏អត់ទាន់បានធ្វើអីប៉ះពាល់គ្នាទេ ហើយក៏គេទៅវិញខ្លះទៅ។ ដល់រាល់តែសប្តាហ៍ចេះតែមកបន្តបន្ទាប់ទៀត ក្រោយទៀតយើងក៏កំណត់ថា យើងរាយការណ៍។ យើងអត់មានចាប់អី ធ្វើអីឲ្យមានការប៉ះពាល់ទេ ប៉ុន្តែយើងរាយការណ៍ទៅតាមថ្នាក់កងពលគ្នានីមួយៗដើម្បីឲ្យដឹងថា ថ្ងៃនេះត្រូវកាណូតចូលចាប់ត្រីយើងប៉ុណ្ណេះគ្រឿង ១០អ៊ីចឹងទៅ ២០គ្រឿអីទៅ ដោយមានកប៉ាល់អមការពារអ៊ីចឹងទៅ យើងបានរាយ-ការណ៍ម្តងពីរដងអ៊ីចឹងទៅ។ ដល់អ៊ីចឹងបទបញ្ជាថាទៅ យើងមើលប្រសិនណាតែវាចូលជ្រៅអ៊ីចឹងទៅ យើងនឹងទៅមើលឲ្យច្បាស់ ពីព្រោះអីកាលយើងនៅហ្នឹងអត់មានទាក់ទងនិយាយបានទេ ពីព្រោះថៃ និងយើង យើងអត់ទាន់បានជួបគ្នានិយាយយ៉ាងម៉េចផងទេ។ អ៊ីចឹងយើងប្រើតែរបៀបកម្លាំងហិង្សា អាវុធអ៊ីចឹងទៅ។ ដល់ពេលថ្ងៃក្រោយទៀត លើកសប្តាហ៍ទី៣ទៀត ចេះតែមកទៀត យើងទៅបណ្តោយ។ ទៅៗ ដល់ទៅគេបាញ់កប៉ាល់យើងមក គេបាញ់កប៉ាល់យកមក យើងក៏ដកថយបន្តិចបន្តួចមក។ ក្រោយមកក៏បាន តមកក៏មានបាញ់គ្នាជាបន្តបន្ទាប់ជាមួយនឹងកប៉ាល់ថៃហ្នឹងទៅ។ ដល់យើង -- ដល់គេបាញ់ទៅ យើងក៏បាញ់ត តបន្តបន្ទាប់ទៅ ដល់ពេលលើកទី៣ គេយកយន្តហោះមកបាញ់។ បាញ់កន្លែងព្រំដែនព្រំប្រទល់ដីគោក និងដីទឹកហ្នឹង បាញ់ពីលើអាកាសមក យើងក៏ត្រូវរបួស ពួកយើងខ្លះ គេទម្លាក់គ្រាប់បែកមកក៏ត្រូវ គ្រោះថ្នាក់របួសខ្លះទៅ កើតជារឿងបានទាស់គ្នាទៅ ក៏ថៃគេយកកប៉ាល់មកបីគ្រឿងថែមទៀត បាញ់រះពីតាមទឹក តាមព្រំនឹងមក កើតមានរឿង ក៏ប្រយុទ្ធគ្នារវាងមួយអាទិត្យតទៀតអ៊ីចឹងទៀត។ នេះដែលឃើញថា យើងអត់ចេះ យើងអត់ធ្វើទៅតាមចិត្តយើងដែលនេះទេ ព្រោះយើងបានរាយការណ៍ទៅតាមបញ្ជាការរៀងៗខ្លួន ហើយខាងលើបានសម្រេចឲ្យដោះស្រាយអ៊ីចឹង ប៉ុន្តែដល់ពេលនេះទៅ វាទៅជាមានកើតបានវ៉ៃគ្នា បានយូរមួយអាទិត្យអ៊ីចឹងទៅ។ មានការគ្រោះថ្នាក់អ៊ីចឹងទៅ តែយើងអត់មានបាញ់ ក្រោយមកទៀតមកយើងខឹងពេកទៅក៏យើងទៅវ៉ៃតាមជាយដែនថៃមទៀត ដើម្បី ព្រោះអីវាគ្រោះថ្នាក់យើងច្រើនដែរ។ ហ្នឹងដែលកើតមានរឿងហេតុហ្នឹង បានក្រោយមកក៏យើងឈប់មក ដកថយរៀងខ្លួនមក មកកន្លែងវិញ នេះដែលជារឿងបន្តបន្ទាប់។ ហើយក្រោយមកក៏សភាពការណ៍ដែលអូសត្រី ឬចាប់ត្រីទាំងយប់ទាំងថ្ងៃហ្នឹង ក៏មានការផ្អាកបាត់បន្តបន្ទាប់មក។ ហ្នឹងសូមអស់បញ្ជាក់ហេតុការណ៍ប៉ុណ្ណឹង។

[១៤:២៦:១៨]

E1/386.1/Old-1

**សៈ** តើកងពលរបស់លោក តើធ្លាប់បានប៉ះទង្គិចជាមួយកងកប៉ាល់សង្គ្រាមវៀតណាមដែរឬទេ ដែលជានៅតំបន់កោះកុងទេ ឬក៏ជាតំបន់ដែលឆ្ងាយមិនធ្លាប់បានពើបប្រទះគ្នាទេ?

**ធៈ** ខ្ញុំវាងកប៉ាល់វៀតណាម ខ្ញុំអត់ដែលប៉ះទេ ប៉ុន្តែគេខាងកោះវៃ កោះអីគេប៉ះមិនដឹង ប៉ុន្តែខ្ញុំខាងនេះអត់មានប៉ះទេជាមួយនឹងកប៉ាល់វៀតណាម។ បើកប៉ាល់ថៃមានការប៉ះ ដូចខ្ញុំបានបញ្ជាក់អំមិញអីចឹង។

**សៈ** អរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅរកប្រធានបទមួយខុសស្រឡះពីអ្វីដែលយើងទើបតែបញ្ចប់នេះ។ សំណួរនេះ បាន -- ត្រូវបានសួរទៅលោករួចមកហើយ ប៉ុន្តែខ្ញុំសួរបំភ្លឺឡើងវិញ គឺនិយាយអំពីការចូលរួមសន្និបាតៗភូមិភាគបស្ចិមនៅថ្ងៃទី២៥ កក្កដា ១៩៧៧ ដែលប្រជុំនៅតំបន់ចម្ការដូង កំពង់ស្ពឺ ច្បារមន។ តើលោកចាំដែរឬទេ នៅក្នុងសន្និបាតភូមិភាគបស្ចិមនៅកំពង់ស្ពឺ គឺថានៅកន្លែងមួយឈ្មោះថា ចម្ការដូង?

**ធៈ** ចាំ ប៉ុន្តែខ្ញុំភ្លេចថ្ងៃខែ ខ្ញុំមិនចាំទេ។ ចាំថាឆ្នាំ៧២-៧៣ ហ្នឹង។

**សៈ** ប្រហែលជាការបកប្រែខុស ហើយខ្ញុំនិយាយពីនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ ជាសន្និបាតភូមិភាគបស្ចិម?

**ធៈ** បាទ មានៗឆ្នាំ៧៧ -- ៧២-៧៣។ មានតែឆ្នាំ៧២ អេមិនមែនឆ្នាំ៧២ទេ គឺ៧៧ហ្នឹង។ ខ្ញុំភ្លេចឆ្នាំ ខ្ញុំមិនចាំ។

**សៈ** មិនអ្វីទេ លោកសាក្សី ខ្ញុំនឹងរំឭកការចងចាំរបស់លោក។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីគឺថា E3/80 សំណួរ-ចម្លើយ១៣ លោកនិយាយដូចខាងក្រោមនេះ (សូមទោស) គឺសំណួរ-ចម្លើយ១៤ទេ។ “តើលោកបានចូលមហាសន្និបាតនៅភូមិភាគបស្ចិមនៅថ្ងៃទី២៥ ខែ៧ ឆ្នាំ១៩៧៧ តើលោកចូលរួមដែរឬទេ? តើមានសមាសភាពថ្នាក់ណាខ្លះចូលរួមក្នុងសន្និបាតនោះ? ចម្លើយ៖ ខ្ញុំបានចូលរួមសន្និបាតភូមិភាគបស្ចិមនៅខេត្តកំពង់ស្ពឺ នៅចម្ការដូង ក្នុងស្រុកច្បារមន កាលពីឆ្នាំ១៩៧៧ តែមិនចាំខែច្បាស់ទេ។ អ្នកចូលរួមមានគណៈភូមិភាគ គណៈតំបន់ គណៈស្រុកគ្រប់ ស្រុក ប្រធាន អនុប្រធានកងពល ប្រធាន អនុប្រធានវរសេនាធំ និងភូមិភាគ -- ក្នុងភូមិភាគបស្ចិម។ ខ្ញុំអានសំណួរចម្លើយទី១៥ផងដែរ៖ “តើនៅពេលនោះ ថ្នាក់ដឹកនាំជាន់ខ្ពស់ខាងលើណាខ្លះដែលចូលរួមរួមក្នុងមហាសន្និបាតនោះ? លោកឆ្លើយថា៖ “នៅពេលនោះ មានតាប៉ាល់ តាស៊ី និងតាសឿង អ្នកទាំងបីជាគណៈភូមិភាគ។” ចប់ការដកស្រង់។ តើខ្ញុំអានប៉ុណ្ណោះរំឭកការចងចាំរបស់លោកបានដែរឬទេ លោកសាក្សី?

**ឆ៖** បាទ ចាំបាន។

**ស៖** បាទ អ៊ីចឹង គឺខ្ញុំតទៅទៀត គឺថានៅកន្លែងចម្ការដូងដែលលោកបាននិយាយនោះ តើចម្ការដូងហ្នឹងជារបស់ -- ជាចម្ការរបស់ នរោត្តម ច័ន្ទ រង្សី ឬក៏របស់អ្នកណា?

**ឆ៖** បាទ តាមអ្នកស្រុកនិយាយថា ចម្ការដូងទ្រង់ ច័ន្ទ រង្សី។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់ទៅរកឯកសារទង់បដិវត្តន៍។ លោកប្រធាន E3/193 អង់គ្លេស ERN 00399236, ខ្មែរ 00062965-66, បារាំង 00611840 និង 841។ នេះជាខ្លឹមសាររវែងរាយការណ៍អំពីការប្រជុំ បាទ បើខ្ញុំអានទាំងស្រុង គឺថាអាចនឹងធ្វើឲ្យលោកនឿយហត់ ប៉ុន្តែខ្ញុំអានសេចក្ដីដកស្រង់ខ្លី។ នៅលើទំព័រទាំងនេះគេបានបោះពុម្ពគឺថា នៅក្នុងមហាសន្និបាតនោះ ប្រធានបទនិយាយអំពីការរៀបចំទ័ពដើម្បីកម្ទេចខ្មាំង គឺសមាសភាពមិនល្អនៅក្នុងសហករណ៍ ហើយនិងខ្មាំងខាងក្រៅ។ ហើយបន្ទាប់ទៅខាងក្រោមនោះទៀត នៅក្នុងទំព័រដដែលនេះដែរ គឺនិយាយដូចខាងក្រោមនេះ ការវាយប្រហារនេះ គឺមិនចាប់ឲ្យបានទាំងអស់ ហើយយកមកដាក់ទោសទាំងអស់ទេ គឺដើម្បីប្រើកសិករក្រ និងកសិករកណ្ដាលដើម្បីត្រួតត្រាសហករណ៍ កាន់កាប់សហករណ៍។ ចប់សេចក្ដីដកស្រង់។ តើលោកសាក្សីនៅចាំថា អ្នកដែលនិយាយពីការកម្ទេច ឬការប្រយុទ្ធខ្មាំង ហ្នឹងគឺមិនត្រូវចាប់ឲ្យបានទាំងអស់ទេ គឺគ្រាន់តែ រកឲ្យឃើញក្នុងឋានៈហ្នឹងអ្នកណាត្រូវកាន់កាប់សហករណ៍ ឬមិនត្រូវសហករណ៍តែប៉ុណ្ណឹងទេ។

[១៤:៣៣:៥៧]

**ឆ៖** បាទ ខ្ញុំមិន -- ការដែលគេប្រជុំនោះ គឺប្រជុំរៀបចំអ៊ីចឹងហើយ ប៉ុន្តែគេមិននិយាយថាកសិករឲ្យមកគ្រប់គ្រង ឬក៏កសិករកណ្ដាល ឲ្យមកគ្រប់គ្រងទេ អ្នកណាដែលស្មោះត្រង់ៗ ក្នុងការដឹកនាំនោះក៏គេឲ្យគ្រប់គ្រងដែរ គេមិនមែនចាត់ទុកថាជាខ្មាំងទេ។ តែឲ្យតែអ្នកណាដែលស្មោះត្រង់ជាមួយនឹងប្រជាជន ថាមិនកេងមិនប្រវ័ញ្ច ឬក៏មិនឆក់កណ្ដៀតអីរបស់ប្រជាជន អាហ្នឹងក៏គេឲ្យកាន់កាប់ដែរ។ ឯចំពោះខ្មាំងសត្រូវនោះ គេចង់និយាយអំពីខ្មាំងសត្រូវដែលបង្កប់នោះ គេចង់និយាយពីឧបាយកលរបស់យួន ពីព្រោះអីកាលនោះ គឺយើងនៅទំនាស់ជាមួយនឹងយួន ហើយយួនក៏មានវិធានការដើម្បីវ៉ៃកម្ពុជានោះដែរ។ ដូច្នេះ គេរកតែខ្មាំងណាដែលបង្កប់នៅក្នុងជួរសហករណ៍ ឬក៏ក្នុងជួរកងទ័ព ឬក្នុងជួរណាដែលជាឧបាយកលរបស់ខ្មាំង។ គេចង់រកតែចំណុចហ្នឹងទេ។ ឯដទៃទៀតយើងមិនដឹងថា ខ្មាំងខាងក្រៅ គេចង់និយាយពីខ្មាំងដែលៗវាយឈ្លានពានមកពីក្រៅ ឯខ្មាំងខាងក្នុងគេចង់និយាយពីឧបាយកល ឬភ្នាក់ងាររបស់ខ្មាំងដែលវាបង្កប់នៅក្នុងរដ្ឋអំណាច ឬនៅក្នុងជួរយើង។ ហ្នឹង ខ្ញុំចង់បញ្ជាក់

ខ្លីប៉ុណ្ណឹង។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ លោកសាក្សី។ នៅក្នុងឯកសារទង់បដិវត្ត ខែសីហា ឆ្នាំ ១៩៧៧ គឺទំនងជានិយាយអំពិសន្និបាតរបស់កម្មាភិបាលភូមិភាគបស្ចិមទាំងអស់ មានៗចំណងជើងនៅទំព័រដំបូង គឺនិយាយថា បទឧទ្ទេសនាមអង្គការ -- តំណាងអង្គការបក្ស និយាយអំពីបញ្ហាការណែនាំមួយចំនួន និងក្នុងការកសាងពង្រឹងពង្រីកបក្សដឹកនាំក្នុងឱកាសសន្និបាតកម្មាភិបាលភូមិភាគបស្ចិម ថ្ងៃទី ២៥ ខែ៧ ឆ្នាំ១៩៧៧។ ខ្ញុំដឹងថាជាការលំបាកណាស់ក្នុងការឲ្យលោករំឭកចងចាំឡើងវិញនេះ។

តើលោកនៅចាំអំពីឯកសារទង់បដិវត្តនេះទេ ដែលបញ្ជូនព័ត៌មានដែលនិយាយនៅក្នុងមហាសន្និបាតហ្នឹងទេ ដែលនិយាយពីបទឧទ្ទេសនាមរបស់តំណាងអង្គការបក្ស។ អ្វីដែលលោកអានទស្សនាវដ្ដីទង់បដិវត្តហ្នឹង តើខ្លឹមសារអ្វីៗដែលគេកត់ត្រាក្នុងហ្នឹង គឺជាពាក្យសម្ដីរបស់ តាស៊ី ដែលបាននិយាយក្នុងឱកាសនោះដែរឬទេ?

[១៤:៣៧:០]

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំគិតថា គួរតែរៀបចំសំណួរនេះឡើងវិញ ពីព្រោះថាជាការសួរនាំមុខថា តាស៊ី ជាអ្នកធ្វើបទឧទ្ទេសនាមនេះ។ វាមិនមែនចេញមកពីការពិភាក្សាដេញដោលគ្នានោះទេ ដូច្នេះតំណាងអង្គការបក្សនេះមិនមានបញ្ជាក់ឈ្មោះទេ។ អ៊ីចឹងគាត់ប្រាប់ថា តាស៊ី ហ្នឹង ដូចជាប្រាប់នាំមុខហើយ ហើយអ្វីដែលគាត់លើកឡើងហ្នឹង ដូចវាហួសពីអ្វីដែលមានបង្ហាញនៅក្នុងទស្សនាវដ្ដីទង់បដិវត្តនេះទៅទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយក្នុងការដាក់បញ្ចូល ប៉ុល ពត ព្រោះបើគាត់ជាមនុស្សអ្នកធ្វើបទឧទ្ទេសនាម ឬក៏ តាស៊ី ប៉ុន្តែខ្ញុំមិនច្បាស់ពីរឿងហ្នឹង។ យើងសួរមិនទៅសាក្សី ថាតើលោកសាក្សីដឹងឬទេថា ទស្សនាវដ្ដីទង់បដិវត្តនេះ គឺតាមពិត គឺដាក់ពាក្យជាក់ស្ដែង គឺគ្រប់សុន្ទរកថាគ្រប់ម៉ាត់របស់អ្នកដែលថ្លែងការណ៍ ចូលក្នុងទស្សនាវដ្ដីបដិវត្តហ្នឹង តើអ៊ីចឹងដែរឬទេ លោកសាក្សី?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយសាក្សី។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ ជាដំបូង លោកគួរតែសួរសាក្សី ដើម្បីចង់ដឹងថា តើគាត់ស្គាល់អំពីខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្តនេះក៏អត់។ អត្ថបទនេះ គឺមានច្រើនទំព័រណាស់។ អ៊ីចឹង តើមានផ្នែកណាមួយជាក់លាក់ដែលលោកចង់សួរ ឬក៏លោកសួរទៅលើអត្ថបទហ្នឹងទាំងមូលតែម្តង? សំណួរដែលលោកសួរនេះ គឺថាវាមិនច្បាស់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានពេលទេ លោកចៅក្រម គឺថាអានឲ្យចប់ទាំងអស់នោះ គឺមិនអាចទៅរួច អ៊ីចឹងហើយបានខ្ញុំដកស្រង់ចំណុច ដកស្រង់ខ្លីៗ ហើយសួរសំណួរគាត់ដើម្បីឲ្យដឹង ឲ្យគាត់បញ្ជាក់ ថាតើកម្មាភិបាលភូមិភាគបស្ចិមណាដែលធ្វើបទឧទ្ទេសនាម ហើយនិងសួរគាត់ ថាតើព័ត៌មានដែលចុះនៅក្នុងទស្សនាវដ្តីទង់បដិវត្តនេះ វាឆ្លុះបញ្ចាំងពីអ្វីដែលនិយាយក្នុងបទឧទ្ទេសនាមដែរឬទេ។ ប៉ុន្តែដោយសារបញ្ហាពេលវេលាមានកម្រិតហ្នឹង ខ្ញុំមិនអាចនឹង អាចដកស្រាយនូវបញ្ហាដែលខ្ញុំចង់សួរនៅទីនេះឲ្យបានទាំងអស់ទេ។

[១៤:៤០:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកគួរតែចាប់ផ្តើមដោយដកស្រង់នូវចំណុចណាមួយដែលលោកចង់សួរជាក់លាក់តែម្តង មិនគួរនិយាយពីបទឧទ្ទេសនាមទាំងមូលនៅក្នុងអត្ថបទនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងបន្តទៅមុខទៀតលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយនៅក្នុងចម្លើយមជ្ឈមណ្ឌលឯកសារកម្ពុជាអំពី វន វ៉េត។ តើលោកនៅចាំអ្វីខ្លះអំពី វន វ៉េត នេះ?

**លោក មាស វឿន៖**

**ឆ៖** ខ្ញុំចាំឈ្មោះ វន វ៉េត ខ្ញុំចាំ។

**ស៖** បាទ ខ្ញុំសួរថា តើលោកចាំអ្វីខ្លះអំពីរឿងរ៉ាវគាត់ខុសពីឈ្មោះគាត់នោះណា?

**ឆ៖** ខ្ញុំមិនយល់ អត់យល់ សំណួរខ្ញុំអត់យល់។

**ស៖** តើ វន វ៉េត គាត់មានតំណែងជាអ្វី?

**ឆ៖** ខ្ញុំភ្លេចតំណែងគាត់ ខ្ញុំមិនចាំមុខតំណែងរបស់គាត់ទេ ព្រោះខ្ញុំភ្លេច។ ក្រោយមកក៏ខ្ញុំភ្លេចគាត់ ខ្ញុំបែកគាត់យូរអ៊ីចឹង ខ្ញុំភ្លេច មិនដឹងគាត់ទទួលខាងអ៊ីចឹង ចាំមិនបានកន្លែងហ្នឹង។

**ស៖** តើៗលោកនៅចាំឈ្មោះនីរសារលោក វន វេត ណាម្នាក់ដែរឬទេ?

**ឆ៖** អត់ទេ ខ្ញុំអត់ចាំទេ នីរសារគាត់ខ្ញុំអត់ចាំ ហើយក៏អត់ស្គាល់ដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រហែលជាពេលសមស្របដែលអាចនឹងសម្រាកសម្រាប់ល្ងាចនេះហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបញ្ចប់ឆាប់ៗនេះទេ ប្រើប្រាស់ពេលវេលាប្រហែលជា១០នាទីទៀត ហើយខ្ញុំនឹងផ្អាកការសួរសំណួរសិន។ តាមពិតខ្ញុំមានសំណួរច្រើនណាស់។

ពាក់ព័ន្ធទៅនឹង នៅក្នុងចម្លើយរបស់លោក ERN 0084--

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាត ញាប់ពេក តាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ បញ្ជាក់លេខអត្តសញ្ញាណឯកសារ និងលេខ ERN សាជាថ្មីម្ដងទៀត ហើយសូមយឺត មួយៗ ព្រោះអ្នកបកប្រែបកប្រែមិនទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ លោកប្រធាន គឺ E3/8752, ERN អង់គ្លេស 00849489, ខ្មែរ 00733315 ត្រង់នេះលោកនិយាយអំពី វន វ៉េត នៅ លោកថានៅពេលមួយនោះនីរសាររបស់ វន វ៉េត គឺជាប៉េអឹមនៅក្នុងរបប លន់ នល់ ពាក់ស័ក្តិ៥។ អ៊ីចឹងបានជាខ្ញុំសួរទៅលោក តើចំណុចនេះលោកនៅនឹកឃើញទេថា វន វ៉េត នេះគឺមាននីរសារម្នាក់ធ្លាប់ធ្វើជាប៉េអឹមពាក់ស័ក្តិ៥?

[១៥:០៣:៥៧]

**លោក មាស វឿន៖**

**ឆ៖** ខ្ញុំមិនចាំទេ។ ខ្ញុំអត់បាន អត់ដឹង អត់ស្គាល់នីរសារ វន វ៉េត ផង ខ្ញុំស្គាល់តែ វន វ៉េត ប៉ុណ្ណឹងឯង។

**ស៖** មិនថ្វីទេលោកសាក្សី ខ្ញុំចូលទៅប្រធានចុងក្រោយ ដោយសារតែពេលវេលា ខ្ញុំសួរត្រង់ៗតែម្ដង នូវអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/8752 ដដែល ត្រង់ទំព័រ១៨ជាភាសាអង់គ្លេស ERN 00849503, ខ្មែរ 00733330។ ខ្ញុំនឹងអានសម្រង់នេះឲ្យលោកស្ដាប់លោកសាក្សី ហើយខ្ញុំសួរសំណួរតាមក្រោយ។ គេបានសួរលោកអំពី ជូ ជេត ហៅ តាស៊ី ហើយលោកបានឆ្លើយថា៖ "នៅពេលនោះ ខ្ញុំបានឮថា តាស៊ី មានបំណងធ្វើរដ្ឋប្រហារទម្លាក់មេដឹកនាំកំពូលជាមួយនិង សោ ភឹម ហើយនិងកងចាប នៅពេលនោះ អ្នកទាំងអស់ហ្នឹង គឺថា អនុញ្ញាតឲ្យអ្នកទាំងអស់នោះធ្វើការទម្លាក់មេដឹកនាំហ្នឹង ហើយមានឈ្មោះ ចេង មួយដែរ មកពីក្រសួងឧស្សាហកម្ម។ អ្នកទាំងអស់នេះ គឺថាមានទំនាក់ទំនងគ្នាល្អរហូតដល់គេបានព្រមព្រៀងគ្នាធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត ដើម្បីក្ដាប់ក្ដោបក្ដាប់អំណាច។ មិនជារឿងងាយស្រួលក្នុងការរៀបរាប់ឲ្យអស់នោះទេ ហើយសោ ភឹម នេះ គឺថាមានជាប់ទំនាក់ទំនងជាមួយនិងវៀតណាម ហើយវៀតណាមហ្នឹង គេបញ្ជូនស្រីមកឲ្យគាត់ ហើយមាន

ផែនការរបស់វៀតណាមនេះ គឺថាបង្ហូរស្រីមក ឲ្យចូលមកធ្វើការជាមួយនឹង សោ ភឹម។ នេះ គឺរបៀបដែលគេជាប់ទំនាក់ទំនងជាមួយគ្នាគឺយ៉ាងដូច្នេះ។" បញ្ចប់ការដកស្រង់។ លោកសាក្សីលោកនៅចាំទេថាលោកបានឆ្លើយអ៊ីចឹងជូនទៅខាងផ្នែកមជ្ឈមណ្ឌលឯកសារកម្ពុជា?

[១៥:០៦:១៨]

**ឆៈ** បាទ ខ្ញុំឮកងពលខ្ញុំប្រាប់ខ្ញុំ ប្រធានកងពលប្រាប់ខ្ញុំ។ ខ្ញុំបានបញ្ជាក់តាមពាក្យគាត់ប្រាប់ខ្ញុំអ៊ីចឹងមែនបាទ។

**សៈ** លោកចាំទេថា ធ្លាប់ -- ថាតើលោកឮអំពីបំណងធ្វើរដ្ឋប្រហារទម្លាក់មេដឹកនាំហ្នឹង តើវាខកខានទៅវិញ ឬក៏ថាមានបានអនុវត្តនូវផែនការនេះទេ? ហើយតើលោកបានដឹងអំពីបំណងនៃការធ្វើរដ្ឋប្រហារនេះ ដោយរបៀបណា?

**ឆៈ** បាទ ខ្ញុំមិនដឹងថា គេធ្វើរបៀបណានោះទេ ប៉ុន្តែកងពលខ្ញុំគ្រាន់តែប្រាប់ថា ការដែលធ្វើផ្តួលរំលំ ប៉ុល ពត ហ្នឹងគឺដោយ តាជូ ជេត ហ្នឹងផង ហើយនិងនៅបូព៌ានោះន៎ៃ ឈ្មោះន៎ៃអនុប្រធានរដ្ឋហ្នឹង សោ ភឹម ហ្នឹងផង ហើយនៅខាងឧត្តរហ្នឹងផង។ អាហ្នឹង គឺគាត់ប្រាប់ខ្ញុំតែចំណុចខ្លីៗទេ មិនជាប្រាប់វែងទេ ក៏ប៉ុន្តែដើម្បីឲ្យគ្រាន់តែខ្ញុំដឹង ខ្ញុំយល់ទេ។ ប៉ុន្តែកិច្ចការដែលត្រូវផ្តួល ត្រូវធ្វើ ឬក៏ត្រូវមានផែនការរបៀបណានោះ ខ្ញុំមិនបាន គាត់មិនបានប្រាប់ខ្ញុំអស់ទេ។ មានប៉ុណ្ណឹង។

**សៈ** តើលោកអាចពន្យល់ឲ្យបានទូលំទូលាយបន្តិចបានទេ ត្រង់ផ្នែកដែលលោកនិយាយថា សោ ភឹម នេះ ពីព្រោះខ្ញុំខ្លាចថា ខ្ញុំយល់មិនបានច្បាស់ថា គាត់មានបន្ទាយមួយនៅភូមិភាគបូព៌ា ហើយដែលប្រហែលវៀតណាមមានផែនការដឹកយន្តហោះៗយកមកឲ្យធ្វើការជាមួយនឹង សោ ភឹម។ តើលោកចង់និយាយថាយ៉ាងម៉េចដែរនៅពេលដែលថាគេដឹកយន្តហោះស្រីៗហ្នឹង ដឹកស្រីៗមកឲ្យធ្វើការជាមួយ សោ ភឹម?

[១៥:០៨:២១]

**ឆៈ** នេះ ខ្ញុំឮពេទ្យ -- បាទ ខ្ញុំជម្រាបឲ្យបានខ្លីល្មមតែស្តាប់បាន គឺដែលសោ ភឹម ដែលគាត់មានផែនការហ្នឹង ពេទ្យរបស់ខាងបូព៌ាហ្នឹង គាត់ប្រាប់ខ្ញុំពេលដែលគាត់រត់យួនហ្នឹង គាត់ជួបខ្ញុំ គាត់ប្រាប់ខ្ញុំ។ គាត់ថា សោ ភឹម ហ្នឹងគាត់ទៅមានបន្ទាយនៅព្រំដែនខ្មែរ និង យួន ហ្នឹង។ យួនហ្នឹងធ្វើបន្ទាយឲ្យ ហើយយប់ឡើង ដឹកស្រីយួនហ្នឹងមកឲ្យសោ ភឹម តាមយន្តហោះកន្ទុំរុយ។ ដូច្នេះ ដែលបន្ទាយនៅកន្លែងណាៗ នោះខ្ញុំមិនដឹងទេ ប៉ុន្តែគាត់ប្រាប់ថានៅព្រំដែនខ្មែរ-យួនហ្នឹង ប៉ុន្តែមិនមែនជាប់ទេ ចូលក្នុងដី

យួនប្រហែលជា១០០ម៉ែត្រអ៊ីចឹង គាត់ប្រាប់ខ្ញុំអ៊ីចឹង។ ខ្ញុំដឹងតែតាមគាត់ប្រាប់ ពីព្រោះខាងបូព៌ាដែលគាត់រត់យួនមកហ្នឹងគាត់ប្រាប់។ ពេទ្យហ្នឹងគាត់ប្រាប់ខ្ញុំអ៊ីចឹង។ បានន័យថា សោ ភឹម ហ្នឹងគាត់ក្បត់។ អ៊ីចឹងបានថា -- ខ្ញុំឮតាមពេទ្យហ្នឹងគាត់ប្រាប់ខ្ញុំទេ។ ខ្ញុំឃើញនោះ មិនបានឃើញទេ ក៏ប៉ុន្តែខ្ញុំឮគាត់ គេប្រាប់ខ្ញុំអ៊ីចឹង។ សូមបញ្ជាក់ខ្លី។

**ស៖** តើពេទ្យទាំងនោះ មានពន្យល់អំពីស្រីៗវៀតណាមហ្នឹងទេ?

**ឆ៖** គាត់មិនបានពន្យល់ពីរឿងស្រីវៀតណាមថាយ៉ាងម៉េចនោះទេ ក៏ប៉ុន្តែថា គាត់ថាមានដឹកស្រីយកមកឱ្យ សោ ភឹម តាមយន្តហោះ តាមយន្តហោះកន្ទុំរុយនោះ។ រឿងស្រីប៉ុន្មានៗខ្ញុំមិនបានសួរបញ្ជាក់ទៀតបាទ។

**ស៖** ថាតើស្រីៗទាំងអស់ហ្នឹង ជាកងទ័ព ឬក៏មិនមែនទេ?

**ឆ៖** ទេ ខ្ញុំមិនបានសួរបញ្ជាក់ពីរឿស្រី។ កងទ័ព ឬក៏ស្រីកូនប្រជាជន ខ្ញុំមិនបានសួរគេផងបាទ។

[១៥:១០:៤០]

**ស៖** អរគុណលោកសាក្សី។ សំណួរមួយទៀត ទាក់ទងទៅនឹងផែនការធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត ហើយនិងមេដឹកនាំកំពូលៗ។ ខ្ញុំសូមអានសម្រង់ខ្លីមួយឱ្យលោកស្តាប់ គឺពីកងទ័ពម្នាក់ដែលជាសមាជិកនៃកងពលលេខ១៦៤នេះ គឺឯកសារ E319/23.3.17.1 គឺជាឯកសារដែលអង្គជំនុំជម្រះទើបតែបានទទួល, ERN អង់គ្លេស 01174833, បារាំង 00996698 ដល់ 99, ខ្មែរ 00955619។

លោកសាក្សី កម្មាភិបាលមកពីកងពលលេខ១៦៤នេះ បានឆ្លើយដូចតទៅ៖ "មិនមែនមានរដ្ឋប្រហារតែម្តងទេ តាមដែលខ្ញុំដឹងគឺមានរដ្ឋប្រហារបួនទៅប្រាំដងឯនោះ កើតឡើងនៅក្នុងទីក្រុងភ្នំពេញ។ ពួកគេចង់ទម្លាក់ ប៉ុល ពត។ ហេតុដូច្នេះឯងទើបបានមានគេសម្លាប់មនុស្សហ្នឹង។ ហើយគឺថាម្នាក់ៗលែងទុកចិត្តគ្នាអស់ហើយ។"

លោកសាក្សី កម្មាភិបាលនេះ មិនមិនមែននិយាយតែត្រឹមរដ្ឋប្រហារមួយដងទេ គាត់ថាមានការប៉ុនប៉ងធ្វើរដ្ឋប្រហារហ្នឹង បួនប្រាំដងឯនោះ ដែលធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ។ តើលោកដឹងដែរទេ?

**ឆ៖** បាទ ខ្ញុំមិនសូវដឹងទេ ព្រោះអីខ្ញុំនៅឆ្ងាយជាងគេ មិនសូវដឹងរឿងកិច្ចការហ្នឹងទាំងអស់។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំសម្រាប់ពេលនេះ លោកសាក្សី តើលោកមានឮអ្វីទៀតដែរអំពីកម្លាំងបះបោរប្រឆាំងទៅនឹងមជ្ឈិម។ តើលោកមានឮអ្វីទៀតដែរទេ ពាក់ព័ន្ធទៅនឹងរដ្ឋប្រហារ ឬក៏ព័ត៌មានណាមួយដែលលោកចង់ជម្រាបជូនអង្គជំនុំជម្រះបន្ថែមឱ្យលម្អិតតទៅទៀតទេ?

**ឆ៖** ខ្ញុំមិនបានឮអីក្រៅពីហ្នឹងទៀតទេ តាមដែលខ្ញុំដឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

[១៥:១៣:៥១]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វាំងសង់ ដេវីល ខ្ញុំនឹងសួរសំណួរលោកៗនៅថ្ងៃនេះ និងថ្ងៃស្អែក តាំងនាមឲ្យសហព្រះរាជអាជ្ញា។ ប្រសិនបើលោកមិនយល់ សូមលោកប្រាប់ខ្ញុំថា សំណួរខ្ញុំមិនច្បាស់ ខ្ញុំនឹងសួរលោកឡើងវិញ។ ខ្ញុំដឹងថាលោកត្រូវបានស្តាប់ចម្លើយកាលពីឆ្នាំ២០១២ ខែតុលា ទៅលើប្រធានបទជាច្រើន ហើយខ្ញុំមិនអាចត្រឡប់មកសួរលើប្រធានបទទាំងអស់ហ្នឹងវិញទេ។ ខ្ញុំសួរតែទៅលើប្រធានបទមួយចំនួនតែប៉ុណ្ណោះ នៅរសៀលនេះ និងនៅថ្ងៃស្អែក។

ជាដំបូងខ្ញុំចង់សួរបញ្ជាក់លោកបន្តពីសំណួរមុន អំពីការប៉ុនប៉ងធ្វើរដ្ឋប្រហារដែលមេធាវីការពារក្តីសួរលោក។ លោកបាននិយាយថា លោកបានឮគេនិយាយគ្នាអំពីរឿងនេះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើរឿងនេះ គ្រាន់តែជាពាក្យចចាមអារ៉ាម ឬក៏មានមូលដ្ឋានរឹងមាំ ពាក់ព័ន្ធនឹងរឿងប៉ុនប៉ងធ្វើរដ្ឋប្រហារនេះ?

**លោក មាស វឿន៖**

**ឆ៖** បើតាមមិត្តភក្តិប្រាប់ខ្ញុំ គោលបំណងធ្វើរដ្ឋប្រហារនេះគឺជារឿងពិត ពីព្រោះអីកាលដែលមិត្តភក្តិខ្ញុំប្រាប់ហ្នឹង ហើយនិងដែលឲ្យដឹងហ្នឹង គឺថាមានថ្ងៃមួយមិនដឹងថ្ងៃណា ខ្ញុំមិនបានចាំ។ មានពោងបណ្តែតមកពីតាមទន្លេមកសរសេរជាអក្សររុស្ស៊ី តែយើងមិនបានដឹងថាពោងហ្នឹងគេបណ្តែតមកពីខាងណាទេ តែបែបមកពីក្រោមមក មកពីភ្នំពេញហ្នឹង។ ពោងហ្នឹងសរសេរអក្សររុស្ស៊ី ប៉ុន្តែយើងមិនចេះមើលទេ អ្នកទាំងអស់អត់ចេះមើលទេ តែគេនៅជិតហ្នឹងគេរើសបាន – គេរើសបានពីក្នុងពោងដែល

រសាយរសាត់មកចំមកមុខវាំងហ្នឹងគេចាប់បានហើយ គេយកទៅឲ្យពួកចិនមើល ចិនគេចេះអក្សរគេប្រាប់យើង។ ដូច្នេះ ការធ្វើរដ្ឋប្រហារហ្នឹងគេមានគោលការណ៍របស់គេ។ អ៊ីចឹងអានេះដែលមិត្តភក្តិខ្ញុំប្រាប់ ឲ្យដឹងខ្លីៗខ្លះ ហើយខ្ញុំក៏បានទទួលដំណឹងហ្នឹងខ្លីៗតាមមិត្តភក្តិរបស់ខ្ញុំដែលប្រាប់។ គោលបំណងធ្វើរដ្ឋប្រហារគឺផ្តួលរលំ ប៉ុល ពត អ៊ីចឹងមែន។ តែប៉ុន្មានដងៗ ខ្ញុំមិនបានដឹងថាគោលបំណងធ្វើប៉ុន្មានដងពីរបីដងហ្នឹង ខ្ញុំអត់បានដឹងទេ ប៉ុន្តែខ្ញុំដឹងថាៗ ចំណុចត្រង់ហ្នឹងដែលដឹងតែម្តងហ្នឹងឯង ដែលដឹងច្បាស់។ សូមអស់។

[១៥:១៦:៤០]

**ស៖** ដូច្នេះ មានន័យថាលោកមិនដឹងប្រភពច្បាស់លាស់នោះទេ មែនទេ ពាក់ព័ន្ធទៅនឹងព័ត៌មានដែលលោកទទួលបាននោះ? លោកមិនដឹងថាមិត្តភក្តិដែលទៅប្រាប់លោកហ្នឹងគាត់មានមូលដ្ឋានអ្វីច្បាស់លាស់ពាក់ព័ន្ធនឹងព័ត៌មានដែលគាត់ប្រាប់លោកហ្នឹងទេ មែនទេ?

**ឆ៖** បាទ។

**ស៖** ពេលដែលលោកនិយាយបាទហ្នឹង មានន័យថា លោកឯកភាពថាលោកមិនស្គាល់ប្រភពច្បាស់លាស់នៃព័ត៌មានហ្នឹងទេ មែនទេ?

**ឆ៖** បាទ ខ្ញុំដឹងថាព័ត៌មានហ្នឹងគេប្រាប់ខ្ញុំអ៊ីចឹង ប៉ុន្តែប្រភពហ្នឹងគេប្រាប់ខ្ញុំច្បាស់អ៊ីចឹងហើយ ក៏ប៉ុន្តែត្រង់តែថាគោលការណ៍ដែលរដ្ឋប្រហារប៉ុន្មានដងៗនោះ ខ្ញុំមិនដឹងច្បាស់ទេ ក៏ប៉ុន្តែពេលដែលខ្ញុំឃើញហ្នឹង ឃើញតែម្តងហ្នឹងឯង ដែលគេប្រាប់ខ្ញុំហ្នឹងណា មានប៉ុណ្ណឹងឯង។

**ស៖** មុននេះលោកបាននិយាយថា លោកបាន ពេលលោករត់យួនហ្នឹង ពេទ្យបាននិយាយប្រាប់លោក។ អ៊ីចឹងមានន័យថា ពេលដែលលោក -- គេប្រាប់លោកហ្នឹង ពេលណា ពេលបែកយួនហ្នឹង ឬក៏ម៉េច?

**ឆ៖** ពេលបែកពីយួនហ្នឹងឯង ពេលដែលយួនវ៉ៃយើងបែកហ្នឹងឯង។

**ស៖** ខ្ញុំមានសំណួរមួយទៀតពាក់ព័ន្ធនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ នៅថ្ងៃនោះ លោកចូលទៅភ្នំពេញជាមួយកងកម្លាំងរបស់លោក។ តើលោកមានឮគេផ្សព្វផ្សាយសារតាមវិទ្យុនៅពេលថ្ងៃ ដែលផ្សាយថា អតីតរដ្ឋមន្ត្រីក្រសួងនានា ហើយនិងអតីតឧត្តមសេនីយ៍ មន្ត្រីជាន់ខ្ពស់អីហ្នឹងឲ្យទៅប្រមូលផ្តុំគ្នានៅក្រសួងព័ត៌មាននិងឃោសនាការទេ? លោកមានឮការអំពាវនាវថា ឲ្យអ្នកដែលមានបណ្តាស័ក្តិហ្នឹងឲ្យទៅជួបជុំគ្នានៅក្រសួងឃោសនាការនិងព័ត៌មានទេ?

**ឆ៖** ខ្ញុំអត់បានដឹងផង ពីព្រោះអីអត់មានវិទ្យុស្តាប់ផងនៅពេលដែលយើងរៀ។

**ស៖** ចុះលោកផ្ទាល់នោះ លោកមានទៅប្រចាំការ ឬក៏ឈរជើងអីនៅមុខក្រសួងព័ត៌មានហ្នឹងទេ?

**ឆ៖** ខ្ញុំគ្មានដឹងផង អត់មានបានទៅផង។

**ស៖** លោកបានទទួលបញ្ជាឲ្យចាកចេញពីភ្នំពេញឲ្យឆាប់បំផុត ក្រោយពីបែកភ្នំពេញ។ ដូច្នេះលោកស្នាក់នៅភ្នំពេញប៉ុន្មានថ្ងៃដែរមុនពេលលោកចាកចេញទៅនុ៎ង? ព្រោះថាចម្លើយរបស់លោកមានច្រើនហើយវាដូចជាមិនស៊ីចង្វាក់គ្នា។

**ឆ៖** ខ្ញុំចង់សួរបញ្ជាក់ថា សំណួរឲ្យៗសួរឲ្យខ្ញុំច្បាស់ថាតើ -- សួរថាខ្ញុំពេលដែលបែកភ្នំពេញ ឬក៏ ពេលដែលបែកភ្នំពេញតើខ្ញុំនៅបានប៉ុន្មានថ្ងៃ អ៊ីចឹងអ្វេស? ខ្ញុំស្ដាប់សំណួរមិនៗសូវបាន ចង់សួរបញ្ជាក់ម្ដងទៀត។

**ស៖** ខ្ញុំមិនទទួលបានការបកប្រែនូវចម្លើយរបស់លោកទេ។ ខ្ញុំសួរថា ពេលបែកភ្នំពេញហ្នឹងលោកនៅភ្នំពេញហ្នឹងបានប៉ុន្មានថ្ងៃ បែកភ្លាមលោកចេញភ្លាម ឬក៏លោកស្នាក់នៅសិន បានចេញទៅតាមក្រោយ?

**ឆ៖** ខ្ញុំបានប្រាប់មកហើយថា ខ្ញុំថានៅបានប្រហែលជាមួយអាទិត្យ គេឲ្យខ្ញុំទៅកំពត ទៅផ្លូវកំពត អាហ្នឹងខ្ញុំប្រាប់គេលើកមុនរួចហើយ។

[១៥:២១:២៥]

**ស៖** ក្រោយពីទៅកំពតខ្ញុំៗដឹងថាលោកឆ្លងកាត់តាមកំបូល និងបែកចាន។ អ៊ីចឹង ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេមុនទៅដល់កំពត លោកឆ្លងកាត់កំបូលសិន លោកទៅៗកំបូលសិនមែនទេ?

**ឆ៖** បាទ ខ្ញុំចេញពីកំបូលហ្នឹង ទៅផ្លូវលេខ៣ ទៅកំពត។

**ស៖** ក្រោយពីលោកចេញពីភ្នំពេញទៅ តើលោកមានបានចូលក្នុងកិច្ចប្រជុំណាមួយធំៗ ឬក៏ចូលរួមក្នុងវគ្គរៀនសូត្រនៅកំពតជាមួយនឹងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** អត់មានទេ ចេញៗតែពីៗភ្នំពេញទៅកំពតហ្នឹងរហូតអត់មានបាន ដែលបានប្រជុំទេខ្ញុំ។

**ស៖** ខ្ញុំនឹងអាននូវសម្រង់ពីរនៃចម្លើយពីមុនរបស់លោក។ ទី១ គឺឯកសារ E3/73 ជាកំណត់ហេតុស្ដាប់ចម្លើយគឺនៅចម្លើយទី១៣ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោក៖ “ក្រោយពីរំដោះភ្នំពេញកងទ័ពរបស់ខ្ញុំចាកចេញពីក្រុង ហើយខ្ញុំឃើញប្រជាជនដើរចេញមកក៏អនុញ្ញាតឲ្យប្រជាជនចេញទៅ។

ខ្ញុំនៅក្រៅក្រុងភ្នំពេញបានរយៈពេលប្រហែលមួយសប្តាហ៍ប៉ុណ្ណោះ។” សូមបញ្ចប់ការដកស្រង់។ ហើយ នៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/8752 ទំព័រ១៤ ជាភាសាអង់គ្លេស, ១៥ ជាភាសាខ្មែរ លោកបាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ “បន្ទាប់ពីគេកាន់កាប់ភ្នំពេញ គេបានចាប់ផ្តើមរៀបចំកងទ័ពខាងជើងទឹក ហើយនិងជើងអាកាស ហើយពេលនោះហើយដែលយើងជួបគ្នា ហើយយើងទទួលភារកិច្ចឲ្យទៅទិសដៅផ្សេងៗ យើងមិនដែលត្រឡប់មកជួបគ្នាវិញទេ។ សំណួរ ៖ តើលោកបានចូលក្នុងហេតុការណ៍ដែលរៀបចំនៅស្តាតអូឡាំពិកទេ?” លោកឆ្លើយថា៖ បាទ ខ្ញុំបានចូលរួម។” ចប់សេចក្តីដកស្រង់។

ការបកប្រែជាភាសាអង់គ្លេសដូចជាមិនសូវល្អទេ ក៏ប៉ុន្តែក្នុងនេះបញ្ជាក់ថា លោកបានចូលរួមនៅក្នុងព្រឹត្តិការណ៍មួយនៅស្តាតអូឡាំពិក។ តើលោកអាចបញ្ជាក់បានទេ លោកចូលរួមហេតុការណ៍នៅស្តាតអូឡាំពិកហ្នឹងនៅពេលណា? ប៉ុន្មានថ្ងៃក្រោយពីប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ?

**ឆ៖** សំណួរហ្នឹងខ្ញុំបានឆ្លើយម្តងរួចហើយ កាលដែលលោកសួរថា ចេញពីនៅភ្នំពេញប៉ុន្មានថ្ងៃបានចេញពីភ្នំពេញ ខ្ញុំឆ្លើយថាបានប្រហែលមួយសប្តាហ៍ ហើយខ្ញុំទៅកំពត ហើយសំណួរតទៀត ខ្ញុំចេញពីកំពតទៅកោះកុងទៀត អាហ្នឹងបានៗទៅរៀបចំកោះកុងហើយ បានខ្ញុំបានមកប្រជុំ។ អាហ្នឹងវាទាក់ទងអ៊ីចឹងបានខ្ញុំ ខ្ញុំចេះតែឆ្លល់ ហើយសំណួរហ្នឹងមិនទាក់ទងអីខ្ញុំទៅកំពតហើយមកប្រជុំវិញ។ អាហ្នឹង គឺខ្ញុំអត់ស្របតាមសំណួរហ្នឹង ពីព្រោះអីមិនទាន់ដល់ដំណាក់កាលដែលខ្ញុំមកប្រជុំណា។ ខ្ញុំចេញពីភ្នំពេញទៅកំពត ហើយចេញពីកំពតទៅកោះកុង បានចេញពីកោះកុងបានខ្ញុំមក។ មកវិញ បានមកប្រជុំគេ។ អ៊ីចឹងបានន័យថា ខ្ញុំឆ្ងល់សំណួរហ្នឹង ទាក់ -- មិនទាន់គ្នាអ៊ីចឹងបានខ្ញុំឆ្លើយមិនត្រូវ។ សូមទោស។ ខ្ញុំឃើញអ៊ីចឹងឯង។

[១៥:២៥:៥០]

**ស៖** ខ្ញុំព្យាយាមសួរឲ្យវាស៊ីចង្វាក់គ្នាពាក់ព័ន្ធទៅនឹងការបរិច្ឆេទផ្សេងៗ ដែលលោកបានឆ្លើយជូនអង្គជំនុំជម្រះនិងអ្នកស៊ើបអង្កេត។ លោកនិយាយអំពីការប្រជុំ ហើយលោកៗថានៅកោះកុង។ អ៊ីចឹងខ្ញុំចង់ដឹងថាការប្រជុំនេះ ដែលលោកនិយាយហ្នឹង នៅកន្លែងណា?

**ឆ៖** ខ្ញុំឆ្លើយកាត់ ខ្ញុំអត់ៗស្តាប់សំណួរបាន។ តាមសង្វាក់ហ្នឹងខ្ញុំអត់យល់ ព្រោះអីសំណួរវិលចុះវិលឡើងអ៊ីចឹង ខ្ញុំពិបាកជម្រាបជូនលោក។ ហើយខ្ញុំមិនយល់ថា ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង ព្រោះអម្បាញ់មិញដែលលោកសួរខ្ញុំពីៗនៅភ្នំពេញបានប៉ុន្មានថ្ងៃ ហើយខ្ញុំទៅកំពត។ ហើយត្រឡប់មកសួរទៅកំពតៗ

បានមកប្រជុំ។ អាហ្នឹងខ្ញុំអត់បានមកប្រជុំទេ ទាល់តែខ្ញុំទៅកោះកុងទៀតនោះ បានខ្ញុំបានមកប្រជុំក្រោយមកទៀត។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិ រៀបចំសំណួរឡើងវិញ បើលោកមានបំណងសួរដូច្នេះ គឺលោកសួរទី១ គឺកាលបរិច្ឆេទនៃការដែលសាក្សីចងចាំ អំពីពេលវេលាដែលគាត់មកប្រជុំនៅទីក្រុងភ្នំពេញជាមុនសិន។ អំឡុងពេលណា ហើយគាត់នៅទីណាដែលគាត់ត្រូវគេកោះហៅមកប្រជុំ ហើយតើប្រជុំនៅកន្លែងណា អានោះជារឿងបន្តសំណួរទៀត។ បើពុំដូច្នោះទេ គឺការស្តាប់មិនយល់ហ្នឹង គឺបានអូសបន្លាយពេលវេលាឥតប្រយោជន៍ទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមឲ្យលោកឆ្លើយជាក់លាក់ទៅនឹងសំណួររបស់ខ្ញុំ ក្នុងសម្រង់ដែលខ្ញុំអាននុ៎ង លោកថាលោកបានចូលរួមនៅក្នុងការប្រជុំមួយនៅស្តាតអូឡាំពិក។ លោកថាលោកនៅកោះកុងហើយ អ៊ីចឹងពេលដែលលោកត្រឡប់មកភ្នំពេញ មកចូលរួមក្នុងកិច្ចប្រជុំនៅស្តាតអូឡាំពិកហ្នឹង ពេលណា? ហើយអ្នកណាខ្លះបានចូលរួមកិច្ចប្រជុំហ្នឹង?

[១៥:២៨:១១]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំសូមរៀបរាប់ដោយតាមសំណួរដែលខ្ញុំចាំ។ លោកសួរខ្ញុំ បើសួរថា "លោកដែលបានប្រជុំ មកប្រជុំនៅភ្នំពេញទេមុនពេលដែលទៅកំពតហ្នឹង?" អ៊ីចឹងខ្ញុំអាចឆ្លើយបាន។ ឥឡូវខ្ញុំឆ្លើយថាអ៊ីចេះ ខ្ញុំបានមកប្រជុំនៅភ្នំពេញ ប្រជុំនៅ -- ខ្ញុំឆ្លើយសំណួរ ខ្ញុំបានប្រជុំនៅភ្នំពេញថ្ងៃខែខ្ញុំអត់ចាំទេ។ ការដែលប្រជុំហ្នឹង គឺមានការប្រជុំរៀបចំកងទ័ព។ កងទ័ពជើងទឹក ជើងគោក ជើងអាកាស។ ហ្នឹងខ្ញុំបានប្រាប់ ដើម្បីឲ្យដឹងថាក្នុងប្រជុំហ្នឹងគឺរៀបចំរបៀបម៉េច គឺរៀបចំដែលអ្នកដឹកនាំប្រជុំបានដឹកនាំនែរៀបចំកងទ័ពជើងទឹក ជើងគោក ជើងអាកាសហ្នឹង ខ្ញុំឃើញៗអ៊ំ ប៉ុល ពត មួយ, អ៊ំ នួន ជា មួយ, ពីរនាក់ដែលខ្ញុំឃើញ ឃើញពីរនាក់ ក្រៅពីហ្នឹងខ្ញុំមិនបានឃើញទាំងអស់ទេ។ ហើយការដែលក្នុងរៀបចំប្រជុំហ្នឹង គឺរៀបចំកងទ័ពជើងទឹក ជើងគោក ជើងអាកាសហ្នឹង គាត់ឲ្យអ៊ំ ប៉ុល ពត ថ្លែងសុន្ទរកថាស្តី

ពីការអបអរនៃការរៀបចំកងទ័ពជើងទឹក ជើងគោក ជើងអាកាសហ្នឹង។ ហ្នឹងខ្ញុំបញ្ជាក់ក្នុងសំណួរដែលពាក់ព័ន្ធក្នុងអានចម្លើយអំមិញហ្នឹង បានបញ្ជាក់ឃើញអ៊ីចឹង។ ដូច្នេះ ការដែលរៀបចំកងទ័ពជើងទឹក ជើងគោក ជើងអាកាសរួចហើយ យើងនឹងមានការបែកគ្នាទៅតាមអង្គភាពផ្សេងៗ តាមមុខសញ្ញាម្នាក់ៗ តាមអង្គភាពវិញ។ មានប៉ុណ្ណឹង។

**ស៖** ក្នុងពេលប្រជុំហ្នឹងហើយមែនទេ ដែលកងពលដែលជារបស់ភូមិភាគហ្នឹង ក្លាយមកជាកងពលរបស់មជ្ឈិមនោះ ពេលក្នុងប្រជុំហ្នឹងហើយមែនទេដែលគេផ្លាស់ប្តូរកងពលហ្នឹង ឲ្យក្លាយទៅជាកងពលជាកងពលមជ្ឈិមវិញនុ៎ង?

**ឆ៖** បាទ មិនមែនទេ។ ក្នុងការរៀបចំកងពលជើងទឹក ជើងគោក ជើងអាកាសហ្នឹង ដកចម្រុះគ្នា ដកពីក្នុងភូមិភាគមួយៗ មកដូចថាៗកងពលលេខ១ ដកប៉ុន្មានមកខាងជើងអាកាស កងពលលេខប៉ុន្មាន ដកៗចម្រុះគ្នាតាមរៀបចំសាជាថ្មី។ អាហ្នឹងជាកិច្ចការរបស់អ្នកដឹកនាំខាងលើ ព្រោះខ្ញុំមិនមែនអ្នកដកទេ គេត្រូវការប៉ុន្មាន យើងបែកឲ្យគាត់រៀបចំប៉ុននុ៎ង។ ខ្ញុំមិនបានទៅរៀបចំទេ ប៉ុន្តែគ្រាន់តែដឹង។ ការរៀបចំជាក់ស្តែង នៅលើអ៊ំៗខាងលើតើ។ ខ្ញុំមានប៉ុណ្ណឹង។

[១៥:៣១:៣០]

**ស៖** ពាក់ព័ន្ធទៅនឹងការងាររបស់លោកនៅកោះកុង។ លោកថាលោកធ្វើការបីឆ្នាំ ជាអនុកងពល១ នៃភូមិភាគបស្ចិម (សុំទោស) គឺភូមភាគបូព៌ា។ ខ្ញុំសូមដកស្រង់នូវចម្លើយដែលលោកបានឆ្លើយជូនមជ្ឍមណ្ឌលឯកសារកម្ពុជា គឺ E3/8752 ទំព័រ១០ ជាភាសាអង់គ្លេស និងទំព័រ១០ ជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

ដូចអត់ច្បាស់ទេ ហើយចេញភូមិភាគបូព៌ាពីណាមក ហើយគាត់ជាអនុប្រធានកងពលលេខ១ មិនមែនកងពល១ទេ កងពលលេខ១ ហើយកងពលហ្នឹង គឺចំណុះឲ្យភូមិភាគបស្ចិម ហើយចេញមកបូព៌ាឯណាដែរ អ៊ីចឹងវាឆ្លើយឆ្គង បើគាត់នៅកំពុងតែច្របូកច្របល់ផង ហើយយើងបង្កើតបញ្ហាឲ្យច្របូកច្របល់ទៀត កាន់តែទម្ងន់។ បញ្ហាហ្នឹងមិនអាចជាឆ្លើយរួចទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន គឺភូមិភាគបស្ចិម គឺកងពលលេខ១ នៃភូមិភាគបស្ចិម។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/8752 ទំព័រ១០ ជាភាសាខ្មែរ និងភាសាអង់គ្លេស លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "នៅឆ្នាំ១៩៧៥ គេបានបញ្ជូនខ្ញុំទៅកំពត។ ខ្ញុំបានស្នាក់នៅ -- ក្រោយពីស្នាក់នៅកំពតបីខែ គេក៏បញ្ជូនខ្ញុំទៅវាលរេញ ហើយខ្ញុំនៅវាលរេញពីរខែ គេក៏បញ្ជូនខ្ញុំបន្តទៅទៀត គឺទៅកោះកុង។ គេបញ្ជូនខ្ញុំទៅកោះកុងនៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ហើយនៅទីនោះរហូតដល់វៀតណាមវាយចូលមក។" បញ្ចប់ការដកស្រង់។

លោក លោកថា ពេលនុ៎ង គឺលោកទៅព្រះវិហារ។ អ៊ីចឹងត្រឹមត្រូវទេ លោកអាចបញ្ជាក់បានទេ អំពីចម្លើយរបស់លោក ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គឺថាលោកទៅកោះកុងហ្នឹង គឺនៅចុងឆ្នាំ៧៥ ឬដើម៧៦។ បន្ទាប់មកទៀត លោកចេញពីកោះកុងទៅព្រះវិហារហ្នឹង គឺនៅឆ្នាំ១៩៧៨?

[១៥:៣៤:០៣]

**លោក មាស វឿន៖**

**ឆ៖** បាទ ចាំមើលណ៎ា ខ្ញុំទៅកោះកុង ខ្ញុំនៅៗកោះកុង។ នៅចុងឆ្នាំ១៩៧៨ ខែ៨ គេផ្លាស់ខ្ញុំពីកោះកុងមកព្រះវិហារ។ មកព្រះវិហារបានបួនខែ ខ្ញុំចាំៗ ខ្ញុំៗប្រាប់ក្នុងឯកសារហ្នឹង ក៏ខ្ញុំថាបួនខែដែរហ្នឹងនៅព្រះវិហារ។ នៅព្រះវិហារបានបួនខែ យួនត្រូវវាយចូលស្រុក ចូលកម្ពុជា បែក ចូលកម្ពុជា ដល់ភ្នំពេញ។ ខ្ញុំដូច្នេះ ខ្ញុំនៅព្រះវិហារបានតែបួនខែប៉ុណ្ណោះទេ មិនបាននៅយូរដូចតាមកន្លែងនៅកោះកុងទេ។ ដូច្នេះបានន័យថា ខ្ញុំនៅដើមចុងខែ ចុង៧៨ ខែ៨ ខ្ញុំមកព្រះវិហារ។ ហើយក្រោយមក យួនវាយមក ក៏បែកតាមព្រំដែនរហូតមក។

**ស៖** បាទ អ៊ីចឹងមានន័យថា លោកនៅកោះកុងបីឆ្នាំ។ ពេលលោកទៅដល់កោះកុង តើលោកមានកូនទាហានប៉ុន្មាននាក់នៅក្នុងកងពលលេខ១នោះ?

**ឆ៖** បាទ នៅកងពលលេខ១ហ្នឹង ខ្ញុំសុំនិយាយបែកចេញជាពីរ។ ទី១ ប្រចាំការនៅលង្វែក ទី២ នៅវាលរេញ ហើយទី៣ នៅកោះកុង។ ដូច្នេះបែកក្នុងមួយកងពលហ្នឹងបែកជាបីៗកន្លែង។ ហើយមួយចំនួនដកចេញពីក្នុងហ្នឹងមកនៅខាងជើងអាកាស ខាងអង្គភាពជើងអាកាស។ អ៊ីចឹងនៅខាងកោះកុង ខ្ញុំនៅពីមុនថាឲ្យខ្ញុំនៅ២៧០០ ដល់ចុងក្រោយបំផុតនោះឲ្យខ្ញុំនៅតែ១៧០០ ទេដែលនៅប្រចាំជាប់នៅកោះកុង ដូច្នេះត្រូវការដកបន្តបន្ទាប់មកព្រំដែនខាងកើតទៀត។ ដូច្នេះនៅតែ ១៧០០ហ្នឹង មានការ

ឧបសគ្គ គ្រុន ឈឺ ចាញ់ ឈឺគ្រុនស្លាប់អីផង ដូច្នេះនៅតិចដែរ។ នេះដែលខ្ញុំកំណត់ថា កាលដែលខ្ញុំទៅ គឺមាន២៧០០ ក៏ប៉ុន្តែខាងលើត្រូវដកចេញបន្តបន្ទាប់មកនៅសល់តែ១០០០ នៅសល់តែ ១៥០០ទេ តិចទៅៗ។ សូមបញ្ជាក់មានប៉ុណ្ណឹងឯង។

**ស៖** នៅកោះកុងនិងនៅតាមកោះហ្នឹង តើមានជនស៊ីវិលរស់នៅទេ? ឬក៏ជនស៊ីវិលទាំងអស់ត្រូវបានបញ្ជូនទៅខាងក្រោយអស់ហើយ?

**ឆ៖** បាទ អង្កាល់ដែលខ្ញុំទៅកោះកុងហ្នឹងអត់ៗមានទេ ប្រជាជនគេត្រូវដកចេញអស់ មុនដែលខ្ញុំទៅហ្នឹង គេដកចេញអស់ហើយ។ ដកចេញមកៗកំពង់សិលា វាលរេញ ដែលចាប់ពីត្រឹមត្រពាំងរូងអណ្តូងទឹក ម្តុំតាមកោះអី គឺអត់មានទេ នៅសុទ្ធតែពួកខ្ញុំទាំងអស់ ស្ងាត់។ និយាយរួមនៅស្ងាត់ទាំងអស់ ដូចនៅក្នុងព្រៃអ៊ីចឹង អត់មានប្រជាជនមួយទេ មានគោ មានក្របី ដែរ ក៏ប៉ុន្តែគោក្របីហ្នឹង លែងស្គាល់មនុស្សអស់ហើយ ឃើញបោលចេញ រត់ចេញពីយើងអស់។ អ៊ីចឹងបានន័យថា ខ្ញុំនៅតែកងទ័ពទាំងអស់។ នៅកងទ័ពសុទ្ធតែពួកប្រុសៗទាំងអស់ អត់មានស្រីៗទេ ហើយធ្វើស្រែហូបខ្លួនឯងទៀត ការពារទឹកដីខ្លួនឯងទៀត ធ្វើស្រែខ្លួនឯងទៀត ឧបត្ថម្ភកម្លាំងកងទ័ពខ្លួនឯង បម្រើជីវភាពខ្លួនឯង។ អស់ហើយមានប៉ុណ្ណឹងឯង។

[១៥:៣៨:០៩]

**ស៖** ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងកងពលលេខ៣ ឬកងពល១៦៤ កងពលជើងទឹក លោកថា មាស មុត ជាមេដឹកនាំកងពលនេះ។ ចុះលោកធ្លាប់ជួបឈ្មោះ ឌឹម ទេនៅកោះកុង?

**ឆ៖** កងពល១៦៤ហ្នឹង ខ្ញុំឮមិនច្បាស់ទេ ក៏ប៉ុន្តែក៏មុនគឺថា កងពលលេខ៣ តែក្រោយមកឮថា កងពល៦៤។ ប៉ុន្តែខ្ញុំស្គាល់ច្បាស់ ក្រោយមកគឺថា ដឹងតែកងពល៦៤ ដែលមកជាប់ជើងជាមួយខ្ញុំ សហប្រតិបត្តិការជាមួយគ្នាតាមទឹក តាមកោះ តាមគោកហ្នឹង គឺដឹងច្បាស់ តែកងពល៦៤។ ឯឈ្មោះ ឌឹម ហ្នឹងខ្ញុំស្គាល់ ពីព្រោះអីគាត់មកមុនដំបូង គាត់ជួបខ្ញុំ គាត់ទាក់ទងជាមួយខ្ញុំ ហើយក៏គាត់បានសម្រាកនៅកោះជាមួយខ្ញុំខ្លះដែរ តែគាត់មិននៅជាប់នឹងនរទេ ពីព្រោះអីគាត់មានការងារគាត់ច្រើន។ ជួនកាល នៅបានមួយថ្ងៃ ឬមួយយប់អ៊ីចឹង គាត់ទៅបាត់ទៅ។ ដូច្នេះ នៅត្រឹមតែអនុសេនាធំអីខ្លះដែលនៅជាប់ជាមួយខ្ញុំ។ ដូច្នេះ ខ្ញុំឃើញថាឈ្មោះ ឌឹម ខ្ញុំស្គាល់ ក៏ប៉ុន្តែក្រោយមក ក៏ប្រហែលជាមួយឆ្នាំក្រោយមក មិនបានគាត់មកទៀតទេ មានតែត្រឹមអនុសេនាធំទេ ដែលមកជួបខ្ញុំ។ មានប៉ុណ្ណឹងឯង។

**ស៖** លោកមិនឆ្លើយទៅនឹងសំណួរខ្ញុំទេ ខ្ញុំសួរថាលោកបានជួបឈ្មោះ ឌឹម នេះឬក៏អត់? គាត់

មកពីភូមិភាគបូព៌ា ហើយគាត់នៅក្នុងកងពល១៦៤។ តាមពិតនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E319/23.3.30 នៅចម្លើយទី៣ លោកបាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំចាំពីឈ្មោះ ឌឹម ស្លាប់។ គាត់បើកនាវានៅកោះកុង ហើយគាត់បានជួបខ្ញុំ។ ហើយនៅចម្លើយ១២ហ្នឹង លោកថា ឌឹម មកពីភូមិភាគបូព៌ា។" ដូច្នេះលោកចាំអំពីមុខងាររបស់ ឌឹម ទេ គាត់ធ្វើអ្វីដែរ ហើយពេលដែលលោកជួបគាត់ហ្នឹងលោកនិយាយគ្នាអំពីរឿងអ្វីដែរ?

**ឆ៖** អម្បាញ់មិញហ្នឹងខ្ញុំប្រាប់ហើយតើ អំមិញខ្ញុំប្រាប់ពីរឿងឈ្មោះ ឌឹម តើ! ថាគាត់បានមកជួបខ្ញុំតើ! ហើយម៉េចថាខ្ញុំមិនឆ្លើយតាមហ្នឹង? បើឈ្មោះ ឌឹម ហ្នឹង គាត់បានមកសម្រាកជាមួយខ្ញុំមួយយប់ដែរតើ។ ហើយក្រោយមកគាត់បានសហការជាមួយខ្ញុំ ដែលកាលមុនគាត់មកហ្នឹង គាត់សហការជាមួយខ្ញុំការពារជើងទឹក ការពារកប៉ាល់អីគាត់ហ្នឹង គាត់បានមកសហការជាមួយខ្ញុំដែរតើ។ ប៉ុន្តែក្រោយមក វាមិនឃើញព្រោះអីបាត់គាត់ទៅ ក៏ខ្ញុំមិនបានសួរថាគាត់ស្លាប់ ឬក៏គាត់រស់ ខ្ញុំមិនបានដឹងថាគាត់ស្លាប់ទេ ប៉ុន្តែខ្ញុំដឹងថាវាបាត់ បាត់ពីកន្លែងដែលសមរភូមិខ្ញុំ ដែលជួបខ្ញុំហើយ បាត់គាត់រហូតមកលែងមកជួបខ្ញុំវិញ។ គ្រាន់តែថាប៉ុណ្ណឹងតើ អំមិញខ្ញុំប្រាប់ហើយតើ។

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីឆ្លើយតបត្រឹមត្រូវហើយ សំណួរទេដែលសួរមិនច្បាស់លាស់ សំណួរគ្រាន់តែបានជួប គាត់បានឆ្លើយជួប ហើយគាត់បានស្គាល់ច្បាស់ហើយ។ ហើយលោកចង់ដឹងរឿងអីផ្សេងទៀតលោកអត់ទាន់សួរគេផង ម៉េចក៏ទៅដកស្រង់នូវប្រតិចារឹកដែលវាហួសពីសំណួរដែលលោកតាំងសំណួរចំពោះសាក្សី?

[១៥:៤១:៥៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន ខ្ញុំមិនទទួលបានការបកប្រែនូវចម្លើយរបស់សាក្សីទាំងស្រុងទេ។

**ប្រធានអង្គជំនុំ៖**

តែអំមិញគឺលោកបានដកស្រង់ហ្នឹង គឺវាហួសពីសំណួរដែលលោកសួរចំពោះសាក្សី។ សួរគ្រាន់តែបានជួប ហើយនិងស្គាល់ទេ លោកអត់បានតាំងសំណួរថា ពាក្យថាស្គាល់ហ្នឹង តើមកពីណា? ហើយគាត់មានមុខងារធ្វើអី សំណួរនេះមិនទាន់សួរទេ។ សាក្សីឆ្លើយពេញលេញហើយតបទៅនឹងសំណួររបស់លោកដែលសួរនោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ប្រហែលជាភាសាបារាំងបកប្រែនោះ ខ្ញុំមិនទទួលបានចម្លើយពេញ អ៊ីចឹងបានជាខ្ញុំមិនសូវយល់នូវចម្លើយរបស់គាត់នោះ។ ខ្ញុំស្មានតែគាត់និយាយជាទូទៅ មិននិយាយអំពី ឌឹម នេះទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំសូមចូលទៅម្នាក់ទៀត នៅក្នុងកងពល១៦៤។ លោកស្គាល់ឈ្មោះ សារឿន ទេ? ហើយ សារឿន នេះជាសាច់ញាតិលោកទេ?

**លោក មាស រឿន៖**

**ឆ៖** ស្គាល់។ នៅក្នុងកងពល១៦៤ ខ្ញុំស្គាល់ ពីព្រោះអីប្អូនជីដូនមួយខ្ញុំ។

**ស៖** លោកដឹងថា សារឿន គាត់មានមុខងារអ្វីនៅក្នុងកងពល១៦៤ នៃកងទ័ពជើងទឹកហ្នឹង?

**ឆ៖** គាត់ទទួលជាបញ្ជាការ ទទួលជាបញ្ជាការកងពល៦៤។

**ស៖** ក្នុងពេលលោកធ្វើការបីឆ្នាំនៅកោះកុង លោកធ្លាប់ទាក់ទងគ្នាជាមួយ តាសារឿន ទេ? ហើយលោកមានបាននិយាយគ្នាជាមួយគាត់អំពីសភាពការណ៍ខ្មាំងយួនទេ?

**ឆ៖** អត់បានមកជួបគ្នាទេ ពីព្រោះខ្ញុំហើយនិង សារឿន មិនបានជួបគ្នាទេ ពីព្រោះអីគាត់មានការងារទៅខាងនោះ ឲ្យតែគាត់ណែនាំតែកូនចៅគាត់មកជួបនឹងខ្ញុំ។

[១៥:៤៤:៣៧]

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីការទាក់ទង និងការផ្លាស់ប្តូរព័ត៌មានគ្នារវាងកងពលលេខ១ និងកងពល១៦៤ នៅកោះកុង។ អ្នកណាជាតំណាងកងពល១៦៤ ដែលមានវត្តមានជាអចិន្ត្រៃយ៍នៅកោះកុង? គឺនៅឆ្នាំ៧៧ និងឆ្នាំ៧៨?

**ឆ៖** ខ្ញុំដឹងថាៗ លោក សារឿន ហើយនិងឈ្មោះ តាមុត – មុត, សារឿន។ ប៉ុន្តែ រឿន គាត់ដឹងថាបញ្ជាការហើយ គាត់ទទួលបញ្ជាការ។ ប៉ុន្តែការចូលរួមប្រហែល តាមុត ហើយ តាមមើល៍ ព្រោះអីគាត់ ខ្ញុំដឹងថា តាមុត គាត់នៅទទួលខុសត្រូវនៅកន្លែងហ្នឹង។

**ប្រធានអង្គជំនុំ៖**

សំណួរមិនសួរអ៊ីចឹងទេលោកសាក្សី។ សំណួរសួរថាតើលោកដឹងទេ តើអ្នកណាជាតំណាងរបស់កងពល១៦៤ ប្រចាំការនៅកោះកុងក្នុងអំឡុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។

**លោក មាស វឿន៖**

**ឆ៖** បាទ ៧៧, ៧៨ ខ្ញុំអត់បានដឹងទេ។ ខ្ញុំដឹងតែ៧៥មក ត្រឹម៧៥, ៧៦ -- ៧៥ ខ្ញុំដឹងត្រឹម៧៥ ហ្នឹងឯង ដល់៧៧-៧៨ ខ្ញុំអត់ដឹងថាអ្នកណានៅទទួលរងរ៉ាប់នៅកន្លែងហ្នឹងផង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នៅចម្លើយ៣៣ នៃកំណត់ហេតុ E319/23.3.31 លោកនិយាយអំពីឈ្មោះ ស៊ីម ជាមេបញ្ជាការអនុសេនាធំ។ លោកថាកងអនុសេនាធំនេះមាននាវាប្រាំមួយគ្រឿង។ អ៊ីចឹងតើលោកមានសហការគ្នាជាមួយនឹងឈ្មោះ ស៊ីម ហ្នឹងទេ ដែលជាមេបញ្ជាការអនុសេនាធំនោះ?

**ឆ៖** បាទ ស៊ីមៗ ហ្នឹងនៅជាមួយនឹងខ្ញុំនោះឯង ខ្ញុំស្គាល់ច្បាស់ហើយ ស៊ីម ហ្នឹង អនុសេនាធំតើមិនមែនអ្នកទទួលខុសត្រូវរួមណា៎ គាត់អនុសេនាធំតើ មកភ្ជាប់ជើងជាមួយនឹងខ្ញុំនោះឯង។ គាត់ថ្នាក់គាត់ត្រឹមអនុសេនាធំទេ។ កប៉ាល់គាត់មិនមែនប្រាំមួយគ្រឿងទេ តែបីតើ! បីៗ និងកប៉ាល់នែ៎ កប៉ាល់របស់អាមេរិកាំង ឈ្មោះកប៉ាល់អីទេអាហ្នឹងនោះ អូប័រ។ ហ្នឹងកប៉ាល់អីទេរបស់អាមេរិកាំងពីរគ្រឿងដែរអាហ្នឹង។ តែមិនដល់ប្រាំមួយគ្រឿងទេ របស់ចិនបីគ្រឿង -- ប្រាំគ្រឿង។

[១៥:៤៨:០១]

**ស៖** តើ ស៊ីម និងកម្មាភិបាលផ្សេងទៀតនៃកងពល១៦៤ មាននាវាលឿនដើម្បីអាចចាប់នាវាបរទេសដែលតូចៗ ឬក៏ធំដែលចូលមកដែនទឹកយើងទេ? តើកងពល១៦៤ហ្នឹង មានកប៉ាល់លឿនដើម្បីចាប់កប៉ាល់នេសាទថៃ ឬក៏កប៉ាល់ជនភៀសខ្លួនវៀតណាមទេ?

**ឆ៖** បាទ មានដែរ មានតែកប៉ាល់នោះតូចល្មមទេ តែវាលឿនអាចចាប់បាន។ តែបើល្បឿន វាលឿនហើយ គ្រាន់តែប្រដាប់វា -- បច្ចេកទេសវាតិចទេ។

**ស៖** នាវាលឿនរបស់អាមេរិកាំងហ្នឹង គេហៅថា ប៉េ.សេ.អេហ្វ ហ្នឹងមែនទេ?

**ឆ៖** បាទ ប៉េ.សេ.អេហ្វ ខ្ញុំភ្លេចឈ្មោះ។ ប៉េ.សេ.អេហ្វ ហ្នឹងមិនលឿនដល់កប៉ាល់មកពីចិនទេ មកពីចិនវាលឿនជាង ព្រោះអីអាប៉េ.សេ.អេហ្វហ្នឹងវាមានពីរគ្រឿង, អាកប៉ាល់ចិនហ្នឹងវាមានបីគ្រឿង។

**ស៖** ចុះនាវានៅកោះកុងដែលមានទំហំធំជាងគេហ្នឹង គឺប៉ុន្មានសេះដែរលោកដឹងទេ?

**ឆ៖** កប៉ាល់ធំមិនសូវហ៊ានចូលមកទេ គេចតនៅតែឯកោះកុង តែបើគ្រាន់ប្រចាំការនៅហ្នឹងមានតែត្រឹមកប៉ាល់ ប៉េ.សេ.អេហ្វ របស់អាមេរិកហ្នឹង ហើយនិងកប៉ាល់ចិន អាហ្នឹងធុនប៉ុន្មានសេះទេ ខ្ញុំមិនដឹងដែរ តែវាលឿន។ ហើយមានទូកទំហំ២៥០សេះមានពីរគ្រឿង ហើយ១៥០សេះ មានពីរគ្រឿង

ដែរ។ មានប៉ុណ្ណឹង ធំៗមានប៉ុណ្ណឹង។

[១៥:៥០:០០]

**ស៖** ចុះកាណូតរៀតណាមដែលចូលមកដល់ក្នុងតំបន់របស់លោកនោះ តើកាណូតទាំងអស់ហ្នឹងមានទំហំសេះហ្នឹងធំទេ?

**ឆ៖** តូចៗហ្នឹង ត្រឹម៣០សេះ ៤០សេះប៉ុណ្ណឹងឯង មិនជាធំប៉ុន្មានទេ។

**ស៖** ក្រៅពីនាវារបស់កងពល១៦៤ តើកងពលលេខ១ មាននាវាសម្រាប់ចាប់ទូក ឬក៏កាណូតរបស់ថៃដែលមានទំហំពី៣០ទៅ៤០សេះទេ?

**ឆ៖** មានៗកាណូតត្រឹម១៥០សេះមាន តែកាណូតទេ មិនមែនជាកប៉ាល់ទេ ប៉ុន្តែវាធន់កម្លាំងម៉ាស៊ីនវា១៥០មានពីរបីគ្រឿង។

**ស៖** ខ្ញុំចង់សូមការបញ្ជាក់មួយពាក់ព័ន្ធនឹងខ្សែបញ្ជាដែលនៅពីលើលោក នៅក្នុងកងពលលេខ១ លោកទទួលបញ្ជា និងលោករាយការណ៍តែទៅ តាសឿង ហ្នឹងមែនទេ ឬក៏លោករាយការណ៍ទៅអ្នកណាដែលនៅពីលើទៀត?

**ឆ៖** បាទ ខ្ញុំមានសភាពការណ៍ ខ្ញុំរាយការណ៍ទៅខាង បងសឿង មួយ។ អត់មានទៅខាងណាទៀតទេ លុះត្រាណាតែគាត់អត់នៅ គាត់ប្រាប់ថាត្រូវរាយការណ៍ឲ្យទៅខាងភាគ។ ខ្ញុំរាយទៅខាងភាគ តែបើគាត់មិនប្រាប់ទេ ខ្ញុំអត់បានរាយទៅខាងនុ៎ងទេ ទាល់តែគាត់ប្រាប់។ រាយទៅតែខាង តាសឿង តែមួយមុខហ្នឹង។

[១៥:៥២:២៥]

**ស៖** តើមន្ទីររបស់លោកមានឈ្មោះជាលេខទេ?

**ឆ៖** ខ្ញុំ មន្ទីររបស់ខ្ញុំអត់មានមន្ទីរឯណា ខ្ញុំនៅតែតាមៗកន្លែងធម្មតាដូចតែទាហាន ដូចតែគ្នាអត់មានកន្លែងមន្ទីរទេ មានតែកន្លែងធ្វើរោង កងនៅតិចតួច។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺលោកទំនាក់ទំនងគ្នាជាមួយ តាសឿង ហើយនិងភូមិភាគបស្ចិមហ្នឹង គឺតាមរយៈទូរលេខ។ អ៊ីចឹងទាល់តែមានមន្ទីរមួយបានអាចដាក់ទូរលេខសម្រាប់ទទួល និងផ្ញើបាននោះ?

**ឆ៖** ហ្នឹងមាននៅផ្ទះគេចាស់ៗហ្នឹង ខ្ញុំមិនមានធ្វើអីដូចគេឥឡូវអី ខ្ញុំមានតែផ្ទះចាស់សម្រាកសម្រាប់នៅសម្រាកបណ្ដោះអាសន្នហ្នឹង។

**ស៖** តើលោកធ្លាប់ទទួលបញ្ជាដោយផ្ទាល់ពី តាខៀវ ទេ គឺ សុន សេន នុ៎ង?

**ឆ៖** អត់ទេ។ អត់បានទទួលទេ។

**ស៖** ខ្ញុំចង់បំភ្លឺចំណុចនេះ ពីព្រោះថានៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺE3/8752 ទំព័រ២៧ ជាភាសាអង់គ្លេស និងទំព័រ៣០ ជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "តាខៀវ មិនដែលមកជួបខ្ញុំទេ យើងទំនាក់ទំនងគ្នាតាមរយៈវិទ្យុទាក់ទង ជួនកាលខ្ញុំទទួលបញ្ជាពីគាត់ ជួនកាលទទួលពីកងពលដែលមានមេបញ្ជាការឈ្មោះ បងសឿង ម្តងម្កាល មួយសប្តាហ៍ ឬក៏មួយខែម្តង គឺថាយើងមានការទំនាក់ទំនងគ្នា"។ តាមរយៈចម្លើយនេះ គឺមានន័យថា សុន សេន ទំនាក់ទំនងជាមួយលោកតាមទូរលេខ ឬក៏តាមវិទ្យុទាក់ទង ហើយនិងមានការចេញបញ្ជាផងដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកថា លោកទទួលបញ្ជាពី សុន សេន នេះផ្ទាល់តែម្តង ឬក៏បញ្ជាត្រូវឆ្លងកាត់តាម តាសឿង សិន ទើបមកដល់លោក?

**ឆ៖** បាទ ខ្ញុំទទួលតាម បងសឿង។ ឧបមាថា បើៗ សុន សេន គាត់ៗបញ្ជាមក បងសឿង – បងសឿង គាត់ៗប្រាប់មកខ្ញុំ គាត់ដាក់ឈ្មោះគាត់ផង ហើយឃើញឈ្មោះអ៊ំ សុន សេន ជាប់នឹងៗក្រដាសសារទូរលេខហ្នឹងដែរ។ អ៊ីចឹងបានន័យថាគាត់បញ្ជាមកតាម បងសឿង – បងសឿងមកតាមខ្ញុំ។

[១៥:៥៥:៥១]

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីចម្លើយរបស់លោក ដែលលោកបាននិយាយកាលពីមុន គឺលោកនិយាយពាក់ព័ន្ធទៅនឹងជនភៀសខ្លួនវៀតណាម និងកាណូតវៀតណាមដែលលោកហៅថា "យួន"។ ដូច្នេះនៅសម័យនោះ បើតាមអ្វីលោកដឹងនោះ ពាក្យ "យួន" នេះ វាមាន វាសំដៅទៅលើជនស៊ីវិល ឬក៏ជាទាហាន ឬក៏ឲ្យតែវៀតណាម ជនជាតិវៀតណាម គេហៅថា យួន តែម្តង?

**ឆ៖** តាមធម្មតា ជនជាតិខ្មែរ គេច្រើនតែហៅយួនអ៊ីចឹងតាំងគ្រប់គ្នា ខ្ញុំក៏ហៅតាមប្រជាជនខ្មែរអ៊ីចឹងដែរ ប្រជាជនកម្ពុជាអ៊ីចឹងដែរ។ គេហៅតែយួនៗអ៊ីចឹង មិនសូវឮវៀតណាមផង។

**ស៖** ខ្ញុំនៅសល់ពេលតិចណាស់សម្រាប់រសៀលនេះ ខ្ញុំសួរលោកប្រធានបទមួយពីរទៀត។ ជាដំបូង គឺពាក់ព័ន្ធទៅនឹងវៀតណាមនៅក្នុងទឹកដីកម្ពុជា ខ្ញុំមិននិយាយអំពីជនភៀសខ្លួនទេ ខ្ញុំនិយាយអំពីជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ តើលោកធ្លាប់ស្តាប់ឮថាមានផែនការកម្ទេចវៀតណាមដែលរស់នៅកម្ពុជានៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ទេ?

**ឆ៖** មានៗឮរឿងវៀតណាមនៅក្នុងស្រុកខ្មែរហ្នឹង ពីព្រោះអីវៀតណាមដែលនៅក្នុងស្រុកខ្មែរ

ហ្នឹងមិនមែននៅដើម្បីរកស៊ីទេ នៅដើម្បីបង្ករឿងហេតុឲ្យប្រជាជនកម្ពុជាលំបាកដែរ។ អ៊ីចឹងបានន័យថា ជាៗការងារដែលត្រូវកម្ទេចហ្នឹង ឲ្យប្រជាជនគេឲ្យទៅតាមសម្រួលហ្នឹង កាលមុនគេឲ្យទៅតាមសម្រួល ដោយតាំងពីឆ្នាំ៧០នោះ។ រឿងៗវៀតណាម ថ្នាក់ដឹកនាំខ្មែរយើងឲ្យទៅតាំងពីឆ្នាំ១៩៧០ រហូតមក៧៥ ក៏ឲ្យទៅដែរ តែគេអត់ចង់ទៅ អាហ្នឹងគេមានទិសដៅ ឬផែនការ។ អ៊ីចឹងតាមអង្គភាពអ៊ីចឹង ឲ្យតែជនជាតិវៀតណាមត្រូវកម្ទេចអ៊ីចឹង។ អាហ្នឹងខ្ញុំឆ្លើយត្រង់អ៊ីចឹង។ បើកាលណា គេឲ្យទៅហើយ យើងមិនព្រមទៅ ហើយម្យ៉ាងបានកើតជាវិវាទគ្នាតាមព្រំដែន ដោយសារអី? ហ្នឹងខ្ញុំឮអ៊ីចឹង។ សូមអស់។

[១៥:៥៨:៥១]

**ស៖** តើមានជនជាតិវៀតណាមច្រើនទេដែលមិនព្រមទៅស្រុកវិញ ហើយត្រូវបានកម្ទេចចោល? ឧទាហរណ៍ដូចជានៅក្នុងភូមិភាគបស្ចិមនោះ លោកមានធ្លាប់ឮថា នៅមានវៀតណាមណានៅក្នុងភូមិភាគហ្នឹងទេ?

**ឆ៖** មាន នៅមាននៅ មិនមែនទៅអស់ទេ។ កាលដែលគេឲ្យទៅ ទៅមិនអស់ ខ្លះក៏នៅនឹងទៅ ខ្លះក៏មានប្រពន្ធ មានកូននៅនឹងទៅ។ អាហ្នឹងក៏គេមិនថាអីដែរ ក៏ប៉ុន្តែការដែលគេឲ្យទៅស្រួល យើងមិនព្រមទៅ ប៉ុន្តែនៅភូមិភាគបស្ចិមមាននៅច្រើន ភាគច្រើនតាមមាត់ទន្លេនៅកំពង់ឆ្នាំង។ លោកឃើញស្រាប់ហើយរាល់ថ្ងៃ មានខ្មែរឯណានៅក្នុងទឹក។ អ៊ីចឹងបានន័យថាខ្មែរច្រើនតែមានការប្រទូសរ៉ាយគ្នា រវាងជនជាតិវៀតណាម ហ្នឹងហើយនិងខ្មែរនោះ វានៅបង្ករឿងហេតុ។ ហ្នឹង គឺក្នុងភូមិភាគបស្ចិមមាន។ នៅរហូតដល់យួនវាយចូលស្រុកខ្មែរទៀត ឆ្នាំ៧៩ហ្នឹង។ ហ្នឹងឃើញថាទៅនុ៎ង។ ការពិត អត់ទៅទេ នៅរហូតទាល់តែយួនវាយចូលស្រុកខ្មែរ រហូតទាល់រាល់ថ្ងៃ។ អស់ហើយខ្ញុំ។

**ស៖** លោកបាននិយាយអំពីប្ដីប្រពន្ធដែលមានជាតិសាសន៍ចម្រុះ ហើយនិងជនជាតិវៀតណាម ដែលមិនទៅស្រុកវិញដោយសារតែរៀបការជាមួយប្ដី ឬក៏ប្រពន្ធខ្មែរ។ ខ្ញុំចង់សួរថា បើសិនជាប្រពន្ធវៀតណាម ហើយប្ដីខ្មែរនោះ តើគេយ៉ាងម៉េចចំពោះកូន? គេត្រូវកម្ទេចទាំងកូនដែរ ដោយសារកូនហ្នឹងជាខ្មាំង ឬក៏យ៉ាងម៉េច?

**ឆ៖** អាហ្នឹងក្នុងជំនាន់នុ៎ងបីឆ្នាំ ខ្ញុំមិនបានដឹងៗអស់ទេ ពីព្រោះអី ខ្ញុំមិនបានដឹងកិច្ចការប្ដីខ្មែរ ប្រពន្ធ -- ប្ដីយួនប្រពន្ធខ្មែរ។ ប៉ុន្តែការពិតខ្ញុំឃើញអ៊ីចេះ នេះខ្ញុំនិយាយត្រង់ ពីព្រោះអីដែលមីងខ្ញុំគាត់មានប្ដីយួនតាំងពីជំនាន់សង្គ្រាមឥស្សរៈ ហើយក៏បានកូនៗពីរ។ យួន មកស្រឡាញ់ខ្មែរដល់យួនចូលស្រុកខ្មែរ ជំនាន់ឥស្សរៈហ្នឹង ហើយនៅផ្ទះជិតខ្ញុំហ្នឹង អាហ្នឹងមីងខ្ញុំ ហើយគាត់មានកូនពីរហ្នឹង។ ហើយដល់ពេល

យួនចូលមកឆ្នាំ៧០ គាត់យកកូនក្មួយខ្ញុំហ្នឹងទៅស្រុកនៅរាល់ថ្ងៃហ្នឹងឯង។ នៅខេត្តតាយនិញ ហើយដល់ពេលហ្នឹងប្តីគាត់ ពេលនុ៎ងគេចាប់។ ហើយខ្ញុំនិយាយឲ្យអស់ហេតុការណ៍ ប្តីគាត់យួនហ្នឹងគេចាប់ ហើយដល់គេចាប់ប្តីបាត់ទៅ គាត់ក៏ភ័យដែរ រត់ៗគេចាប់ៗទាំងមីងខ្ញុំហ្នឹងទៀត ដូច្នេះអស់ ដូច្នេះនៅសល់តែកូនមួយនៅស្រុកយួន។ នេះដែលយើងឃើញថា ហ្នឹងដែលជា ដែលខ្ញុំដឹង តែរឿងផែនការដទៃទៀត ខ្ញុំមិនដឹងថាច្បាប់រដ្ឋរបស់ខ្មែរយើងត្រូវដោះស្រាយយ៉ាងណា អាហ្នឹងខ្ញុំមិនបានដឹងកិច្ចការងារហ្នឹងទៅមុខទៀតទេ ក៏ប៉ុន្តែក្នុងសម័យហ្នឹងគេកំពុងខឹងយួនដែរ។ គេទាំងអស់គេកំពុងខឹងយួនដែរ រហូតដល់យួនវាយចូលស្រុកខ្មែរអ៊ីចឹងក៏កំពុង -- ក៏នៅតែខឹង។ អ៊ីចឹងហើយបានន័យថា រឿងការងារហ្នឹង បញ្ហាហ្នឹងវានៅមានគំនុំ។ គេនិងខ្ញុំវាមានចិត្តមួយគឺថា បើនៅមានសេចក្តីសុខខអត់អីទេ កុំឲ្យនៅមានកើតទុក្ខ។ អ៊ីចឹងក្នុងសម័យហ្នឹងវាមានបាត់អ៊ីចឹង។ ដូច្នេះបានន័យថា គឺគេកំពុងស្អប់យួន។ អ៊ីចឹងអ្នកមានណាដទៃទៀតដែលគេមិនទាន់បានធ្វើអីហ្នឹងក៏នៅរហូតទាល់រាល់ថ្ងៃហ្នឹងទៅ គេអត់មានធ្វើអីផង។ ខ្ញុំសូមអស់។

[១៦:០៣:០៧]

**ស៖** លោកប្រធាន សូមអនុញ្ញាតសួរសំណួរចុងក្រោយ។ ជនជាតិវៀតណាមដែលរស់នៅកម្ពុជាតាំងពីយូរណាស់មកហើយនោះ ហើយដែលនិយាយចេះនិយាយភាសាខ្មែរច្បាស់ទៀតនោះ តើលោកដឹងថារដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យធ្វើយ៉ាងម៉េចដើម្បីអាចបែងចែកបានថា អ្នកណាជាខ្មែរ អ្នកណាវៀតណាមនោះ បើវៀតណាមហ្នឹងគាត់នៅខ្មែរតាំងពីយូរហើយ គាត់និយាយខ្មែរច្បាស់ដូចខ្មែរដែរនោះ?

**ឆ៖** អានេះខ្ញុំមិនអាចអារកាត់បានទេ ក៏ប៉ុន្តែបើយើងនិយាយពីសិទ្ធិរបស់មនុស្សនោះ ខ្ញុំក៏ឃើញអ៊ីចេះ សូម្បីតែប្រពន្ធសម្តេច សីហនុ ក៏ៗយួនដែរ ខ្ញុំនិយាយត្រង់ តែម៉េចក៏គាត់នៅបាន។ ដូច្នេះបើគាត់នៅបាន ហើយគេទាំងអស់នោះក៏អាចគេនៅបានដែរ តែគេនៅបានសេចក្តីសុខ ក៏គេនៅបានសេចក្តីសុខហើយ យើងក៏អត់មានបញ្ហាអីជាមួយគេដែរ។ តែក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំយល់ថាគេមិនឲ្យនៅទេ ពីព្រោះអីវានៅមានហេតុការណ៍បង្ករឿង ពីព្រោះអីចង់បាន ពីព្រោះយើងដឹងថាយើងបានរៀនចេះដឹងខ្លះដែរ ពីរឿងយួនហើយខ្មែរ។ ហើយយួន ខ្មែរ លាវ លោកក៏អាចដឹងដែរ--

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយចាកប្រធាន ចាកនឹងសំណួរ សំណួរមិនសួរអ៊ីចឹងទេ។ សំណួរគេសួរថា តើតាមជាការដែលលោកធ្វើការសង្កេត ឬកត់សម្គាល់នេះ ដើម្បីកត់សម្គាល់បុគ្គលណាមួយថាជាជនជាតិយួនដោយសារគាត់ហ្នឹងមករស់នៅស្រុកខ្មែរហ្នឹងយូរហើយ គាត់និយាយជាភាសាខ្មែរច្បាស់លាស់អ៊ីចឹង។

តើលោកអាចគេបែងចែកយ៉ាងម៉េចដែល ដើម្បីសម្គាល់ថា បុគ្គលម្នាក់ហ្នឹងជាយួន ហើយដែលបែងចែកជាមួយនឹងជាខ្មែរ? តើលោកមានការកត់សម្គាល់ ឬក៏បែងចែកបានទេរវាងអ្នកដែលជាជនជាតិយួននៅស្រុកខ្មែរហ្នឹង ដែលមកនៅយូរហើយ ហើយជាមួយនឹងខ្មែរដទៃទៀត គេបែងចែកដោយសារបញ្ហាអីខ្លះ? ហើយចម្លើយសូមឆ្លើយឲ្យចំទៅនឹងសំណួរបានហើយ កុំឲ្យអត្ថាធិប្បាយវែងបង្កើតជាបញ្ហាច្រើនសំណួរនិងសួរទៅលោកទៀត ពីព្រោះអង្គជំនុំជម្រះចង់ឲ្យលោកឆ្លើយតបពេញលេញចាំបាច់ ទៅនឹងសំណួរដែលសួរលោកបានហើយ។

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំមិនដែលជួបប្រទះថារៀបឲ្យគេនៅ រស់នៅយ៉ាងម៉េចទេ ពីព្រោះស្រេចតែច្បាប់រដ្ឋទេតទៅទៀត ឬក៏ពីមុនៗគឺថាគេមិនឲ្យនៅទេ តែក្រោយនេះខ្ញុំមិនដឹងដែរ។ ខ្ញុំឆ្លើយខ្លីប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

លោកៗសាក្សី លោកអ៊ីចេះ ចង់កត់សម្គាល់ថា ចំពោះលោកផ្ទាល់តើលោកកត់សម្គាល់ថាបែងចែករវាងជនជាតិយួន និងជនជាតិខ្មែរដែលនៅរស់នៅទៅលើទឹកដីខ្មែរហ្នឹងបែងចែកតាមអី ពណ៌សម្បុរសម្លៀកបំពាក់ ឬក៏ពាក្យសម្ដីដែលគាត់និយាយ? ឧបមាថាគាត់និយាយរដឺនៗអ៊ីចឹង យើងស្គាល់ថា អ្នកនេះជាជនជាតិយួន អ្នកនេះជាជនជាតិខ្មែរអ៊ីស្លាមអ៊ីចឹង យល់ទេ? តើលោកអាចធ្វើការកត់សម្គាល់ ឬក៏ធ្វើការបែងចែកនេះបានទេ? ហើយអ្នកដទៃទៀតហ្នឹងគេធ្វើបែបលោកដែរទេ ក្នុងការកត់សម្គាល់បែងចែកប្រភេទមនុស្សដែលរស់នៅក្នុងសង្គមខ្មែរកាលនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ គេសម្គាល់ដូចលោកប្រធានលើកអ៊ីចឹងហើយ ប៉ុន្តែគេសម្គាល់ថា និយាយមិនច្បាស់ទី១ និយាយមិនច្បាស់ ហើយទី២ គឺប្រជាជនគេនៅជិតខាងគេដឹងប្រវត្តិគាត់នៅនឹងប៉ុន្មានឆ្នាំមកហើយ អីមកហើយហ្នឹងគេ ភាគច្រើនគេៗស្គាល់ យើងៗមិនអាចស្គាល់គេបានថា ព្រោះអីគេនិយាយខ្មែរ និយាយអក្សរខ្មែរ និយាយភាសាច្បាស់លាស់មែន ក៏ប៉ុន្តែសំអាងលើប្រជាជនដែលនៅក្នុងស្រុក ក្នុងភូមិដែលគេនៅយូរហើយគេដឹង គេដឹងគេប្រាប់យើង។ សូមមានមតិប៉ុណ្ណោះ។

[១៦:០៧:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយ ឥឡូវនេះសវនាការនៅថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះ

ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅស្អែក ថ្ងៃពុធ ទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ចាប់ពីផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយសវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនេះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី មាស វឿន នៅពេលព្រឹក និងបន្តស្តាប់សក្ខីកម្មសាក្សី អ៊ុន យឿន នៅពេលរសៀលសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក មាស វឿន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី សុក សុជាតា មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមេធាវីមកចូលរួម ប្រឹក្សាសាក្សី មាស វឿន នៅក្នុងសវនាការនៅព្រឹកថ្ងៃស្អែកទៀតដែរ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក មាស វឿន ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៨នាទី)*